និទានកថា
EDITORIAL

# ៣៦ឆ្នាំនៃការតស៊ូប្រឹងប្រែង និងជ័យជម្នះប្រកបដោយមោទនភាពរបស់ប្រជាជនកម្ពុជា

# Cambodian People's 36 Years Efforts and Proud Achievements

ប្រវត្តិសាស្ត្រកម្ពុជាបានកត់ត្រាទុកនូវព្រឹត្តិការណ៍ នៃការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា(បច្ចុប្បន្នរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា)នាថ្ងៃ ២ ធ្នូ ឆ្នាំ១៩៧៨ នៅស្រុកស្នួលខេត្តក្រចេះ នៅកណ្តាលពេលវេលាដ៏ខ្មៅងងឹត ដែលប្រជាជនទូទាំងប្រទេសកំពុងទទួលរងការសម្លាប់រង្គាលដោយរបបកម្ពុជាប្រជាធិបតេយ្យរបស់ប៉ុល ពត ដែលបានអនុវត្តនយោបាយប្រល័យពូជសាសន៍យ៉ាងឃោរឃៅបំផុត។ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា គឺជាអង្គការចាត់តាំងខាងនយោបាយ និងយោធាតែមួយគត់ដែលបានប្រមូលផ្តុំអ្នកស្នេហាជាតិពីគ្រប់ទិសទី ឲ្យក្រោកឈរតស៊ូវាយរំលំរបបដ៏យង់ឃ្នងនេះឲ្យដួលរលំនៅថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩។ ជ័យជម្នះជាប្រវត្តិសាស្ត្រនេះបានសង្គ្រោះអាយុជីវិតប្រជាជាតិខ្មែរឲ្យរស់រានមានជីវិតឡើងវិញទាន់ពេលវេលា និងបើកឡើងនូវសករាជថ្មីនៃកម្ពុជា។ ពេលនេះប្រជាជនទូទាំងប្រទេសកំពុងរីករាយអបអរសាទរប្រារព្ធខួបអនុស្សាវរីយ៍លើកទី ៣៦ ថ្ងៃបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងទិវាជ័យជម្នះ ៧ មករា ក្នុងស្មារតីចងចាំជានិច្ចនូវគុណូបការៈដ៏ធំធេងនៃយុទ្ធជន យុទ្ធនារីកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមរាប់ម៉ឺនសែននាក់ ដែលបានធ្វើពលិកម្មយ៉ាងអង់អាចក្លាហានបំផុត ដើម្បីសង្គ្រោះ និងការពារការរស់ឡើងវិញរបស់ប្រជាជនកម្ពុជា។មានរណសិរ្ស២ធ្នូទើបមានជ័យជម្នះ៧មករា មានជ័យជម្នះ៧មករាទើបយើងមានអ្វីៗសព្វយ៉ាងដូចថ្ងៃនេះ ។ នេះជាសច្ចធម៌ប្រវត្តិសាស្ត្រដែលគ្មានមជ្ឈដ្ឋានណាអាចបំភ្លៃបានឡើយ។

៣៦ ឆ្នាំបានកន្លងផុតទៅ មាតុភូមិកម្ពុជាដែលត្រូវបានរំដោះចេញផុតពីរបបប្រល័យពូជសាសន៍ ហើយបានឈានមកដល់ដំណាក់កាលបច្ចុប្បន្ននេះ គឺត្រូវឆ្លងកាត់ឧបសគ្គ និងការលំបាករាប់ម៉ឺនសែនជំពូកដែលពុំអាចនឹងពណ៌នាអស់បានឡើយ។ ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ដែលមានសម្តេចទាំងបីជាប្រមុខដ៏ឈ្លាសវៃ ប្រជាជនដែលនៅរស់រានរួចផុតពីរបបប៉ុលពត បានរួមសាមគ្គីកៀកស្មាគ្នាដើម្បីប្រយុទ្ធទប់ស្កាត់ការប៉ុនប៉ងវិលត្រឡប់មកវិញនៃរបបដ៏យង់ឃ្នងនេះ និងស្តារសេដ្ឋកិច្ចសង្គមឡើងវិញតាំងពីលេខសូន្យ ឲ្យមានការរីកចម្រើនជាជំហានៗ។ ប្រទេសកម្ពុជាដែលជាសមរភូមិនៃសង្គ្រាមដ៏រ៉ាំរ៉ៃ បានប្រែក្លាយជាទឹកដីមានសន្តិភាពពេញលេញមានការអភិវឌ្ឍដ៏ខ្លាំងក្លាប្រជាជនមានសិទ្ធិសេរីភាពបរិបូរ និងកំពុងធ្វើជាម្ចាស់លើជោគវាសនារបស់ខ្លួន។ កម្ពុជាត្រូវបានវាយតម្លៃថាជាប្រទេសទី ១៥ លើពិភពលោក ដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេល១០ឆ្នាំចុងក្រោយជាប្រទេសទី៥ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ដែលអាចសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សនិងស្ថិតក្នុងចំណាត់ថ្នាក់ទី១នៅអាស៊ីប៉ាស៊ីហ្វិកដែលសម្រេចបានវឌ្ឍនភាពដ៏ល្អប្រសើរ ក្នុងការកែលម្អសូចនាករផ្នែកសង្គមកិច្ច។ ដោយឡែក ក្នុងឆ្នាំ ២០១៣-២០១៤ កន្លងមកនេះ វិស័យកសិកម្ម ឧស្សាហកម្ម ទេសចរណ៍ សំណង់ ហេដ្ឋារចនាសម្ព័ន្ធ និងវិស័យផ្សេងៗទៀត សម្រេចបានសមិទ្ធផលដ៏ល្អ ដែលធ្វើឲ្យមូលដ្ឋាននៃកំណើនសេដ្ឋកិច្ចកាន់តែត្រូវបានពង្រឹងឡើង។ ម្យ៉ាងទៀតគួរបញ្ជាក់ថា ក្នុងរយៈពេល ២ ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់បំផុតដល់ការអភិវឌ្ឍធនធានមនុស្ស ជាពិសេសការបណ្តុះបណ្តាលយុវជនដែលជាអនាគតសសរទ្រូងដ៏រឹងមាំ និងជាកម្លាំងបន្តវេនរបស់ប្រទេសជាតិ ដើម្បីធានានូវមូលដ្ឋាន

The Cambodian history recorded the event of 2 December 1978 foundation of the United Front for National Salvation of Kampuchea (currently the United Front for Solidarity and Development of Cambodian Motherland) in the district of Snuol, Kratie province, in midst of darkest time when the whole people of Cambodia were under massacre of the regime of the Pol Pot's Democratic Kampuchea that implemented the most brutal genocide policy. The United Front for National Salvation of Kampuchea was the sole political and military organization that gathered compatriots from all corners of the country to stand up and eventually throw out the brutal regime on 7 January 1979.

The historic victory saved the Cambodian people's life in a timely manner while ushering in a new era for Cambodia. As of now, the whole people of Cambodia are pleased to greet the 36th anniversary of the foundation of the United Front for Salvation of Kampuchea and the 7-January victory in commemoration always of the sacrifices made by thousands of Cambodian and Vietnamese soldiers for the sake of rescuing and defending the revival of the Cambodian people. With December 2 comes victory on 7 January and with the victory comes everything we have today. This is a historic reality that no one can distort.

As thirty years have passed, the Cambodian motherland, liberated from the regime of genocide, has marched this far presently after going through indescribably numerous obstacles and hardships. Under the leadership of the Cambodian People's Party, wisely led by the three leaders, survivors from the regime of Pol Pot fought shoulders to shoulders to prevent the return of the brutal regime, while restoring from scratch and assuring gradual progress its socio-economic state. Cambodia, once a protracted war country, becomes the land of full peace and lively development, in which people have full rights and are mastering own destinies.

Cambodia has been assessed as the 15th country that achieves high economic growth in the world in the last 10 years, the 5th among the world's developing countries that has significant achievements towards meeting its Millennium Development Goals (MDG) and the 1st in Asia-Pacific region that makes substantial progress in improving social indicators. Particularly, in between 2013 and 2014, the country made positive achievements in areas of agriculture, industry, tourism, construction, infrastructure, etc., that further strengthens base for economic growth. It should be affirmed that in the last two years, the Royal Government of Cambodia has given highest priority for human resource development, especially training of youth, who are chief buttress and succeeding force of the country to guarantee foundation for the construction of Cambodia.

Cambodia has been making active steps on the path of democracy, rule of law and respect of human rights despites endless attempts of derailment by the opposition. National and sub-national elections, which are the critical elements of liberal democracy, have been implemented regularly according to law in a free, fair and just manner, while reflecting entirely will of the people. Having lost its honour in the past on the international arena, Cambodia has once again lifted up its prestige.

Currently, taking energetic and confident steps forward, the fifth legislative term Royal Government of Cambodia under the leadership

គ្រឹះនៃការកសាងអនាគតដ៏រុងរឿងរបស់កម្ពុជា។ កម្ពុជាបាន និងកំពុងធ្វើដំណើរយ៉ាងស្វាហាប់នៅលើគន្លងនៃលទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស ទោះបីជាមានការព្យាយាមឥតឈប់ឈរពីកម្លាំងប្រឆាំងដែលចង់ទាញប្រជាជនឲ្យធ្លាក់ចេញពីគន្លងនេះយ៉ាងណាក្ដី។ ជាក់ស្ដែងការបោះឆ្នោតទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលជាសមាសធាតុមួយយ៉ាងសំខាន់នៃលទ្ធិប្រជាធិបតេយ្យសេរី ត្រូវបានអនុវត្តយ៉ាងទៀងទាត់តាមច្បាប់ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែលឆ្លុះបញ្ចាំងទាំងស្រុងនូវឆន្ទៈរបស់ប្រជាជន។ ព្រមជាមួយនេះ កម្ពុជាដែលពីអតីតកាលត្រូវបាត់បង់កិត្តិយសលើឆាកអន្តរជាតិនោះ ឥឡូវបានជ្រោងកិត្យានុភាពរបស់ខ្លួនឲ្យខ្ពស់ត្រដែតឡើងវិញនៅលើឆាកអន្តរជាតិ។

បច្ចុប្បន្ន ក្នុងជំហានទៅមុខប្រកបដោយថាមពល និងភាពជឿជាក់ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី ៥ ក្រោមការដឹកនាំរបស់សម្ដេចតេជោ **ហ៊ុន សែន** កំពុងជំរុញអនុវត្តយ៉ាងសកម្ម និងប្រកបដោយផ្លែផ្កានូវកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ព្រមទាំងផែនការ និង គោលនយោបាយទាំងឡាយនៅក្នុងរបៀបវារៈរបស់ខ្លួន។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលប្ដេជ្ញាយ៉ាងមោះមុត បន្តអនុវត្តរាល់កំណែទម្រង់ដ៏ទូលំទូលាយនិងស៊ីជម្រៅលើគ្រប់វិស័យតាមទិសស្លោកឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល និងព្យាបាលជំងឺ ដើម្បីធានាអភិបាលកិច្ចល្អ សមធម៌ យុត្តិធម៌សង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព និងដើម្បីឆ្លើយតបទៅនឹងសំណូមពររបស់ប្រជាជនដែលកាន់តែកើនឡើងៗ។

បើទោះបី ជាយើងបានសម្រេចនូវសមិទ្ធផលដ៏ធំធេងលើគ្រប់វិស័យយ៉ាងនេះក្ដី ក៏ក្រុមប្រឆាំង និងមជ្ឈដ្ឋានអគតិមួយចំនួនទាំងក្នុង និងក្រៅប្រទេស នៅតែបន្តធ្វើជាសត្រូវនឹងជ័យជម្នះ ៧ មករា ហើយរកគ្រប់វិធីដើម្បីបំផ្លាញសមិទ្ធផលនៃជ័យជម្នះ ៧ មករា សំដៅធ្វើឲ្យសភាពការណ៍កម្ពុជាត្រូវផ្លាស់ប្ដូរតាមយុទ្ធសាស្ត្រដ៏ពិសពុល និងគ្រោះថ្នាក់របស់ពួកគេ ។ ពិតប្រាកដណាស់ថា ប្រសិនបើយុទ្ធសាស្ត្ររបស់ពួកគេបានសម្រេចនោះ ប្រវត្តិសាស្ត្រដែលពោរពេញដោយសោកនាដកម្ម និងការវិនាសអន្តរាយនឹងសាដានឡើងវិញ។ ដូច្នេះ តើយើងទាំងអស់គ្នាអាចទុកឲ្យប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតនោះសាដានឡើងវិញបានទេ? ក្នុងសភាពការណ៍នេះ ប្រជាជនកម្ពុជា ជាពិសេសស្រទាប់យុវជនដែលជាកម្លាំងបន្តវេនគប្បីមើលឃើញឲ្យអស់នូវឧបាយកលដ៏គ្រោះថ្នាក់នេះ យល់ច្បាស់អំពីប្រវត្តិសាស្ត្រ និងដំណើរវិវឌ្ឍន៍របស់ជាតិ ទើបមិនធ្លាក់ទៅក្នុងអន្លង់នៃការឃោសនាបោកប្រាសប្រជាភិថុតិរបស់មជ្ឈដ្ឋានទាំងនោះបាន។ យើងប្រកាន់ខ្ជាប់នូវឧត្ដមគតិស្នេហាជាតិ ស្មារតីធ្វើជាម្ចាស់មាតុភូមិ ម្ចាស់លើជោគវាសនាខ្លួនឯង ហើយបន្តថែរក្សាពូនជ្រំសមិទ្ធផលទាំងឡាយ ដែលប្រជាជាតិយើងខិតខំសម្រេចបានយ៉ាងលំបាកវេទនាបំផុតតាំងពីបាតដៃទទេ រហូតបង្កើតបានមនុញ្ញផលដ៏ថ្លៃថ្លាបំផុតយ៉ាងច្រើនអនេកដល់ថ្ងៃនេះ ។

៣៦ ឆ្នាំនៃការតស៊ូប្រឹងប្រែង និងជ័យជម្នះ កម្ពុជាបានឆ្លងកាត់ពីឆ្នាំសូន្យ ឈានមកដល់ដំណាក់កាលដែលមានការផ្លាស់ប្ដូរយ៉ាងស៊ីជម្រៅលើគ្រប់វិស័យប្រកបដោយមោទនភាព ដែលបានឆ្លុះបញ្ចាំងឲ្យឃើញច្បាស់នូវសារជាតិ និងសមត្ថភាពដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ព្រមទាំងស្មារតីធ្វើម្ចាស់របស់ប្រជាជនយើង។ ប៉ុន្តែបេសកកម្មរបស់គណ-បក្សប្រជាជនកម្ពុជានៅមិនទាន់បញ្ចប់នៅឡើយទេ ដើម្បីសម្រេចនូវសុបិនដ៏យូរលង់របស់ប្រជាជនយើង គឺកម្ពុជាមួយឯករាជ្យ សន្តិភាព សេរីភាព អព្យាក្រឹត ប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គម ដែលនឹងធ្វើឲ្យប្រជាជនបានរស់នៅយ៉ាងសុខដុមរមនា សុភមង្គលជារៀងរហូត។ អាស្រ័យហេតុនេះ គណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក មន្ត្រីដឹកនាំគណបក្សគ្រប់រូប ត្រូវយកចិត្តទុកដាក់ លើកកម្ពស់សមត្ថភាពបំពេញការងាររបស់ខ្លួនជានិច្ច ជិតស្និទ្ធជាមួយប្រជាជន ខិតខំធ្វើតែអំពើល្អ មិនប្រព្រឹត្តអំពើខុសឆ្គងដែលធ្វើឲ្យប៉ះ-ពាល់ដល់សិទ្ធិ និងផលប្រយោជន៍ប្រជាជនជាដាច់ខាត។ ធ្វើយ៉ាងនេះបាន ទើបគណបក្សអាចស្ថិតស្ថេរជានិច្ចក្នុងដួងចិត្តរបស់ប្រជាជន ហើយសមិទ្ធផលនៃជ័យជម្នះ ៧ មករា នឹងត្រូវបានការពារយ៉ាងគត់មត់។

សូមស្មារតី ២ ធ្នូ និងស្មារតី ៧ មករាចារជាប់ជានិច្ចក្នុងក្រអៅបេះដូងរបស់ប្រជាជនកម្ពុជា ទាំងអ្នកដែលធ្លាប់រស់ក្នុងរបបប្រល័យពូជសាសន៍ ទាំងអ្នកស្រករក្រោយ ដែលមិនបានឆ្លងកាត់របបប្រល័យពូជសាសន៍ ហើយប្រែក្លាយជាកម្លាំងដ៏មហិមា ដើម្បីបម្រើបុព្វហេតុកសាង និងការពារមាតុភូមិយើង៕

**ទស្សនាវដ្ដីប្រជាជន**

of Samdech Techo Hun Sen is actively and fruitfully implementing its political platform, rectangular strategy phase III as well as plans and policies inclusive in its agenda. In this context, the Royal Government is firmly determined to continue implementing wide ranging and deepening reform in all fields according to slogan "reflect oneself in the mirror, take a bath, wash off dirt and take treatment" aimed at guaranteeing good governance, equity, social justice and sustainable development, while responding to growing people's demand.

Although achievements have been made in all fields, opposition groups and ill-willed circles inside and outside the country continue to nurture enmity to the 7-January victory, while seeking every means to destroy the victory's achievements aimed at reversing the Cambodian situation in accordance with their perfidious and dangerous strategy. It is true, should they realize their strategies, the country's history of tragedy and holocaust would repeat itself. Would we leave this history of darkness to resurge?

In this situation, the people of Cambodia, especially the youth, who will be the country's succeeding force, should see the danger of every trick, while understanding well history and evolvement of our nation so as to refrain oneself from being misled by propaganda full of deception and demagogy. We adhere firmly to patriotic idea and spirit as master of our motherland and destiny, while continuing to nurture national achievements that we have scored from scratch until present.

After 36 years of efforts and victory, Cambodia has gone from nil to a stage where there are fundamental reforms in all fields that reflect clearly the nature and leadership capability of the Cambodian People's Party and our people's ownership spirit. CPP, however, has yet to realize the sacred mission in achieving long awaiting dream of our people to make Cambodia a country of independence, peace, freedom, neutrality, democracy and social progress, where people can live in harmony and happiness forever.

It is in this regard, the party committees of every level and officials in leadership position must raise high their capacity in fulfilling their tasks and works, while staying always close to the people, making good deeds and refraining absolutely from wrongdoings that may infringe upon rights and interests of the people. Only by doing that were the party to always exist in the heart of the people and the 7-January victory could be protected. May the spirit of December 2 carves always in the hearts of every Cambodians – those who survived the genocide and those who are born after the regime of the genocide – to transform into a great force ever for the course of construction and defence of our motherland./.

*THE PRACHEACHUN MAGAZINE*

# គណបក្សប្រឆាំងកំពុងតែការពារនិទ្ទណ្ឌភាព

កន្លងមកនេះ តុលាការរាជធានីភ្នំពេញបានចាត់ការយ៉ាងត្រឹមត្រូវតាមច្បាប់ និងនីតិវិធី ចំពោះជនប្រព្រឹត្តបទល្មើសមួយចំនួនដែលក្នុងនោះ ក៏មានមន្ត្រីជាន់ខ្ពស់មួយរូបរបស់គណបក្សប្រឆាំងផងដែរ ដែលបានពាក់ព័ន្ធនឹងការដឹកនាំកុប្បកម្មដោយហិង្សាកាលពីថ្ងៃទី១៥ខែកក្កដាឆ្នាំ២០១៤នៅស្ពាននាគជិតទីលានប្រជាធិបតេយ្យ។ នេះគឺជាការចាត់វិធានការតាមផ្លូវច្បាប់លើពាក្យបណ្តឹងរបស់ជនរងគ្រោះ និងបទល្មើសជាក់ស្តែងដែលជនទាំងនោះបានប្រព្រឹត្តបំពានច្បាប់ ធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់សន្តិសុខសណ្តាប់ធ្នាប់សង្គម និងដំណើរប្រព្រឹត្តទៅជាប្រក្រតីនៃជីវភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាជន។ ជនប្រព្រឹត្តល្មើសទាំងនោះមួយចំនួនត្រូវបានតុលាការបើកសវនាការកាត់ទោសឲ្យជាប់ពន្ធនាគាររួចហើយ និងមួយចំនួនទៀតកំពុងត្រូវតុលាការសម្រេចឃុំខ្លួន រង់ចាំសវនាការនៅពេលខាងមុខ ។

ប៉ុន្តែគណបក្សប្រឆាំង រួមទាំងសង្គមស៊ីវិល និងមជ្ឈដ្ឋានអគតិមួយចំនួនដែលមាននិន្នាការលម្អៀងបានបញ្ចេញប្រតិកម្មទាំងទទឹងទិស ចោទប្រកាន់ដោយគ្មានមូលដ្ឋានត្រឹមត្រូវមកលើគណបក្សប្រជាជនកម្ពុជាថា បានរំលោភទៅលើស្មារតីនៃកិច្ចព្រមព្រៀងនយោបាយថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ទាក់ទងទៅនឹងករណីខាងលើនេះ។ ពួកគេបានទាមទារឲ្យមានការដោះលែងជនទាំងនោះជាបន្ទាន់ ដែលជាការរំលោភបំពានលើការងាររបស់ស្ថាប័នតុលាការ ដោយនិយាយឃោសនាបំផ្លើសថា នេះគឺជាការគៀបសង្កត់ខាងនយោបាយ ជាការគំរាមកំហែងបំបិទសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ ធាតុពិតគេបានធ្វើជាមិនយល់ថា ជនទាំងឡាយដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួនទាំងនោះ គឺផ្អែកលើភ័ស្តុតាងគ្រប់គ្រាន់ និងបទល្មើសជាក់ស្តែង ដែលនាំទៅដល់ការវិនិច្ឆ័យទោសស្របតាមច្បាប់ជាធរមាន ដោយមិនអាចលើកលែងបានឡើយ ។ រាជរដ្ឋាភិបាលកម្ពុជា កំពុងតែជំរុញខ្លាំងការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ សំដៅលុបបំបាត់ឲ្យបាននូវនិទ្ទណ្ឌភាពនៅក្នុងសង្គមពង្រឹងយុត្តិធម៌សង្គមនិងការគោរពអនុវត្តច្បាប់។រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា ពលរដ្ឋកម្ពុជាគ្រប់រូបត្រូវបានការពារដោយស្មើភាពគ្នានៅចំពោះមុខច្បាប់ គ្មានជនណាអាចនៅពីលើច្បាប់បានឡើយ។ វាជារឿងគួរឲ្យចម្លែក ព្រោះថា ទាំងគណបក្សប្រឆាំង និងសង្គមស៊ីវិលមួយចំនួននោះ ក៏ធ្លាប់បានលើកឡើងទាមទារឲ្យរាជរដ្ឋាភិបាលកម្ពុជាត្រូវគោរពច្បាប់ ត្រូវលុបបំបាត់និទ្ទណ្ឌភាព និងទាមទារឲ្យតុលាការត្រូវតែឯករាជ្យដែរ។ ប៉ុន្តែផ្ទុយទៅវិញ នៅពេលដែលសកម្មជនរបស់ខ្លួន និងជនប្រពឹត្តល្មើសដទៃទៀតត្រូវបានចាប់ខ្លួន និងយកទៅផ្តន្ទាទោស គេបែរជាធ្វើការចោទប្រកាន់មកលើរាជរដ្ឋាភិបាលកម្ពុជាដែលបានអនុវត្តត្រឹមត្រូវតាមច្បាប់ ហើយថែមទាំងឲ្យដំបូន្មានដល់ស្ថាប័នតុលាការទាមទារឲ្យតុលាការធ្វើខុសទៅតាមបំណងខ្លួនទៅវិញ ។

ការចាប់ខ្លួន ការឃុំខ្លួន ការជំនុំជម្រះទោសជនល្មើស គឺជាឆន្ទានុសិទ្ធិរបស់តុលាការ ព្រោះតុលាការជាស្ថាប័នឯករាជ្យ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញមិនអាចមានអ្នកណាបង្គាប់បញ្ជាបានឡើយ។ ឯការចោទប្រកាន់ថា គណបក្សប្រជាជនកម្ពុជារំលោភលើកិច្ចព្រមព្រៀងនយោបាយថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ គឺជារឿងមិនត្រឹមត្រូវទាំងស្រុង។ នោះគឺជាការអុចអាល ញុះញង់ បំភ្លៃការពិត ដែលនឹងធ្វើឲ្យសង្គមជាតិជួបនឹងរឿងប្រេះស្រាំបន្តប៉ុណ្ណោះ ។ កិច្ចព្រមព្រៀងនេះ ត្រូវបានគណបក្សប្រជាជនកម្ពុជាអនុវត្តយ៉ាងពេញលេញ ប្រកបដោយការទទួលខុសត្រូវ គឺគ្មានការឡុកឡំអ្វីជាមួយនឹងការប្រព្រឹត្តល្មើសរបស់ជនទាំងនោះឡើយ ។ ម្យ៉ាងទៀតគប្បីយល់ថា កិច្ចព្រមព្រៀងនយោបាយនោះមិនមែនជាការធានាអភ័យឯកសិទ្ធិឲ្យបុគ្គលណាស្ថិតនៅក្រៅសំណាញ់ច្បាប់ឡើយ ។ ពាក់ព័ន្ធនឹងករណីនេះសម្តេចតេជោ**ហ៊ុនសែន**បានមានប្រសាសន៍ថា កិច្ចព្រមព្រៀងរវាងគណបក្សនយោបាយទាំងពីរនៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ កន្លងទៅ មិនមែនជាកិច្ចព្រមព្រៀងបញ្ចប់នូវដំណើរការរបស់តុលាការ ទាក់ទិនរឿងក្តីព្រហ្មទណ្ឌនោះទេ ហើយនៅក្នុងពិភពលោកនេះក៏គ្មានកិច្ចព្រមព្រៀងនយោបាយណាគ្របដណ្តប់ទៅលើដំណើរការរបស់តុលាការក្នុងរឿងព្រហ្មទណ្ឌដែរ ។ សម្តេចក៏បានក្រើនរំឭកដល់អ្នកនយោបាយ នៃគណបក្សប្រឆាំងគប្បីមានការប្រយ័ត្នប្រយែងក្នុងការនិយាយស្តីរបស់ខ្លួន ។

ពេលនេះជនល្មើសត្រូវបានវិនិច្ឆ័យទោសទៅតាមច្បាប់ហើយដែលបង្ហាញថានិទ្ទណ្ឌភាពមិនត្រូវបានការពារឡើយ។ ប្រជាជនបានសាទរចំពោះចំណាត់ការរបស់តុលាការ និងស្ថាប័នមានសមត្ថកិច្ចផ្សេងៗទៀតដែលបានអនុវត្តត្រឹមត្រូវតាមតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួនដូចបានចែងក្នុងច្បាប់ ។ ប្រជាជនសង្ឃឹមថានិទ្ទណ្ឌភាពនឹងត្រូវតស៊ូលុបបំបាត់ឲ្យអស់ទាំងស្រុងពីសង្គមកម្ពុជា ហើយប្រជាធិបតេយ្យ នីតិរដ្ឋ និងយុត្តិធម៌សង្គមនឹងត្រូវបានពង្រឹងឲ្យកាន់តែរឹងមាំឡើងឥតឈប់ឈរ ៕

# ព្រះរាជពិធីបុណ្យអុំទូក អកអំបុក បណ្ដែតប្រទីប និងសំពះព្រះខែ ប្រព្រឹត្តទៅយ៉ាងអធិកអធម និងជោគជ័យ





*ព្រះករុណា **ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តម សីហមុនី***
*យាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប សំពះព្រះខែ និងអកអំបុក*

ក្រោយពីការខកខានអស់រយៈពេល ៣ ឆ្នាំព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីបសំពះព្រះខែនិងអកអំបុកត្រូវបានប្រារព្ធធ្វើឡើងយ៉ាងអធិកអធមនៅរាជធានីភ្នំពេញចាប់ពីថ្ងៃទី០៥-០៦-០៧ខែវិច្ឆិកាក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណា **ព្រះបាទសម្ដេច ព្រះបរមនាថ នរោត្តមសីហមុនី**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។អញ្ជើញចូលរួមក្នុងឱកាសនោះដែរ មានសម្ដេចចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងលោកជំទាវ សម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ឯកឧត្ដម**សាយ ឈុំ** អនុប្រធានទី ១ ព្រឹទ្ធសភា។

នៅក្នុងព្រះរាជពិធីបុណ្យអុំទូកឆ្នាំនេះ មានទូកចូលរួមសរុប ២៤៨ ទូក ក្នុងនោះមានទូកអុំបុរស ១៦៤ ទូក ទូកអុំនារី ១ ទូក ទូកចែវបុរស ២៨ ទូក ទូកចែវនារី ២ ទូក ទូកខ្ទាតអន្តរជាតិបុរស ៥២ ទូក ទូកខ្ទាតអន្តរជាតិនារី ១ ទូក ។ ក្នុងចំណុះទូកទាំងនេះមានបែងចែកទូកគូពិសេសចំនួន ៨០ ទូកផងដែរ។ ក្នុងចំណោមទូកទាំងអស់នោះ ត្រូវប្រើកម្លាំងកីឡាករអុំផ្នែកបុរសចំនួន ១៤២៦២ នាក់និងផ្នែកអុំនារីចំនួន ១៥៦ នាក់។ចំណែកកម្លាំងកីឡាករបម្រុងមានចំនួន ២ ៩៥៨ នាក់ ផ្នែកនារី ៤៥ នាក់។ ចំពោះខេត្តក្រុង និងស្ថាប័នដែលបានបញ្ជូនទូកឲ្យចូលរួមនៅក្នុងពិធីបុណ្យអុំទូកឆ្នាំនេះ គឺខេត្តកណ្ដាលមាន ៦១ ទូក រាជធានីភ្នំពេញមាន ៣៦ ទូក ខេត្តព្រៃវែងមាន ២៦ ទូក ខេត្តកំពង់ចាមមាន ២៤ ទូក ខេត្តកំពង់ឆ្នាំងមាន ២៣ ទូកខេត្តក្រចេះ ១៧ ទូក ខេត្តកំពង់ធំមាន ១៦ ទូក ខេត្តត្បូងឃ្មុំមាន ១០ ទូក ខេត្តតាកែវមាន ៧ ទូក ខេត្តពោធិសាត់ និងខេត្តកំពង់ស្ពឺមាន ៣ ទូកដូចគ្នា ខេត្តបាត់ដំបង ខេត្តព្រះវិហារ និងខេត្តស្វាយរៀងមាន ២ ទូក ដូចគ្នា ខេត្តបន្ទាយមានជ័យនិងខេត្តមណ្ឌលគីរីមាន ១ ទូកដូចគ្នា កងរាជអាវុធហត្ថលើផ្ទៃប្រទេសមាន ៣ ទូក ទីស្ដីការគណៈរដ្ឋមន្ត្រីមាន ២ ទូក ក្រសួងការពារជាតិមាន ២ ទូក បញ្ជាការដ្ឋានកងទ័ពជើងទឹកមាន ១ ទូក ក្រសួងមហាផ្ទៃមាន ១ ទូក។ ទូកចូលរួមប្រណាំងក្នុងឆ្នាំ ២០១៤ នេះមានចំនួនតិចជាងឆ្នាំ ២០១០ ចំនួន ១៧៩ ទូក។ ដោយសារឆ្នាំនេះចំនួនទូកចូលរួមតិចដូច្នេះត្រូវតែប្រណាំងចំនួនពីរជើងក្នុងមួយថ្ងៃដោយប្ដូរខ្សែទឹកម្ដងម្នាក់ ។ចម្ងាយដែលត្រូវប្រណាំងមានប្រវែង ១៧០០ ម៉ែត្រ ដូចបណ្ដាឆ្នាំកន្លងទៅដែរ ដោយចែកចេញជា ៣ ដំណាក់។ដំណាក់ទី ១ ពីកន្លែងចេញដំណើរមកដល់





*មហាជនចូលរួមយ៉ាងច្រើនកុះករក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប សំពះព្រះខែ និងអកអំបុក*



*ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក*

កងព័ន្ធទី ១ មានចម្ងាយ ១០០០ ម៉ែត្រ ដំណាក់ទី ២ ពីកងព័ន្ធទី ១ ដល់កងព័ន្ធទី ២ មានចម្ងាយ ៥០០ ម៉ែត្រ និងដំណាក់ទី ៣ ពីកងព័ន្ធទី ២ ដល់កន្លែងផ្តាច់ព្រ័ត្រមានចម្ងាយ ២០០ ម៉ែត្រ ។ ទីកន្លែងចេញដំណើរស្ថិតនៅត្រង់ស្ថានីយរដ្ឋករទឹកឯកន្លែងផ្តាច់ព្រ័ត្រនៅពីមុខវេទិការបុណ្យអុំទូក។ចំណែកប្រទីបដែលចូលរួមក្នុងឆ្នាំនេះមាន ១០ គឺប្រទីបរបស់ព្រះបរមរាជវាំង ប្រទីបព្រឹទ្ធសភា ប្រទីបរដ្ឋសភា ប្រទីបរាជរដ្ឋាភិបាល ប្រទីបក្រសួងយុត្តិធម៌ ប្រទីបក្រសួងការពារជាតិ ប្រទីបក្រសួងមហាផ្ទៃ ប្រទីបក្រសួងពាណិជ្ជកម្ម ប្រទីបក្រសួងទេសចរណ៍ និងប្រទីបរបស់រាជធានីភ្នំពេញ។

ក្នុងថ្ងៃបញ្ចប់ព្រះរាជពិធីបុណ្យអុំទូក ក៏មានការប្រកាស់ផ្តល់ចំណាត់ថ្នាក់ដល់ទូកដែលទទួលបានជ័យជម្នះ។ ចំណាត់ថ្នាក់ផ្នែកសោភ័ណភាពលេខ ១ បានទៅលើទូកអុំបុរសឈ្មោះ នរិន្ទរង្សី ស្រីសពីជិតរបស់ខេត្តបាត់ដំបង ពាក់លេខ ០៦៣ ប្រភេទទូកអុំនារីចំណាត់ថ្នាក់លេខ ១ ខាងសោភ័ណភាពបានទៅទូកឈ្មោះ សារាវ័ន្តតេជោសែនជ័យបារមីដូនពេញពាក់លេខ ០០១ ប្រភេទទូកចែវបុរសចំណាត់ថ្នាក់លេខ ១ ខាងសោភ័ណភាពបានទៅលើទូកឈ្មោះព្រះទីនាំងសារាយអណ្តែតចង្ហាន់ហុយ របស់ខេត្តកំពង់ឆ្នាំង និងទូកចែវនារីឈ្មោះប្រពៃស្រពរបស់ខេត្តកំពង់ឆ្នាំង។ រីឯចំណាត់ថ្នាក់នៃការប្រណាំងទូក គឺផែនចំណាត់ថ្នាក់លេខ ១ សំរាប់ទូកខ្នាត អន្តរជាតិបុរសមានចំនួន ១១ ទូក លេខ ២ មាន ១៧ ទូក លេខ៣មាន១៥ទូក និងលេខ ៤ មាន ៥ ទូក។ ប្រភេទទូកអុំបុរសផ្នែកលេខ ១ មាន ១១៩ ទូក លេខ ២ មាន ៤៨ ទូក លេខ ៣ មាន ៣២ ទូក និងលេខ ៤ មាន ១៦ ទូក ប្រភេទទូកអុំនារី ផែនលេខ ១ មាន ១ ទូក។ ទូកចែវបុរសផែន លេខ ១ មាន ៦ ទូក ផែនលេខ ២ មាន ៩ ទូក ផែនលេខ ៣ មាន ៨ ទូក និងផែនលេខ ៤ មាន ១ ទូក។ ទូកពិសេសដែលលឿនជាងគេក្នុងរយៈពេល ៣ ថ្ងៃនេះ លេខ ១ ទូកឈ្មោះស្រីស្រស់គឿនជ័យ បារមី តេជះរបស់ខេត្តកំពង់ចាម ដែលក្នុងរយៈពេល ៣ ថ្ងៃនេះប្រើថេរវេលា ២៧ នាទី ១០ វិនាទី ១៧ ទូកលេខ ២ ឈ្មោះច័ន្ទសោមសែនមង្គល របស់ខេត្តតាកែវ ថេរវេលា ២៧ នាទី ១៤ វិនាទី ៣៥ និងលេខ ៣ ទូកឈ្មោះគីរីវង្សសុខសែនជ័យ របស់ខេត្តតាកែវ ប្រើថេរវេលា ២៧ នាទី ២៤ វិនាទី ៤៥។ បន្ទាប់ពីបញ្ចប់ការប្រណាំងទូក ក៏មានពិធីចាប់កូនក្លែង និងកាត់ព្រ័ត្រ ដែលជាការបិទកម្មវិធីប្រណាំងទូក។

នៅរាត្រីថ្ងៃទី ១៥ កើត ខែកត្តិក ទោស័ក ពុទ្ធសករាជ ២៥៥៨ ត្រូវនឹងថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ២០១៤ ដែលជាថ្ងៃទី ២ នៃព្រះរាជពិធីបុណ្យអុំទូក នៅក្នុងព្រះបរមរាជវាំងមានប្រារព្ធព្រះរាជពិធីសម្រក់ទៀនជ័យ ដើម្បីបួងសួងព្យាករណ៍អំពីឧទកៈធារា ឬដំណើរទឹកភ្លៀង ក្រោមព្រះរាជាធិបតីភាពព្រះករុណា **ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ បន្ទាប់ពីព្រះមហាក្សត្រយាងថ្វាយគ្រឿងសក្ការៈបូជាដល់ព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធមួយម៉ឺនលោកធាតុ ក្នុងព្រះរាជពិធីនោះរួចមក ការបួងសួងចង់ដឹងអំពីដំណើរទឹកភ្លៀង ដែលបង្អុរធ្លាក់លើប្រឹថពីនៃព្រះរាជាណាចក្រកម្ពុជាក្នុង ២៥ ខេត្ត រាជធានីនាឆ្នាំនេះក៏បានចាប់ផ្តើម។ ក្នុងព្រះរាជពិធីសម្រក់ទៀនផ្សងទឹកភ្លៀងនារាត្រីនេះបង្ហាញថា ខេត្តរាជធានីទាំង ២៥ ភាគច្រើននៅដើមឆ្នាំ និងកណ្តាលឆ្នាំ មានភ្លៀងធ្លាក់តិច និងមធ្យម ឯចុងឆ្នាំមានភ្លៀងធ្លាក់ច្រើន។

មហាជនប្រមាណជាង ១ លាននាក់បានចូលរួមកម្សាន្តសប្បាយនៅតាមទីកន្លែងជាច្រើន ដោយមានទាំងការសម្តែងសិល្បៈ ការប្រគុំតន្ត្រីដែលរៀបចំដោយបណ្តាស្ថានីយទូរទស្សន៍ជាច្រើនផងដែរ ។ ព្រះរាជពិធីបុណ្យអុំទូកឆ្នាំនេះបានប្រព្រឹត្តទៅដោយសុវត្ថិភាព ពុំមានបញ្ហាអ្វីកើតឡើងគួរឲ្យកត់សម្គាល់នោះទេ ។ កម្លាំងអាជ្ញាធរចម្រុះជាង ៥ ពាន់នាក់ត្រូវបានដាក់ពង្រាយតាមគោលដៅសំខាន់ៗនៅក្នុងព្រះរាជពិធីបុណ្យនេះ ។ និយាយជារួមកម្លាំងមានសមត្ថកិច្ចបានរក្សាសន្តិសុខសុវត្ថិភាពសណ្តាប់ធ្នាប់ជូនប្រជាជនដែលអញ្ជើញចូលមកចូលរួមក្នុងព្រះរាជពិធីបុណ្យអុំទូក អកអំបុក បណ្តែតប្រទីប និងសំពះព្រះខែ បានកម្សាន្តដោយរីករាយទាំងអស់គ្នា៕





*ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក*

# ពិធីចម្រើនព្រះជន្មគម្រប់ ៨២ ឈានចូល ៨៣ ឆ្នាំ របស់សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម




*សម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ក្នុងឱកាសដ៏នក្ខត្តប្ញក្សនៃពិធីបុណ្យចម្រើនជន្មាយុ*

នៅក្នុងឱកាសដ៏នក្ខត្តប្ញក្សនៃពិធីបុណ្យចម្រើនជន្មាយុ សម្ដេចអគ្គ-មហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា និងជាប្រធានគណបក្សប្រជាជនកម្ពុជា គម្រប់ ៨២ ឈានចូល ៨៣ ឆ្នាំដែលបានប្រព្រឹទ្ធទៅកាលពីថ្ងៃទី ១៥ និង១៦ វិច្ឆិកា ឆ្នាំ ២០១៤ នេះ សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងជាប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អនុប្រធានគណបក្សប្រជាជនកម្ពុជា ថ្នាក់ដឹកនាំគណបក្ស រាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត បានសម្ដែងនូវការគោរពយ៉ាងខ្ពង់ខ្ពស់ និងប្រសិទ្ធពរជ័យ សិរីមង្គលមហាប្រសើរជូនសម្ដេចប្រធាន ក្នុងស្មារតីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅ ។

គណៈកម្មាធិការគណបក្សនៅគ្រប់ថ្នាក់ គ្រប់ផ្នែក សមាជិក សមាជិកាគណបក្សនៅគ្រប់ អង្គការមូលដ្ឋាន និងមហាជន បានសម្ដែងនូវការគោរពស្រឡាញ់ និងការដឹងគុណដ៏ជ្រាលជ្រៅបំផុតដល់សម្ដេចប្រធានដែលបានបូជាអស់កម្លាំងកាយ កម្លាំងចិត្ត បញ្ញាស្មារតី ដើម្បីមាតុភូមិ និងប្រជា-ជនកម្ពុជា ក្នុងបុព្វហេតុសង្គ្រោះជាតិពីរបបប្រល័យពូជសាសន៍ ស្ដារកសាង និងអភិវឌ្ឍមាតុភូមិ និងលើកស្ទួយជីវភាពប្រជាជនឲ្យរីកចម្រើនឥតឈប់ឈរ ហើយកំពុងឈានទៅមុខតាមមាគ៌ាឯករាជ្យ សន្តិភាព សេរីភាព អព្យាក្រឹត ប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គម ។

នៅក្នុងឱកាសនៃពិធីបុណ្យនេះដែរ ពេលព្រឹកថ្ងៃទី១៦ ខែវិច្ឆិកា នៅគេហដ្ឋានរបស់សម្ដេចមានពិធីរាប់បាត្រប្រគេនព្រះសង្ឃដែលនិមន្តមកពីវត្តចំនួន ៨៤ វត្ត ក្នុងបរិយាកាសប្រកបដោយទឹកចិត្តជ្រះថ្លា និងកក់ក្ដៅក្រៃលែង។ នៅក្នុងពិធីនោះសម្ដេចប្រធានព្រឹទ្ធសភាបានរាប់បាត្រ និងប្រគេនទេយ្យទានព្រះរាជាគណៈ ១៥ អង្គ ព្រះសង្ឃ ៧៥ អង្គ និងបានជូនលោកតាលោកយាយ ៧០០ នាក់ក្នុងម្នាក់ទទួលបានភួយ១សម្លៀកបំពាក់១កំប្លេ និងថវិកា ៥ ម៉ឺនរៀល ៕





សូមគោរពឯកឧត្ដម លោកជំទាវ និងប្រិយមិត្តអ្នកអានជាទីគោរព
សូមចូលមក Facebook Page : Pracheachun Magazine-ទស្សនាវដ្ដីប្រជាជន
ហើយចុច Like និង Share ដើម្បីទទួលបានព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ព្រមទាំងផ្ដល់ទស្សនៈ ឬ មតិផ្សេងៗ

# សម្តេចតេជោ ហ៊ុន សែន ក្នុងដំណើរបំពេញទស្សនកិច្ចនៅប្រទេសចិន

## ✵ ប្រធានាធិបតីចិនចាត់ទុកកម្ពុជា និងចិន គឺជាប្រទេសដែលមានវាសនាតែមួយ



*សម្តេចតេជោ **ហ៊ុន សែន** ជួបសម្តែងការគួរសមនិងពិភាក្សាការងារ ជាមួយឯកឧត្តម **ស៊ី ជីនភីង** ប្រធានាធិបតីចិន នៅវិមានប្រជាជន*

តបតាមសេចក្តីអញ្ជើញរបស់ឯកឧត្តម **ស៊ី ជីនភីង** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី ៨-៩ ខែវិច្ឆិកា ឆ្នាំ២០១៤ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទៅកាន់ទីក្រុងប៉េកាំង ដើម្បីចូលរួមក្នុងវេទិកាកិច្ចសន្ទនាដើម្បីពង្រឹងភាពជាដៃគូនៃការតភ្ជាប់ និងកិច្ចប្រជុំកំពូលនាយកប្រតិបត្តិនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិច ឆ្នាំ ២០១៤ ( APEC CEO Summit ) ។

នៅថ្ងៃទី ៧ ខែវិច្ឆិកា ក្នុងឱកាសស្នាក់នៅទីក្រុងប៉េកាំង សម្តេចតេជោ **ហ៊ុនសែន** បានអញ្ជើញជួបសម្តែងការគួរសម នឹងពិភាក្សាការងារជាមួយឯកឧត្តម **ស៊ី ជីនភីង** ប្រធានាធិបតីចិននៅវិមានប្រជាជនចិន។ ឯកឧត្តម **ស៊ី ជីនភីង** មានប្រសាសន៍ថា ប្រទេសទាំងពីរចិន-កម្ពុជា គឺជាប្រទេសដែលមានវាសនាតែមួយ មានផលប្រយោជន៍ដូចគ្នានិងមិត្តភាពដ៏ស្មោះជាមួយគ្នាផងដែរ។ដោយសារតែប្រទេសទាំងពីរជាប្រទេសមានទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ចិនបានចាត់ទុកថា កម្ពុជាគឺជាប្រទេសដ៏មានសារៈសំខាន់ និងចាត់ទុកសម្តេចតេជោគឺជាមិត្ត និងជាបងប្អូនរបស់ប្រទេសចិន និងសូមទទួលស្វាគមន៍ជានិច្ចចំពោះវត្តមាននៃដំណើរទស្សនកិច្ចរបស់សម្តេចតេជោមកកាន់ប្រទេសចិន។

ឯកឧត្តមប្រធានាធិបតីមានប្រសាសន៍ថា ចាប់តាំងពីឆ្នាំ២០០៩ នៅពេលដែលឯកឧត្តមបំពេញទស្សនកិច្ចនៅកម្ពុជា ឯកឧត្តមបានឃើញដោយផ្ទាល់ចំពោះសម្តេចតេជោ និងរាជរដ្ឋាភិបាលកម្ពុជា ដែលតែងតែប្រកាន់ខ្ជាប់នូវនយោបាយចិនតែមួយ។ បើទោះបីពេលនេះកម្ពុជារងសម្ពាធពីខាងក្រៅមួយចំនួនក៏ពិតមែន ប៉ុន្តែកម្ពុជានៅតែប្រកាន់យកនយោបាយចិនតែមួយ ។ តាមរយៈនេះយើងអាចបញ្ជាក់បានថា ចិន និងកម្ពុជានៅតែបន្តជួយគ្នាទៅវិញទៅមក ទាំងក្នុងទំនាក់ទំនងទ្វេភាគី តំបន់ និងអន្តរជាតិដែលមានការយកចិត្តទុកដាក់ដូចគ្នា។ ប្រទេសចិននឹងបន្តផ្តល់ជំនួយ និងបន្តការគាំទ្រគ្រប់បែបយ៉ាងដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិរបស់ប្រទេសកម្ពុជាឱ្យកាន់តែរីកចម្រើនទ្វេឡើងថែមទៀត និងបានសម្តែងនូវការវាយតម្លៃខ្ពស់ចំពោះ



សភាពការណ៍នយោបាយនៅកម្ពុជាដែលបាន និងកំពុងវិវត្តន៍រីកចម្រើនទៅមុខ ពិសេសគណបក្សនយោបាយទាំងពីរបានចូលសភា ក្នុងការបន្តនិរន្តរភាពទៅមុខ ។

ឯកឧត្តមប្រធានាធិបតីមានប្រសាសន៍ថា ការដែលប្រទេសចិនអញ្ជើញប្រទេសមិនមែនជាសមាជិកនៃកិច្ចសន្ទនាដើម្បីពង្រឹងភាពជាដៃគូនៃការតភ្ជាប់ និងកិច្ចប្រជុំកំពូលនាយកប្រតិបត្តិនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី ប៉ាស៊ីហ្វិក ( APEC ) មកចូលរួមក្នុងកិច្ចប្រជុំកំពូលនៅពេលនេះ គឺធ្វើឡើងក្នុងទិសដៅដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងប្រទេសជាមិត្ត និងប្រទេសជាសមាជិករបស់ APEC ។ ឯកឧត្តមមានប្រសាសន៍សង្កត់ធ្ងន់ថា ប្រទេសចិនសូមគាំទ្រប្រទេសកម្ពុជាក្នុងការចូលជាសមាជិករបស់ APEC តាមរយៈសុំឱ្យប្រទេសកម្ពុជាធ្វើការចរចាជាមួយបណ្តាប្រទេស APEC មួយចំនួនទៀត ។

ក្នុងជំនួបពិភាក្សាគ្នានោះដែរ ឯកឧត្តមប្រធានាធិបតីចិន និងសម្តេចតេជោ **ហ៊ុន សែន** បានវាយតម្លៃខ្ពស់ពីការបង្កើតវិថីសូត្រសមុទ្រ ដែលបានស្នើឡើងដោយប្រទេសចិន និងបង្កើនសមាជិកភាពនៃវេទិកាដ៏មានសារៈសំខាន់នោះ ដែលមានប្រទេសចូលរួមរហូតដល់ ៦៥ ប្រទេស។ ឯកឧត្តមប្រធានាធិបតីចិនក៏បានគូសបញ្ជាក់ពីការជួយដល់យុវជនកម្ពុជាចំនួន ១០០នាក់ មកទស្សនកិច្ចសិក្សានៅប្រទេសចិនក្នុងឆ្នាំ ២០១៥ ផងដែរ ។

ឯកឧត្តម **ស៊ី ជិនពីង** មានប្រសាសន៍ថា ក្នុងរយៈពេលកន្លះឆ្នាំមកនេះ ឯកឧត្តមបានជួបពិភាក្សាដោយផ្ទាល់ជាមួយសម្តេចតេជោនាយករដ្ឋមន្ត្រីចំនួនពីរលើករួចមកហើយ ពោលគឺលើកទី ១ ធ្វើឡើងកាលពីខែឧសភា នៅទីក្រុងសៀងហៃ ក្នុងឱកាសដែលសម្តេចអញ្ជើញចូលរួមកិច្ចប្រជុំកំពូលនៃសន្និសីទស្តីពីអន្តរសកម្មភាព និងវិធានការកសាងទំនុកចិត្តនៅអាស៊ី ។

ឯកឧត្តមប្រធានាធិបតីមានប្រសាសន៍បន្តថា ឯកឧត្តមមានការចងចាំជានិច្ចចំពោះការដែលឯកឧត្តមបានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ របស់ប្រទេសចិនមកបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ ២០០៩ ដោយបានការទទួលយ៉ាងកក់ក្តៅបំផុតពីសំណាក់ព្រះករុណាព្រះមហាក្សត្រ សម្តេចតេជោ នាយករដ្ឋមន្ត្រីរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ។

សម្តេចតេជោ **ហ៊ុន សែន** មានប្រសាសន៍ថា កិច្ចប្រជុំកំពូលនៅទីក្រុងសៀងហៃកន្លងទៅ គឺជាកិច្ចប្រជុំមួយដ៏មានសារៈសំខាន់ និងមានអត្ថន័យធំធេងសម្រាប់

នយោបាយរបស់ប្រទេសកម្ពុជា ជាពិសេសគឺជំនួបកំពូលរវាងឯកឧត្តមប្រធានាធិបតី និងសម្តេច កើតឡើងក្រោយពីការបោះឆ្នោតសកលក្នុងប្រទេសកម្ពុជា ដែលនោះគឺជាការបង្ហាញពីការគាំទ្ររបស់ប្រទេសចិនចំពោះប្រទេសកម្ពុជា ពិសេសគឺគាំទ្រចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលបានបង្កើតឡើង។ សម្តេចតេជោ**ហ៊ុន សែន** មានប្រសាសន៍ថា ជំនួយរបស់ប្រទេសចិននាពេលកន្លងមក និងពេលបច្ចុប្បន្នគឺមិនគ្រាន់តែផ្តល់នូវការគាំទ្រខាងផ្នែកសេដ្ឋកិច្ច និងការអភិវឌ្ឍរបស់ប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែនឹងជួយពង្រឹងដល់ឯករាជ្យភាព ក៏ដូចជាអធិបតេយ្យភាពរបស់កម្ពុជាទាំងមូលផងដែរ ។

ថ្វីត្បិតកម្ពុជាមិនមែនជាសមាជិករបស់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិកក៏ពិតមែន ប៉ុន្តែប្រទេសកម្ពុជាត្រូវបានអញ្ជើញឱ្យមកចូលរួមវេទិកាដ៏មានសារៈសំខាន់នេះ ដើម្បីធ្វើការពិគ្រោះយោបល់ និងការតភ្ជាប់សម្រាប់តំបន់ទាំងមូល។ សម្តេចតេជោក៏បានផ្តល់នូវសេចក្តីសង្ឃឹមថា នៅពេលអនាគតដ៏ខ្លី ប្រទេសដែលជាម្ចាស់នៃកិច្ចប្រជុំកំពូល APEC និងបន្តការផ្តល់នូវការយកចិត្តទុកដាក់ក្នុងការអញ្ជើញដល់បណ្តាប្រទេសដែលមិនជាសមាជិក APEC មកចូលរួមប្រជុំកំពូល APEC ដូចដែលប្រទេសចិនបានធ្វើនៅពេលនេះ ។

ទាក់ទិនទៅនឹងទំនាក់ទំនងទ្វេភាគីនៃប្រទេសទាំងពីរកម្ពុជា-ចិន សម្តេចតេជោ **ហ៊ុន សែន** ស្នើដល់ភាគីចិនបន្តធ្វើកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យនៃប្រទេសទាំងពីរឱ្យកាន់តែស្អិតល្មួតទ្វេឡើងថែមទៀតពិសេសការផ្លាស់ប្តូរនូវដំណើរទស្សនកិច្ចពីគ្រប់កម្រិតទាំងអស់ ចាប់តាំងពីថ្នាក់ដឹកនាំនយោបាយរហូតដល់កម្រិតមហាជន និងប្រជាជន ទី ២ បន្តពង្រីកកិច្ចសហប្រតិបត្តិការក្នុងការរៀបចំចងសម្ពន្ធមេត្រីភាពរវាងខេត្តនិងខេត្ត ទីក្រុងនិងទីក្រុងនៃប្រទេសទាំងពីរ និងទី ៣ បន្តកិច្ចសហប្រតិបត្តិការលើការបណ្តុះបណ្តាលធនធានមនុស្ស ជាពិសេសការផ្លាស់ប្តូរយុវជន ក៏ដូចជាសមាគមស្ត្រីនៃប្រទេសទាំងពីរ ។

សម្តេចតេជោ **ហ៊ុន សែន** ក៏បានស្នើដល់ភាគីចិនបន្តជួយគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា តាមរយៈការផ្តល់កម្ចីហិរញ្ញប្បទានពី ៥០០ លានដុល្លារទៅ ៧០០ លានដុល្លារអាមេរិក ក្នុង ១ ឆ្នាំ និងបើកចំហទីផ្សាររបស់ប្រទេសចិនក្នុងការនាំយកនូវកសិផលពីកម្ពុជាទៅកាន់ប្រទេសចិន ពិសេសការនាំចូលអង្ករពីកម្ពុជាទៅកាន់ប្រទេសចិន។ ក្នុងជំនួបពិភាក្សាគ្នានោះដែរ សម្តេចតេជោក៏បានស្នើដល់ភាគីចិន ជួយជំរុញអ្នកទេសចរចិនមកកាន់កម្ពុជាឱ្យកាន់តែច្រើនឡើងថែមទៀត ពោលគឺកម្ពុជាចង់ឃើញទេសចរចិននៅកម្ពុជាឈរក្នុងអត្រាកំណើនចំណាត់ទី ១ នៅកម្ពុជា ។

នៅក្នុងជំនួបពិភាក្សាដាច់ដោយឡែកជាមួយសម្តេចតេជោ **ហ៊ុន សែន** នៅផ្ទះទទួលភ្ញៀវរដ្ឋក្នុងទីក្រុងប៉េកាំង ឯកឧត្តម **លី យ៉ុនចាវ** អនុប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិនមានប្រសាសន៍ថា វត្តមានរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីនៅពេលនេះនឹងធ្វើឱ្យកិច្ចប្រជុំកំពូល APEC កាន់តែទទួលបានជោគជ័យទ្វេឡើងថែមទៀត ពិសេស ការជំរុញទំនាក់ទំនងនៃប្រទេសទាំងពីរកម្ពុជា-ចិន កាន់តែរឹងមាំទ្វេឡើងថែមទៀត។ ឯកឧត្តមមានប្រសាសន៍ថា កាលពីឆ្នាំ ២០១១ ឯកឧត្តមបានដឹកនាំគណៈប្រតិភូអញ្ជើញទៅបំពេញទស្សនកិច្ចនៅកម្ពុជា ដែលនៅពេលនោះឯកឧត្តមសូមកោតសរសើរដោយស្មោះ ចំពោះការរីកចម្រើនរបស់ប្រទេសកម្ពុជាពិសេសក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី។ ឯកឧត្តមអនុប្រធានាធិបតីមានប្រសាសន៍ថា ចិននឹងពិនិត្យគ្រប់លទ្ធភាពក្នុងការបន្តជួយ ដើម្បីជំរុញសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាឲ្យកាន់តែមានភាពប្រសើរឡើងថែមទៀត។ ឯកឧត្តមបានសង្កត់ធ្ងន់ថា ប្រទេសយើងទាំងពីរកម្ពុជា-ចិន មានទំនាក់ទំនងជាមួយគ្នាជាយូរលង់ណាស់មកហើយ និងមានប្រវត្តិធ្លាប់ជួយគ្នាទៅវិញទៅមកទៀតផង។ ប្រទេសចិនសូមថ្លែងនូវអំណរគុណចំពោះប្រទេសកម្ពុជាដែលតែងតែគាំទ្រចំពោះនយោបាយចិនមួយ និងបានចាត់ទុកថាការគោរពអធិបតេយ្យភាពរបស់ចិន ដូចគ្នានឹងការគោរពអធិបតេយ្យភាពរបស់កម្ពុជាដូច្នេះដែរ ។

សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងនូវអំណរគុណចំពោះរដ្ឋាភិបាល និងប្រជាជនចិនដែលតែងតែគាំទ្រចំពោះប្រទេសកម្ពុជា ក្នុងការផ្តល់ជំនួយឥតសំណង កម្ចីគ្មានការប្រាក់ និងកម្ចីហិរញ្ញប្បទានដល់ការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចជាតិឡើងវិញ។ សម្តេចមានប្រសាសន៍សង្កត់ធ្ងន់ថា ការផ្តល់ជំនួយរបស់ប្រទេសចិនមិនគ្រាន់តែរួមចំណែកដល់ការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែបានជួយពង្រឹងដល់ឯករាជ្យរបស់កម្ពុជាផងដែរ ។

នៅថ្ងៃទី ៨ ខែវិច្ឆិកា កិច្ចសន្ទនាស្តីពីការពង្រឹងភាពជាដៃគូនៃការតភ្ជាប់បានប្រព្រឹត្តទៅនៅទីក្រុងប៉េកាំង ដែលមានការចូលរួមពីប្រមុខរដ្ឋាភិបាលមកពីប្រទេសចិន បង់ក្លាដេស កម្ពុជា ឡាវ មុងហ្គោលី មីយ៉ាន់មា ប៉ាគីស្ថាន តាជីគីស្ថាន។ ក្នុងកិច្ចសន្ទនានោះភាគីទាំងអស់បានទទួលស្គាល់ថា ការអភិវឌ្ឍសេដ្ឋកិច្ច និងការលើកកម្ពស់ជីវភាពប្រជាជន នៅតែជាអាទិភាពសម្រាប់បណ្តាប្រទេសអាស៊ី ហើយប្រការនោះធ្វើឲ្យកាន់តែស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ការអភិវឌ្ឍប្រកបដោយចីរភាព និងសមាហរណកម្មក្នុងតំបន់ នៅតែជាបំណងប្រាថ្នារួមរបស់ប្រជាជនអាស៊ី។ នាពេលបច្ចុប្បន្ននេះ ផលប៉ះពាល់ដែលអូសបន្លាយដោយសារវិបត្តិហិរញ្ញវត្ថុអន្តរជាតិ ដែលបានស្តែងចេញតាមរយៈតម្រូវការពីខាងក្រៅប្រទេសតិចតួចរួមផ្សំ និងការកើនឡើងនូវការប្រកួតប្រជែងផ្នែកមូលធន ទីផ្សារ និងបច្ចេកវិទ្យា បាន និងកំពុងធ្វើឲ្យកិច្ចខិតខំប្រឹងប្រែង ក្នុងការអភិវឌ្ឍរបស់ប្រទេសនៅអាស៊ីកាន់តែលំបាកឡើង ។ ស្ថិតក្នុងកាលទេសៈនេះ ការពង្រឹងការតភ្ជាប់ដែលនឹងផ្តល់លក្ខណៈងាយស្រួលដល់ការកំណត់ចំណុចនៃការវិវឌ្ឍថ្មី នឹងជំរុញឲ្យមានឧត្តមភាពនៃការប្រកួតប្រជែងថ្មីនឹងជាកម្លាំងចលករថ្មី សម្រាប់កិច្ចសហប្រតិបត្តិការនៅតំបន់អាស៊ី និងការស្តារតំបន់នេះឡើងវិញ។ កិច្ចសន្ទនាក៏បានទទួលស្គាល់ថា ការពង្រឹងការតភ្ជាប់ក្នុងតំបន់អាស៊ីសម្រាប់សតវត្សទី ២១ ត្រូវធ្វើតាមរយៈមធ្យោបាយចំនួន ៣ គឺ ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធរឹង ស្តីពីការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ហេដ្ឋារចនាសម្ព័ន្ធទន់ ស្តីពីការធ្វើសុខដុមនីយកម្មផ្នែកច្បាប់ និយ័តកម្ម គោលនយោបាយ និងនិយាមក្នុងចំណោមបណ្តាប្រទេសនានា និងការតភ្ជាប់រវាងប្រជាជន និងប្រជាជន តាមរយៈការជំរុញមិត្តភាព ការជឿទុកចិត្តទៅវិញទៅមក និងការផ្លាស់ប្តូរវប្បធម៌។ ការពង្រឹងការតភ្ជាប់នេះ ពាក់ព័ន្ធនឹងវិស័យ ៥ គឺ ៖ គោលនយោបាយគមនាគមន៍ការមានផ្លូវទៅដល់លំហូរពាណិជ្ជកម្មការតភ្ជាប់ហិរញ្ញវត្ថុនិងការស្វែងយល់គ្នាពីក្នុងចំណោមប្រជាជន ដោយចាត់ទុកការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងអាទិភាព។ កិច្ចសន្ទនាក៏បានគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងក្លា ក្នុងការដោះស្រាយការរាំងស្ទះមូលធនសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ តាមរយៈការបង្កើតយន្តការហិរញ្ញវត្ថុថ្មី។ គាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់ចិន និងប្រទេសពាក់ព័ន្ធក្នុងការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី ដែលជាការបំពេញបន្ថែមសម្រាប់







*មេដឹកនាំនៅក្នុងកិច្ចសន្ទនាស្តីពីការពង្រឹងភាពជាដៃគូ*

ស្ថាប័នហិរញ្ញវត្ថុដែលមានស្រាប់ ដូចជា ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ។ គាំទ្រគំនិតផ្តួចផ្តើម(ខ្សែក្រវ៉ាត់សេដ្ឋកិច្ចវិថីសូត្រ)និង(វិថីសូត្រសមុទ្រសម្រាប់សតវត្សទី ២១ ) ខ្សែក្រវ៉ាត់មួយ វិថីមួយ ដែលផ្អែកលើកត្តាជំរុញពីប្រវត្តិសាស្ត្រ និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ និងពេលវេលាបច្ចុប្បន្ន ដោយស្របទៅតាមការអភិវឌ្ឍនៃការតភ្ជាប់នៅអាស៊ី។ កិច្ចសន្ទនាក៏បានប្តេជ្ញារួមគ្នារៀបចំផែនការសម្រាប់ការអភិវឌ្ឍ និងចែករំលែកអត្ថប្រយោជន៍ខ្សែក្រវ៉ាត់មួយ វិថីមួយ។ ដោយមានប្រភពពីតំបន់អាស៊ី ខ្សែក្រវ៉ាត់មួយវិថីមួយ គួរតែ៖ ផ្តោតជាសំខាន់ចំពោះបណ្តាប្រទេសអាស៊ី និងផ្តល់អាទិភាពចំពោះកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍការតភ្ជាប់នៅអាស៊ីបង្កើតក្របខណ្ឌសម្រាប់ការតភ្ជាប់អាស៊ី ដោយផ្អែកលើច្រករបៀងសេដ្ឋកិច្ចផ្លូវគោក និងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចផ្លូវសមុទ្រ សម្រេចឲ្យបាននូវការទំលាយភាពជាប់គាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន សម្រាប់ការតភ្ជាប់អាស៊ី ពង្រឹងការគាំទ្រជាសាធារណៈ សម្រាប់ការតភ្ជាប់អាស៊ីតាមរយៈការផ្លាស់ប្តូរប្រជាជន និងប្រជាជន។ ជាចុងក្រោយ កិច្ចសន្ទនាបានសម្តែងការជឿជាក់ថា នៅក្នុងយុគសម័យសាកលភាវូបនីយកម្ម និងពហុប៉ូល រួមជាមួយនឹងការកើនឡើងនៃពហុវប្បធម៌ និងសង្គមដែលមានការរីកចម្រើនលឿនផ្នែកព័ត៌មានរបស់ប្រទេសនានា គឺឯករាជ្យ និងពឹងអាស្រ័យគ្នាទៅវិញទៅមកក្នុងពេលតែមួយ។ ភាពជាដៃគូតភ្ជាប់ មិនគ្រាន់តែជាផ្នែកមួយដ៏សំខាន់នៃទំនាក់ទំនងភាពជាដៃគូក្នុងចំណោមប្រទេសអាស៊ីប៉ុណ្ណោះទេ ប៉ុន្តែក៏បម្រើដល់ការអភិវឌ្ឍតំបន់អាស៊ី និងកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសហគមន៍ដែលមានវាសនាតែមួយផងដែរ ។ វេទិកានៃកិច្ចសន្ទនាអំពាវនាវដល់បណ្តាប្រទេសអាស៊ីទាំងអស់ ឲ្យពង្រឹងកិច្ចសហប្រតិបត្តិការលើកកម្ពស់ការអភិវឌ្ឍការតភ្ជាប់នៅតំបន់អាស៊ី និងបង្កើនកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីសម្រេចឲ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងវឌ្ឍនភាពនៅតំបន់អាស៊ីទាំងមូល ។

ក្នុងឱកាសធ្វើមាតុភូមិនិវត្តមកដល់រាជធានីភ្នំពេញ ឯកឧត្តម **កៅ គឹមហួន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីបានថ្លែងប្រាប់អ្នកសារព័ត៌មានថា នៅក្នុងកិច្ចសន្ទនានោះ ឯកឧត្តមប្រធានាធិបតីចិនបានប្រកាសថា ចិនបានចំណាយថវិកាប្រមាណ ៧៣០ ០០០ លានដុល្លារ ក្នុងការបង្កើតហេដ្ឋារចនាសម្ព័ន្ធប្រកបដោយចីរភាពក្នុងទ្វីបអាស៊ី ។ ក្នុងរយៈពេលប្រមាណ ១ ខែកន្លងមកនេះ ចិន និងបណ្តាប្រទេសក្នុងតំបន់អាស៊ីបានចុះហត្ថលេខា ក្នុងការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី ដែលវត្ថុបំណងនៃការបង្កើតធនាគារនោះ គឺដើម្បីចូលរួមដោះស្រាយ និងធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសអាស៊ី ជាពិសេស បណ្តាប្រទេសផ្លូវសូត្រ ។ ឯកឧត្តម **ស៊ី ជីនភីង** មានប្រសាសន៍ថា រដ្ឋាភិបាលចិននឹងបង្កើតផ្លូវដែកនៅក្នុងប្រទេសប៉ាគីស្ថាន បង់ក្លាដេស មីយ៉ាន់ម៉ា ឡាវ កម្ពុជា ម៉ុងហ្គោលី និងតាហ្ស៊ីគីស្ថាន។ ចិននឹងផ្តល់អាហារូបករណ៍ដល់សិស្សនិស្សិត ២ ពាន់នាក់ក្នុងមួយឆ្នាំ និងការធ្វើការផ្លាស់ប្តូដំណើរទស្សនកិច្ចទៅវិញទៅមកនៅក្នុងបណ្តាប្រទេសផ្លូវសូត្រ ពោល គឺធ្វើយ៉ាងណាឲ្យតំបន់អាស៊ីទទួលបាននូវវិបុលភាព សន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព។ មានប្រសាសន៍នៅក្នុងកិច្ចសន្ទនានោះ សម្តេចតេជោ **ហ៊ុន សែន** បានស្វាគមន៍ និងគាំទ្រយ៉ាងពេញទំហឹងចំពោះគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ផ្លូវសូត្រសេដ្ឋកិច្ច និងផ្លូវសូត្រសមុទ្រ សម្រាប់សតវត្សទី២១ ដែលនឹងធានាឲ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ អាចរួមចំណែកដល់ការតភ្ជាប់កាន់តែទូលំទូលាយ និងបំពេញឲ្យគ្នាទៅវិញទៅមករវាងគ្រប់អនុតំបន់។ កម្ពុជាក៏សូមស្វាគមន៍ចំពោះការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី ដែលជាគំនិតផ្តួចផ្តើមរបស់ចិន និងមានជំនឿថា ធនាគារនោះនឹងផ្តល់អាទិភាពជាពិសេសដល់សេចក្តីត្រូវការក្នុងការតភ្ជាប់ទាំងរបស់អាស៊ាននិយាយជារួម ទាំងរបស់កម្ពុជានិយាយដោយឡែក។ សម្តេចតេជោមានប្រសាសន៍ទៀតថា ផែនការមេស្តីពីការតភ្ជាប់តំបន់អាស៊ាន បានបង្កើតក្របខណ្ឌ មិនមែនត្រឹមតែកិច្ចសហប្រតិបត្តិការក្នុងតំបន់អាស៊ានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ជាវេទិកាសម្រាប់ជាដៃគូយុទ្ធសាស្ត្ររបស់អាស៊ានពិសេសក្នុងក្របខណ្ឌអាស៊ានបូក១និងអាស៊ានបូក៣ដើម្បីផ្តល់ការគាំទ្រដល់ការអនុវត្តផែនការមេនោះ ទាំងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្នែករឹង និងផ្នែកទន់ ជាពិសេស លើការតភ្ជាប់គមនាគមន៍ផ្លូវគោក ផ្លូវទឹក ផ្លូវរថភ្លើង ផ្លូវអាកាស ព្រមទាំងការតភ្ជាប់នាវាសមុទ្រ។ សម្តេចតេជោ **ហ៊ុន សែន** បានសម្តែងការពេញចិត្ត និងសូមសម្តែងនូវការកោតសរសើរចំពោះសាធារណរដ្ឋប្រជាមានិតចិន ដែលបានចូលរួមវិភាគទានដ៏មានតម្លៃ និងបានដើរតួយ៉ាងសំខាន់ ក្នុងការពង្រឹងការតភ្ជាប់តំបន់។ ឯកឧត្តម **កៅ គឹមហួន** បានថ្លែងឲ្យដឹងទៀតថា នៅក្នុងកិច្ចប្រជុំ APEC CEO Summit 2014 សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងសុន្ទរកថាទៅកាន់អង្គប្រជុំ ដោយបានស្នើសុំឲ្យAPECលុបចោលការបិទមិនឲ្យមានសមាជិកភាពថ្មីដោយសារចរន្តបច្ចុប្បន្នក្នុងតំបន់គឺសេដ្ឋកិច្ចបើកចំហ។ ដូច្នេះពេលវេលាមកដល់ហើយដែលភាពឯកោក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកនេះគួរតែបញ្ចប់។

សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងគណៈប្រតិភូ បានធ្វើមាតុភូមិនិវត្តន៍មកដល់រាជធានីភ្នំពេញថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ ២០១៤ ប្រកបដោយសុវត្ថិភាព៕

# សម្ដេចតេជោ ហ៊ុន សែន អញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី ២៥ និងកិច្ចប្រជុំពាក់ព័ន្ធនៅសហភាពមីយ៉ាន់ម៉ា





*ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល នៃបណ្ដាប្រទេសអាស៊ានចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី ២៥ និងកិច្ចប្រជុំពាក់ព័ន្ធនៅសហភាពមីយ៉ាន់ម៉ា*

តបតាមសេចក្ដីអញ្ជើញរបស់ឯកឧត្តម **ថេន សេន** ប្រធានាធិបតីនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ាចាប់ពីថ្ងៃទី០៨-១៣ខែវិច្ឆិកាឆ្នាំ២០១៤ សម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ អញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី ២៥ និងកិច្ចប្រជុំពាក់ព័ន្ធនៅសហភាពមីយ៉ាន់ម៉ា។

នៅថ្ងៃទី ១១ ខែវិច្ឆិកា សម្ដេចតេជោ **ហ៊ុន សែន** និងឯកឧត្តម **ថេន សេន** បានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលធុរកិច្ច និងវិនិយោគអាស៊ាន និងការផ្ដល់រង្វាន់ធុរកិច្ចអាស៊ានឆ្នាំ២០១៤នៅមជ្ឈមណ្ឌលសន្និសីទអន្តរជាតិណៃពិដោរ។ ឯកឧត្តម **ថេន សេន** បានថ្លែងថា កន្លងមកអាស៊ានបានឆ្លងកាត់នូវការលំបាកជាច្រើន ពោលគឺក្នុងរយៈពេល ៤៧ ឆ្នាំនៃការបង្កើតអាស៊ាននេះ ពិសេសឆ្លងកាត់វិបត្តិសេដ្ឋកិច្ច គ្រោះធម្មជាតិ និងជំងឺរាតត្បាតនានា ប៉ុន្តែផ្ទុយទៅវិញ បញ្ហាទាំងអស់នេះបានធ្វើឲ្យអាស៊ានកាន់តែមានកម្លាំងខ្លាំងក្លាជាងមុន និងមានផលប្រយោជន៍ពីគ្នា ទៅវិញទៅមក។ បច្ចុប្បន្ន សេដ្ឋកិច្ចអាស៊ានមានកំណើនរហូតដល់ ២៥០ ០០០ លានដុល្លារ ស្ថិតក្នុងចំណាត់ថ្នាក់ទី ៧ នៃសេដ្ឋកិច្ចពិភពលោក។ ការធ្វើបបនីយកម្មក្នុងតំបន់អាស៊ានមានការកើនឡើងជាលំដាប់ ក្នុងនោះកាលពីឆ្នាំ២០១៣ កន្លងទៅ ការធ្វើពាណិជ្ជកម្មក្នុងចំណោមប្រទេសអាស៊ានចំនួន ៦០២ ០០០ លានដុល្លារ ។ ដូចនេះការប្រមើលមើលក្នុងឆ្នាំ ២០៥០ ខាងមុខ សេដ្ឋកិច្ចអាស៊ាននឹងមានការកើនឡើងរហូតដល់ចំណាត់ថ្នាក់ទី ៤ នៃសេដ្ឋកិច្ចពិភពលោក ។ ប្រជាពលរដ្ឋអាស៊ាននឹងមានរហូតដល់ប្រមាណ ៣០០០ លាននាក់ និងមានផលទុនសរុបរហូតដល់ ១ ៧០០ ០០០ ដុល្លារ ពោលគឺស្មើនឹង ៤០% នៃពាណិជ្ជកម្មពិភពលោក។ បច្ចុប្បន្នពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាមក្នុងឆ្នាំ ២០១៣ មានទឹកប្រាក់ប្រមាណ ៣១២ ០០០ លានដុល្លារ គឺមានការកើនឡើងប្រមាណ ៥% បើធៀបនឹងឆ្នាំ ២០១២ ។ ដោយឡែកការវិនិយោគចូលទៅក្នុងប្រទេសទាំង ៤ មានប្រមាណ ១៣ ២០០ លានដុល្លារ ពិសេសការវិនិយោគលើវិស័យសំណង់ និងការផលិត។ ចំពោះបណ្ដាបទអន្តរាគមន៍នៅក្នុងពិធីនោះ ក៏បានធ្វើការទាមទារឲ្យអាស៊ានមានការឯកភាពផ្ទៃក្នុងកាន់តែខ្លាំងជាងមុន និងមានកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធជាងមុនក្នុងចំណោមថ្នាក់ដឹកនាំនយោបាយរដ្ឋាភិបាល អ្នកដឹកនាំពាណិជ្ជកម្ម និងប្រជាជនក្នុងអាស៊ាន ដើម្បីធ្វើយ៉ាងណាឲ្យរបត់ថ្មីនៃការតភ្ជាប់កាន់តែទទួលបានជោគជ័យទ្វេឡើងថែមទៀត ។ ថ្វីត្បិតតែសេដ្ឋកិច្ចអាស៊ានមានលក្ខណៈល្អប្រសើរក៏ពិតមែន ប៉ុន្តែសេដ្ឋកិច្ចអាស៊ាននៅតែជួបប្រទះបញ្ហាប្រឈមមួយចំនួនដោយត្រូវបន្តខិតខំជំរុញបន្ថែមទៀតក្នុងការកាត់បន្ថយ និងលុបបំបាត់នូវភាពក្រីក្រ និងកាត់បន្ថយគម្លាតនៃការអភិវឌ្ឍក្នុងចំណោមប្រទេសអាស៊ាន ។ នៅក្នុងពិធីនោះឯកឧត្តម **ថេន សេន** និងសម្ដេចតេជោ **ហ៊ុន សែន** បានអញ្ជើញប្រគល់ពានរង្វាន់ដល់ក្រុមហ៊ុនឆ្នើមមួយចំនួនរបស់ប្រទេសអាស៊ាន ដែលបានចូលរួមអនុវត្តយ៉ាងពេញលេញក្នុងការធ្វើពាណិជ្ជកម្ម និងការវិនិយោគក្នុងចំណោមបណ្ដាប្រទេសអាស៊ាននៅឆ្នាំ ២០១៤ ។

នៅថ្ងៃទី ១២ ខែវិច្ឆិកា កិច្ចប្រជុំកំពូលពេញអង្គអាស៊ានលើកទី ២៥ បានបើកធ្វើឡើង ដោយបានពិភាក្សាទៅលើរបៀបវារៈចំនួន២គឺ ទី១ការពិភាក្សាទៅលើសហគមន៍អាស៊ានឆ្នាំ២០១៥និងឆ្នាំខាងមុខទី២ការផ្លាស់ប្ដូរទស្សនៈអំពីបញ្ហាតំបន់ និងអន្តរជាតិ។ មេដឹកនាំអាស៊ានបានធ្វើការកត់សម្គាល់នូវរបាយការណ៍ប្រចាំឆ្នាំរបស់អគ្គលេខាធិការអាស៊ាន ស្ដីពីការងារអាស៊ាន របាយការណ៍របស់ក្រុមប្រឹក្សាសហគមន៍នយោបាយសន្តិសុខអាស៊ាន របាយការណ៍ក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន របាយការណ៍ក្រុមប្រឹក្សាសហគមន៍សង្គម វប្បធម៌អាស៊ាន របាយការណ៍ក្រុមប្រឹក្សាធុរកិច្ចអាស៊ាន របាយការណ៍ត្រួតពិនិត្យការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ និងគោលការណ៍អាស៊ានសម្រាប់ក្របខណ្ឌភាពជាដៃគូរវាងស្ថាប័នរដ្ឋ និងវិស័យឯកជន។ សម្ដេចតេជោ **ហ៊ុន សែន** បានថ្លែងសុន្ទរកថាគន្លឹះនៅក្នុងកិច្ចប្រជុំនោះដោយបានបញ្ជាក់ថាអាស៊ានកំពុងបន្តជួបប្រឈមបញ្ហាចម្រុងៗមួយចំនួន ដែលទាមទារអោយមានការពង្រឹងកិច្ចសហប្រតិបត្តិការកាន់តែស៊ីជម្រៅ និងជំរុញការដោះស្រាយឲ្យទាន់ពេលវេលា ជាមួយនឹងវិធានការច្បាស់លាស់ដើម្បីសម្រេចបាននូវសហគមន៍អាស៊ាននៅចុងឆ្នាំ ២០១៥ និងចក្ខុវិស័យអាស៊ានក្រោយឆ្នាំ ២០១៥ ។ សម្ដេចតេជោ**ហ៊ុនសែន**មានប្រសាសន៍ទៀតថាការអភិវឌ្ឍប្រកបដោយចីរភាព ទាមទារនូវអភិក្រមនៃកិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធ និង



*ឯកឧត្ដម **បារ៉ាក់ អូបាម៉ា** បានបង្ហាញនូវការស្វាគមន៍ចំពោះការគាំទ្ររបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលជំរុញឲ្យមានការបង្កើនកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងពួករដ្ឋឥស្លាមនៅអ៊ីរ៉ាក់ និងស៊ីរី*

ទូលំទូលាយជាងមុន ជាពិសេស តាមរយៈកិច្ចសហប្រតិបត្តិការក្នុងតំបន់ដើម្បីដោះស្រាយបញ្ហារួម ។ ជាក់ស្ដែងបច្ចុប្បន្ននេះ ក្រុមជ្រុលនិយមរដ្ឋឥស្លាមនៅអ៊ីរ៉ាក់ និងស៊ីរី បាននិងកំពុងគំរាមកំហែងយ៉ាងធ្ងន់ធ្ងរចំពោះស្ថិរភាព និងសន្តិសុខតំបន់ និងពិភពលោក។ កម្ពុជាសូមចូលរួមជាមួយបណ្ដាប្រទេសក្នុងពិភពលោក និងសម្ដែងនូវការគាំទ្រយ៉ាងពេញទំហឹងចំពោះយុទ្ធនាការអន្តរជាតិប្រឆាំងនឹងក្រុមជ្រុលនិយមនោះ ។ ទាក់ទិនបញ្ហាសមុទ្រចិនខាងត្បូង កម្ពុជាគាំទ្រសេចក្ដីសម្រេចរបស់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន ចិន កាលពីខែសីហា ឆ្នាំ ២០១៤ នៅទីក្រុងណៃពិដោរ និងបានស្នើឲ្យមានការជំរុញការពិគ្រោះយោបល់ជាផ្លូវការដើម្បីឈានទៅសម្រេចការតាក់តែងក្រមប្រតិបត្តិឲ្យបានឆាប់។ ទាក់ទិនបញ្ហាឧបទ្វីបកូរ៉េ កម្ពុជាគាំទ្រកិច្ចសន្ទនា និងការពិគ្រោះយោបល់រវាងប្រទេសកូរ៉េទាំងពីរ ព្រមទាំងការចាប់ផ្ដើមនូវការចរចា ៦ ភាគីឡើងវិញ ដើម្បីធានាសន្តិសុខតំបន់ទាំងមូល ពិសេសកម្ពុជាសូមលើកទឹកចិត្ត និងជំរុញឲ្យភាគីទាំងអស់ខិតខំអនុវត្តឲ្យបានពេញលេញ នូវសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ អ.ស.ប.។

កិច្ចប្រជុំកំពូលអាស៊ាន ចិន លើកទី ១៧ បានប្រព្រឹត្តទៅក្រោមវត្តមានឯកឧត្ដម **លី ខេឈាង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន និងបណ្ដាមេដឹកនាំអាស៊ាន ដោយបានធ្វើការពិភាក្សាយ៉ាងយកចិត្តទុកដាក់ទៅលើទំនាក់ទំនង កិច្ចសហប្រតិបត្តិការអាស៊ាន ចិន និងបានធ្វើការពិភាក្សាអំពីបញ្ហានៅសមុទ្រចិនខាងត្បូង។ភាគីចិនបានឯកភាព និងគាំទ្រនូវវិធីដោះស្រាយពីផ្លូវដែលបានស្នើឡើងដោយប្រទេសអាស៊ាន ក្នុងការដោះស្រាយសមុទ្រចិនខាងត្បូង ហើយជម្លោះនេះត្រូវធ្វើឡើងតាមរយៈការចរចារវាងភាគីពាក់ព័ន្ធផ្ទាល់។ ចិន អាស៊ានត្រូវធ្វើការជាមួយគ្នាដើម្បីរក្សាសន្តិភាព និងស្ថិរភាពនៅក្នុងសមុទ្រចិនខាងត្បូង ដោយប្រកាន់ខ្ជាប់ឲ្យបានពេញលេញ តាមស្មារតីដូចដែលមានចែងនៅក្នុងសេចក្ដីថ្លែងការណ៍ស្ដីពីប្រតិបត្តិការនៃភាគីនៅសមុទ្រចិនខាងត្បូង DOC វិធីដោះស្រាយពីផ្លូវ Dual Track Approach នេះគឺតំណាងឲ្យមាគ៌ាដ៏ត្រឹមត្រូវតែមួយគត់ក្នុងការដោះស្រាយឲ្យបានសមស្រប និងរិះរកនូវដំណោះស្រាយ



*សម្ដេចតេជោ **ហ៊ុន សែន** ជួបពិភាក្សាការងារជាមួយឯកឧត្ដម **បាន គីមូន** អគ្គលេខាធិការនៃ អ.ស.ប.*

សម្រាប់បញ្ហាសមុទ្រចិនខាងត្បូងប្រកបដោយយុត្តិធម៌ និងស្ថិតស្ថេរ ។ ចិននៅតែប្ដេជ្ញាអនុវត្តសេចក្ដីថ្លែងការណ៍ ស្ដីពីការប្រតិបត្តិនៃភាគីនៃសមុទ្រចិនខាងត្បូង DOC ឲ្យបានទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាព ដោយធ្វើការរួមគ្នាជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីគ្រប់គ្រងការខ្វែងគំនិតគ្នា ជំរុញសហប្រតិបត្តិការដែនសមុទ្រ និងការអភិវឌ្ឍរួម ព្រមទាំងកសាងសមុទ្រចិនខាងត្បូង ឲ្យក្លាយទៅជាតំបន់សមុទ្រមួយប្រកបដោយសន្តិភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការ។ ក្នុងកិច្ចប្រជុំនេះ សម្ដេចតេជោ **ហ៊ុន សែន** បានគាំទ្រដល់គំនិតផ្ដួចផ្ដើមរបស់ប្រទេសចិន ពាក់ព័ន្ធនឹងសន្ធិសញ្ញាអាស៊ាន ចិន ស្ដីពីអ្នកជិតខាងល្អ មិត្តភាព និងកិច្ចសហប្រតិបត្តិការ ។

កិច្ចប្រជុំកំពូលអាស៊ាន អាមេរិក លើកទី ២ បានប្រព្រឹត្តទៅក្រោមវត្តមានឯកឧត្ដម **បារ៉ាក់ អូបាម៉ា** ប្រធានាធិបតីសហរដ្ឋអាមេរិក និងមេដឹកនាំអាស៊ាន ដោយបានពិភាក្សាទៅលើទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងអាស៊ាន អាមេរិក ដែលនោះជាទំនាក់ទំនងកម្រិតខ្ពស់បំផុតតាមរយៈការដំឡើងភាពជាដៃគូអាស៊ាន អាមេរិក ឲ្យឈានដល់កម្រិតយុទ្ធសាស្ត្រ។ កិច្ចប្រជុំបានគូសបញ្ជាក់ពីសារៈសំខាន់នៃសន្តិសុខតាមប្រព័ន្ធអ៊ិនធើណេត និងកិច្ចសហការក្នុងការប្រឆាំងឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធើណេត ការរត់ពន្ធមនុស្ស ការប្រឆាំងភេរវកម្ម និងសុវត្ថិភាពលំហសមុទ្រ ដែលរួមចំណែកដ៏សំខាន់ដល់ការលើកកម្ពស់សន្តិភាព និងស្ថិរភាព។ឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រឆាំងភេរវកម្មអន្តរជាតិ ក្នុងក្របខណ្ឌនៃសេចក្ដីថ្លែងការណ៍អាស៊ានអាមេរិក ស្ដីពីកិច្ចសហប្រតិបត្តិការប្រឆាំងភេរវកម្មអន្តរជាតិ និងយុទ្ធសាស្ត្ររបស់ អ.ស.ប ប្រឆាំងភេរវកម្មជាសកល។មេដឹកនាំអាស៊ានអាមេរិកបានគូសបញ្ជាក់អំពីសារៈសំខាន់នៃភាពជាដៃគូរវាងរដ្ឋនឹងវិស័យឯកជន ក្នុងការអនុវត្តគំនិតផ្ដួចផ្ដើមកិច្ចសហប្រតិបត្តិការផ្នែកថាមពល និងសម្ដែងនូវការពេញចិត្តចំពោះការបន្តគាំទ្ររបស់អាមេរិកដល់កិច្ចព្រមព្រៀងអាស៊ាន ស្ដីពីការឆ្លើយតបបន្ទាន់ចំពោះការគ្រប់គ្រងគ្រោះមហន្តរាយ និងមជ្ឈមណ្ឌលសម្របសម្រួលអាស៊ានសម្រាប់ជំនួយមនុស្សធម៌មគ្រប់គ្រងគ្រោះមហន្តរាយ រួមទាំងតួនាទីសកម្មរបស់អាមេរិកក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការអនុតំបន់ តាមរយៈគំនិតផ្ដួចផ្ដើមមេគង្គក្រោម ការគាំទ្រការបង្កើត និងដំណើរការមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន ដែលជាមជ្ឈមណ្ឌលឧត្ដមភាពក្នុង



*សម្តេចតេជោ **ហ៊ុន សែន** ជួបពិភាក្សាការងារទ្វេភាគីជាមួយ ឯកឧត្តម **ស៊ិន ហ្សូអាបេ** នាយករដ្ឋមន្ត្រីជប៉ុន*

ការលើកទឹកចិត្តដល់កិច្ចខិតខំប្រឹងប្រែងរួមសម្រាប់ដោះស្រាយគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះពីសង្គ្រាម នៅក្នុងបណ្តាប្រទេសសមាជិកអាស៊ានមួយចំនួន។ សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងសុន្ទរកថាក្នុងកិច្ចប្រជុំនេះថា យើងទាំងអស់គ្នាគួរតែបង្កើនកិច្ចប្រឹងប្រែងឲ្យកាន់តែខ្លាំងក្លាជាងមុន និងពង្រឹងកិច្ចសហប្រតិបត្តិការរបស់យើងបន្ថែមទៀត ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងនឹងក្រុមជ្រុលនិយមរដ្ឋឥស្លាមនៅអ៊ីរ៉ាក់ និងស៊ីរី និងដោះស្រាយផលប៉ះពាល់អវិជ្ជមានកើតចេញពីការប្រែប្រួលអាកាសធាតុ ដែលជាបញ្ហាប្រឈមសម្រាប់សកលលោកទាំងមូល។ កម្ពុជាសូមសម្តែងនូវការគាំទ្រ ក្នុងការប្រយុទ្ធប្រឆាំងនឹងក្រុមជ្រុលនិយមរដ្ឋឥស្លាមនៅអ៊ីរ៉ាក់ និងស៊ីរី និងសូមស្វាគមន៍នូវការអនុម័តសេចក្តីថ្លែងការណ៍រួមអាស៊ាន អាមេរិក ស្តីពីការប្រែប្រួលអាកាសធាតុ។ គួរបញ្ជាក់ថា ឯកឧត្តមប្រធានាធិបតីសហរដ្ឋអាមេរិក **បារ៉ាក់ អូបាម៉ា** បានបង្ហាញនូវការស្វាគមន៍ចំពោះការគាំទ្ររបស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា ដែលជំរុញឲ្យមានការបង្កើនកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងពួករដ្ឋឥស្លាមនៅអ៊ីរ៉ាក់ និងស៊ីរី ។ ឯកឧត្តម**បារ៉ាក់អូបាម៉ា**បានចាប់ដៃនិងបង្ហាញពីការថ្លែងអំណរគុណដោយផ្ទាល់ បន្ទាប់ពីសម្តេចតេជោ **ហ៊ុន សែន** បានបញ្ចប់សុន្ទរកថាដ៏មានអត្ថន័យជ្រាលជ្រៅនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានអាមេរិកលើកទី ២ នេះ ។

កិច្ចប្រជុំកំពូលអាស៊ាន ជប៉ុន បានប្រព្រឹត្តទៅក្រោមវត្តមានឯកឧត្តម **ស៊ិន ហ្សូអាបេ** នាយករដ្ឋមន្ត្រីជប៉ុន និងមេដឹកនាំអាស៊ាន ដោយបានពិភាក្សាអំពីបញ្ហាជម្លោះនៅសមុទ្រចិនខាងត្បូង ដែលត្រូវតែដោះស្រាយតាមការប្រកាន់ខ្ជាប់នូវភាពអត់ធ្មត់ ចៀសវាងសកម្មភាពនានាដែលបង្កើតឲ្យសភាពការណ៍កាន់តែស្មុគស្មាញ ។ អង្គប្រជុំបានកត់សម្គាល់នូវទស្សនៈរបស់ជប៉ុនដែលថា បណ្តារដ្ឋដែលជាប់ឆ្នេរសមុទ្រត្រូវគោរពដល់គោលការណ៍ទូទៅនៃច្បាប់អន្តរជាតិ ពោលគឺត្រូវប្រកាន់ខ្ជាប់នូវភាពអត់ធ្មត់ ដើម្បីទប់ស្កាត់នូវសកម្មភាពឯកតោភាគីនានា ដែលបង្កឲ្យមាននូវការផ្លាស់ប្តូររូបវន្តជាអចិន្ត្រៃយ៍ដល់បរិស្ថានសមុទ្រ។ មេដឹកនាំអាស៊ាន ជប៉ុន បានស្វាគមន៍ចំពោះការអនុម័តនូវសេចក្តីថ្លែងការណ៍រួមអាស៊ាន ជប៉ុន ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការប្រឆាំងភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែន និងបានបញ្ជាក់ជាថ្មីម្តងទៀត នូវការប្តេជ្ញាចិត្តបង្កើនពាណិជ្ជកម្ម និងលំហូរវិនិយោគទ្វេដងនៅឆ្នាំ ២០២២។ មេដឹកនាំអាស៊ានបានលើកទឹកចិត្តដល់ភាគីជប៉ុនឲ្យជំរុញកិច្ចសហប្រតិបត្តិការ ក្នុងផែនការសកម្មភាពយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម SMEs ក្រោយឆ្នាំ ២០១៥។ មេដឹកនាំអាស៊ានក៏បានលើកទឹកចិត្តដល់ភាគីជប៉ុនឲ្យបន្តគាំទ្រដល់ការកាត់បន្ថយគម្លាតនៃការអភិវឌ្ឍនៅក្នុងតំបន់ តាមរយៈផែនការការងារទី ២ នៃគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន របៀងសេដ្ឋកិច្ច តំបន់សេដ្ឋកិច្ច ជាពិសេសវិស័យនានានៃកិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់។ កិច្ចប្រជុំបានសម្តែងអំណរគុណចំពោះកម្ពុជាដែលបានធ្វើជាម្ចាស់ផ្ទះរៀបចំវេទិកាថ្នាក់ដឹកនាំវ័យក្មេងអាស៊ានជប៉ុនតួនាទីយុវជនក្នុងទំនាក់ទំនងអាស៊ាន ជប៉ុន នៅក្នុងសតវត្សទី ២១ កាលពីឆ្នាំ ២០១៣ និងវេទិកាសហគ្រាសវ័យក្មេងអាស៊ាន ជប៉ុន ភាពជាដៃគូសម្រាប់ការអភិវឌ្ឍនៅដើមឆ្នាំ ២០១៤ ។ មេដឹកនាំអាស៊ាន ជប៉ុន ក៏បានទទួលស្គាល់ពីសារៈសំខាន់នៃការថែរក្សាសន្តិភាព សន្តិសុខ និងស្ថិរភាពនៅក្នុងឧបទ្វីបកូរ៉េ និងអំពាវនាវឲ្យបំបាត់អាវុធនុយក្លេអ៊ែរដោយសន្តិវិធី និងឲ្យមានការចរចា ៦ ភាគី ឡើងវិញឲ្យបានឆាប់។ក្នុងកិច្ចប្រជុំនេះសម្តេចតេជោ**ហ៊ុនសែន**បានគាំទ្រការស្នើសុំរបស់ប្រទេសជប៉ុន ចំពោះការរៀបចំកិច្ចប្រជុំក្រៅផ្លូវការរបស់រដ្ឋមន្ត្រីការពារជាតិអាស៊ាន ជប៉ុន ដែលគ្រោងធ្វើនាពេលខាងមុខ ។

សម័យប្រជុំពេញអង្គនៃកិច្ចប្រជុំអាស៊ីបូព៌ាលើកទី ៩ បានពិភាក្សាទៅលើរបៀបវារៈសំខាន់ ៣ គឺបញ្ហាសន្តិសុខមិនមែនប្រពៃណី បញ្ហាបម្រែបម្រួលអាកាសធាតុ បញ្ហានៃការគ្រប់គ្រងគ្រោះមហន្តរាយ និងជំងឺឆ្លង។ កិច្ចប្រជុំកំពូលនេះ បានធ្វើការកត់សម្គាល់លើរបាយការណ៍របស់ក្រុមប្រឹក្សានៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ាជំហានទី ២ ស្តីពីការពង្រឹងការគ្រប់គ្រងសន្តិសុខស្បៀង និងផលធល។ បញ្ជាក់សារជាថ្មីនូវការគាំទ្រទាំងអស់គ្នាចំពោះការលើកស្ទួយតួនាទីស្នូលរបស់អាស៊ាន នៅក្នុងកិច្ចប្រជុំកំពូលអាស៊ីបូព៌ា។ មេដឹកនាំទាំងអស់ប្តេជ្ញាចិត្តក្នុងការអនុវត្តសេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំកំពូលអាស៊ីលើកទី ៧ ស្តីពីការឆ្លើយតបថ្នាក់តំបន់ទៅនឹងការគ្រប់គ្រងជំងឺគ្រុនចាញ់ ការដោះស្រាយភាពស៊ាំនឹងឱសថរបស់ជំងឺគ្រុនចាញ់។ ស្វាគមន៍ចំពោះរបាយការណ៍វឌ្ឍនភាព ឆ្នាំ២០១៤ និងអនុសាសន៍របស់ក្រុមការងារនៃសម្ព័ន្ធប្រមុខថ្នាក់ដឹកនាំអាស៊ីប៉ាស៊ីហ្វិកប្រឆាំងជំងឺគ្រុនចាញ់ ស្តីពីលទ្ធភាពក្នុងការទទួលបានឱសថដែលមានគុណភាព និងបច្ចេកវិទ្យាផ្សេងៗ និងការផ្តល់ហិរញ្ញវត្ថុប្រឆាំងជំងឺគ្រុនចាញ់ ។ មេដឹកនាំទាំងអស់បានអះអាងនូវការប្តេជ្ញាជាថ្មីសម្រាប់ពិភពលោកគ្មានអាវុធនុយក្លេអ៊ែរ និងអាវុធប្រល័យលោក ស្វាគមន៍ការដាក់បញ្ចូលការរំសាយអាវុធ និងការមិនរីកសាយអាវុធ ជាផ្នែកមួយនៃរបៀបវារៈនៃកិច្ចប្រជុំកំពូលអាស៊ីបូព៌ា។ ប្តេជ្ញាចិត្តផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនានា ដែលចាំបាច់សម្រាប់ទប់ស្កាត់វីរុសអេបូឡាមិនឲ្យរីករាលដាលថែមទៀត ដោយផ្អែកទៅលើបទពិសោធន៍ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺឆ្លង។

កិច្ចប្រជុំកំពូលអាស៊ាន ឥណ្ឌាលើកទី ១២ បានឯកភាពដំឡើងកម្រិតនៃកិច្ចសន្ទនាពីភាពជាដៃគូមកជាដៃគូយុទ្ធសាស្ត្រ ដើម្បីជំរុញផែនការសកម្មភាពពីឆ្នាំ២០១៦ដល់ឆ្នាំ២០២០រវាងអាស៊ានឥណ្ឌាឲ្យទទួលបានជោគជ័យ។ ក្នុងកិច្ចប្រជុំនេះសម្តេចតេជោ **ហ៊ុន សែន** បានស្នើឲ្យរដ្ឋាភិបាលឥណ្ឌាបន្តការគាំទ្រចំពោះហិរញ្ញវត្ថុ ក៏ដូចជាជំនួយផ្នែកបច្ចេកទេស និងការកសាងសមត្ថភាពដល់មជ្ឈមណ្ឌលកម្ចាត់មីនតំបន់អាស៊ាន ។

កិច្ចប្រជុំកំពូលអាស៊ានអ.ស.ប. លើកទី ៦ បានអនុម័តទៅលើផែនការការងារអាស៊ាននិងអ.ស.ប.សម្រាប់ឆ្នាំ២០១៥ដើម្បីដាក់ចេញនូវផែនការអាទិភាព សម្រាប់កិច្ចសហប្រតិបត្តិការរវាងអាស៊ាននឹង អ.ស.ប. ពិសេសធ្វើយ៉ាងណាឲ្យអាស៊ានគ្មានគ្រឿងញៀននៅឆ្នាំ ២០១៥ ។



*សម្ដេចតេជោ **ហ៊ុន សែន** ជួបសម្ដែងការគួរសម និងពិភាក្សាការងារជាមួយ ឯកឧត្ដម **ឌីមីទ្រី ម៉េឌវ៉េដេវ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសហព័ន្ធរុស្ស៊ី*

កិច្ចប្រជុំកំពូលអាស៊ាន អូស្ត្រាលី បានផ្ដោតទៅលើការប្រារព្ធខួបអនុស្សាវរីយ៍លើកទី៤០នៃទំនាក់ទំនងអាស៊ានអូស្ត្រាលី ដោយសារអូស្ត្រាលីជាដៃគូសន្ទនាមានវ័យចំណាស់ជាងគេបំផុត។ កិច្ចប្រជុំបានឯកភាពដំឡើងកម្រិតនៃទំនាក់ទំនងរវាងអាស៊ាន និងអូស្ត្រាលីពីដៃគូពេញលេញទៅជាដៃគូយុទ្ធសាស្ត្រ។ ក្នុងកិច្ចប្រជុំនេះ សម្ដេចតេជោ **ហ៊ុន សែន** បានស្នើឲ្យប្រទេសអូស្ត្រាលីគាំទ្រជាបច្ចេកទេស ហិរញ្ញវត្ថុ និងការកសាងសមត្ថភាពដល់មន្ត្រី ដែលគ្រោងមកធ្វើការនៅមជ្ឈមណ្ឌលកម្ចាត់មីនតំបន់អាស៊ាននេះ។

ក្នុងឱកាសស្នាក់នៅសហភាពមីយ៉ាន់ម៉ាសម្ដេចតេជោ **ហ៊ុន សែន** ក៏បានជួបសន្ទនាដោយឡែកពីគ្នាជាមួយថ្នាក់ដឹកនាំបរទេសជាច្រើនរូប។ ក្នុងឱកាសជួបពិភាក្សាការងារជាមួយឯកឧត្ដម **បាន គីមូន** អគ្គលេខាធិការនៃ អ.ស.ប. សម្ដេចតេជោ **ហ៊ុន សែន** បានបង្ហាញនូវឆន្ទៈក្នុងការដោះស្រាយប្រាក់បៀវត្សរបស់បុគ្គលិកនៃសាលាក្ដីខ្មែរក្រហមភាគីកម្ពុជាសម្រាប់ចុងឆ្នាំ២០១៤។ សម្ដេចតេជោបានបញ្ជាក់ពីការសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការជួយឧបត្ថម្ភថវិកាចំនួន ១ ១៥០ ០០០ ដុល្លារអាមេរិក ក្នុងការដោះស្រាយប្រាក់បៀវត្សជូនដល់បុគ្គលិកនៃសាលាក្ដីខ្មែរក្រហមខាងភាគីកម្ពុជាសម្រាប់ខែតុលា-វិច្ឆិកា និងខែធ្នូ ឆ្នាំ២០១៤។ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តដោះស្រាយប្រាក់បៀវត្ស សម្រាប់បុគ្គលិកភាគីកម្ពុជានៃសាលាក្ដីខ្មែរក្រហមសម្រាប់រយៈពេល ៦ ខែក្នុងឆ្នាំ ២០១៥ ខាងមុខនេះទៀត។ ឯកឧត្ដម **បាន គីមូន** បានថ្លែងអំណរគុណចំពោះសម្ដេចតេជោ **ហ៊ុន សែន** និងរាជរដ្ឋាភិបាលកម្ពុជា ចំពោះការខិតខំដោះស្រាយដល់ការលំបាករបស់បុគ្គលិកនៃសាលាក្ដីខ្មែរក្រហម ប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត។ សម្ដេចតេជោ **ហ៊ុន សែន** ក៏បានជួបពិភាក្សាការងារជាមួយឯកឧត្ដម **ស៊ិន ហ្សូអាបេ** នាយករដ្ឋមន្ត្រីជប៉ុន ដោយភាគីទាំងពីរបានធ្វើការពិភាក្សាគ្នាអំពីការពង្រឹងទំនាក់ទំនងទ្វេភាគី និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យនៃប្រទេសទាំងពីរឲ្យកាន់តែរឹងមាំបន្ថែមទៀត ។ សម្ដេចតេជោបានថ្លែងអំណរគុណដល់ប្រទេសជប៉ុនដែលបានគាំទ្រ និងជួយដល់ការស្ដារ និងអភិវឌ្ឍប្រទេសកម្ពុជា ដោយបានចាត់ទុកថា ការរីកចម្រើនរបស់កម្ពុជានាពេលបច្ចុប្បន្ននេះ គឺមិនអាចកាត់ផ្ដាច់ចេញបានពីការជួយឧបត្ថម្ភគាំទ្ររបស់រាជរដ្ឋាភិបាលជប៉ុន និងប្រជាជនជប៉ុនបានឡើយ ។

សម្ដេចតេជោ **ហ៊ុន សែន** ក៏បានជួបពិភាក្សាការងារទ្វេភាគីជាមួយឯកឧត្ដម **ឌីមីទ្រី ម៉េឌវ៉េដេវ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសហព័ន្ធរុស្ស៊ី ដោយភាគីទាំងពីរបានពិភាក្សាទៅលើបញ្ហាបំណុលដែលកម្ពុជាជំពាក់ក្នុងសម័យក្រោយសង្គ្រាមឆ្នាំ១៩៧៩ ។ ភាគីកម្ពុជាបានស្នើដល់រុស្ស៊ីឲ្យមានការបន្ធូរបន្ថយអត្រាការប្រាក់ ស្របតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងស្របពេលដែលកម្ពុជាកំពុងជួបប្រទះនូវបញ្ហាលំបាកនេះ ។ សម្ដេចតេជោថ្លែងថា សម្ដេចនឹងបញ្ជូនរដ្ឋមន្ត្រីការបរទេស រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅកាន់ប្រទេសរុស្ស៊ីដើម្បីធ្វើការចរចាលើការដោះស្រាយបំណុលដែលកម្ពុជាជំពាក់។ សម្ដេចតេជោ **ហ៊ុន សែន** បានលើកឡើងពីទំនាក់ទំនងដ៏យូរលង់រវាងប្រទេសទាំងពីរ កម្ពុជា-រុស្ស៊ី ដោយសម្ដេចថ្លែងថា ភាពឯករាជ្យរបស់កម្ពុជាដែលមានពីមុនមក ពិសេសក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ គឺមិនអាចផ្ដាច់ចេញបានពីការជួយឧបត្ថម្ភគាំទ្រពីសំណាក់ប្រទេសរុស្ស៊ី ដែលមានតាំងពីយូរលង់ណាស់មកហើយ ពោលគឺចាប់តាំងពីសម័យកាលក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះករុណា **ព្រះបាទ សម្ដេចព្រះនរោត្ដម សីហនុ ព្រះបរមរតនកោដ្ឋ**។ ក្រោយថ្ងៃរំដោះពីរបបប្រល័យពូជសាសន៍ រុស្ស៊ីបានជួយឧបត្ថម្ភគ្រប់បែបយ៉ាងដល់កម្ពុជា ហើយអ្វីដែលសម្ដេចមិនអាចបំភ្លេចបានគឺការជួយដល់ការបណ្ដុះបណ្ដាលធនធានមនុស្ស ដែលបច្ចុប្បន្នអ្នកទាំងនេះកំពុងចូលរួមចំណែកយ៉ាងសកម្មដល់ការដឹកនាំ និងកសាងប្រទេសកម្ពុជា។ ក្នុងនោះ ក្នុងជួរថ្នាក់ដឹកនាំរាជរដ្ឋាភិបាលថ្មីរបស់កម្ពុជាមានរដ្ឋមន្ត្រី ៣ រូប ដែលធ្លាប់បានទទួលការបណ្ដុះបណ្ដាលនៅរុស្ស៊ី។ សម្ដេចតេជោ **ហ៊ុន សែន** ក៏ស្នើឲ្យមានជើងហោះហើរផ្ទាល់ពីម៉ូស្គូមកកម្ពុជា និងពីកម្ពុជាទៅម៉ូស្គូ ព្រោះភ្ញៀវទេសចររុស្ស៊ីកាន់តែមានកំណើនហើយ។ កាលពីអំឡុងទសវត្សឆ្នាំ ១៩៨០ ប្រទេសទាំងពីរក៏ធ្លាប់មានជើងហោះហើរបែបនេះរួចហើយ។ សម្ដេចតេជោក៏ចង់ឃើញការវិនិយោគបន្ថែមទៀតពីសំណាក់ក្រុមហ៊ុនរុស្ស៊ីនៅកម្ពុជា ពិសេសទំហំពាណិជ្ជកម្ម និងវិនិយោគនៃប្រទេសទាំងពីរកំពុងតែមានការកើនឡើង។ ឯកឧត្ដម **ឌីមីទ្រី ម៉េឌវ៉េដេវ** បានថ្លែងថា ប្រទេសយើងទាំងពីរមានទំនាក់ទំនងជាមួយគ្នាល្អណាស់។ តាមរយៈនេះប្រទេសទាំងពីរ គួរសម្លឹងមើលទៅអនាគតឲ្យបានវែងឆ្ងាយដើម្បីប្រយោជន៍យូរអង្វែង ។ ជាមួយនេះ យើងត្រូវធ្វើអ្វីៗដើម្បីពាណិជ្ជកម្ម និងការវិនិយោគសម្រាប់ប្រទេសទាំងពីរ។ ឯកឧត្ដម **ម៉េឌវ៉េដេវ** បានឯកភាពចំពោះសំណើរបស់សម្ដេចតេជោ **ហ៊ុន សែន** ស្ដីពីការរកដំណោះស្រាយចំពោះបញ្ហាស្រាយបំណុលដែលកម្ពុជាជំពាក់ តាមរយៈការបង្កើតគណៈកម្មការនៃប្រទេសទាំងពីរ ដើម្បីជួបគ្នាដោះស្រាយបញ្ហាដែលនៅសេសសល់។ ឯកឧត្ដម **ម៉េឌវ៉េដេវ** បញ្ជាក់ទៀតថា ឯកឧត្ដមយល់ពីការលំបាករបស់កម្ពុជាហើយរុស្ស៊ី និងអនុវត្តទៅតាមស្មារតីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្ដីពីបញ្ហាបំណុល ដែលកម្ពុជាជំពាក់ ។

គណៈប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយសម្ដេចតេជោ **ហ៊ុន សែន** ដែលបានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអាស៊ានលើកទី ២៥ និងកិច្ចប្រជុំពាក់ព័ន្ធនៅសហភាព មីយ៉ាន់ម៉ា បានធ្វើមាតុភូមិនិវត្តន៍ដោយសុវត្ថិភាពនៅពាក់កណ្ដាលអាធ្រាតថ្ងៃទី ១៣ខែវិច្ឆិកា ឆ្នាំ២០១៤៕

# សម្ដេចតេជោ : កិច្ចព្រមព្រៀងថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ មិនមែនជាកិច្ចព្រមព្រៀងបញ្ចប់ដំណើរការរបស់តុលាការក្នុងរឿងក្ដីព្រហ្មទណ្ឌឡើយ





*សម្ដេចតេជោ **ហ៊ុន សែន** ក្នុងឱកាសអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធមន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញក្នុងរាជធានីភ្នំពេញ*

❋ថ្ងៃទី ១៨ ខែវិច្ឆិកាសម្ដេចតេជោ **ហ៊ុន សែន** បានអញ្ជើញចូលរួមសម្ពោធមន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញក្នុងរាជធានីភ្នំពេញ។ ថ្លែងទៅកាន់អ្នកចូលរួមដ៏ច្រើនកុះករសម្ដេចបានធ្វើការកត់សម្គាល់ថា នៅពេលដែលកម្ពុជាមានមន្ទីរពេទ្យដ៏ទំនើបបែបនេះកើតឡើង ក្រៅពីការជួយដល់ប្រជាជនកម្ពុជាក្នុងការស្វែងរកការព្យាបាល កម្ពុជាក៏អាចបង្កើតនូវជំនឿទុកចិត្តថែមទៀតសម្រាប់អ្នកទេសចរ និងអ្នកវិនិយោគឱ្យមកកាន់ព្រះរាជាណាចក្រកម្ពុជា។ សម្ដេចបានរំឭកថានាឆ្នាំ ២០១៣ កម្ពុជាទទួលបានទេសចរចំនួន ៤,២ លាននាក់ ហើយនៅឆ្នាំ ២០១៤ នេះ កម្ពុជារំពឹងថាអាចនឹងទទួលបានទេសចរដល់ ៤,៥ លាននាក់។ សម្រាប់ភ្ញៀវទេសចរដែលមានវ័យចំណាស់ដែលមានការគិតគូពីសុខភាពនោះ មុននឹងមកទស្សនាកម្ពុជាគេក៏ត្រូវដឹងថាតើកម្ពុជាមានកន្លែងព្យាបាលឬកន្លែងសង្គ្រោះសម្រាប់ជំងឺរបស់គេឬអត់? សម្ដេចបានបន្តថា នៅពេលបោះពុម្ពសៀវភៅឃោសនាអំពីទេសចរណ៍មកកាន់កម្ពុជា កុំភ្លេចប្រាប់គេថាកម្ពុជាមានមន្ទីរពេទ្យទំនើបនេះផងដែរដើម្បីឱ្យទេសចរហ៊ានមក ព្រោះអ្នកមានៗនៅបរទេសមុននឹងសម្រេចចិត្តមកធ្វើទេសចរណ៍ ឬមកធ្វើវិនិយោគ គេត្រូវដឹងថាតើនៅកម្ពុជាមានអ្វីខ្លះ? ត្រូវតែជួយឃោសនាដើម្បីនាំទេសចរមកកាន់ទីនេះ ។

គួរបញ្ជាក់ថា មន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញជាមន្ទីរពេទ្យដែលផ្ដល់សេវាវេជ្ជសាស្ត្រកម្រិតឧត្ដម ដែលគ្រប់គ្រងដោយក្រុមហ៊ុនសេវាវេជ្ជសាស្ត្រសាធារណៈបាងកក(ប្រទេសថៃ) ដែលជាប្រតិបត្តិករឯកជននៅក្នុងប្រទេសថៃ និងអាស៊ីអាគ្នេយ៍។ មន្ទីរពេទ្យនេះកសាងឡើងតាមលក្ខណៈស្តង់ដារអន្តរជាតិ ដែលបំពាក់ដោយឧបករណ៍វេជ្ជសាស្ត្រទំនើបៗទាន់សម័យ ជាមួយទឹកប្រាក់វិនិយោគសរុប ៥០ លានដុល្លារអាមេរិក។ ជាមួយនេះ ក៏ផ្ដល់ជូននូវសេវាបញ្ជូនអ្នកជំងឺទាំងផ្លូវគោក និងផ្លូវអាកាស ទៅកាន់ប្រទេសថៃសម្រាប់ការស្វែងរកការព្យាបាលបន្ថែម ។ មន្ទីរពេទ្យនេះមានគ្រូពេទ្យជំនាញសរុប ៤០ នាក់ដែលមកពីកម្ពុជាថៃ អាមេរិក ស្វីស និងបារាំង ។

សម្ដេចតេជោនាយករដ្ឋមន្ត្រីបានសម្ដែងសេចក្ដីសង្ឃឹមថា តាមរយៈមន្ទីរពេទ្យនេះ ចំណេះដឹងទាំងឡាយនឹងត្រូវបានផ្ទេរដល់វេជ្ជបណ្ឌិតរបស់កម្ពុជា និងសង្ឃឹមថានៅពេលមានការវិនិយោគមន្ទីរពេទ្យ មិនថាជារបស់រដ្ឋ ឬឯកជនទេ វានឹងក្លាយជាឱកាសសម្រាប់និស្សិតពេទ្យកម្ពុជាផងដែរ។

សម្ដេចសង្ឃឹមថា អ្នកវិនិយោគថៃនឹងមកវិនិយោគនៅកម្ពុជាបន្ថែមទៀត ។ រំឭកដល់ការជួបប្រាស្រ័យរបស់សម្ដេចជាមួយលោក **ប្រាយុទ្ធ ចាន់អូចា** នាយករដ្ឋមន្ត្រីថៃ នៅប្រទេសមីយ៉ាន់ម៉ាកន្លងទៅ សម្ដេចបានប្រាប់ទៅលោក **ប្រាយុទ្ធ** ថា ប្រទេសកម្ពុជាតូចតែមានកម្លាំងបញ្ចទិញធំណាស់។ ទំហំពាណិជ្ជកម្មប្រទេសទាំងពីរមានរហូតជាង ៤ ពាន់លានដុល្លារអាមេរិក តែកម្ពុជានាំទំនិញទៅថៃមានទឹកប្រាក់ត្រឹមតែជាង ៣០០ លានដុល្លារប៉ុណ្ណោះ។ ចំណែកទេសចរវិញក៏ដូចគ្នាដែរ។ ប្រជាជនកម្ពុជាមានចំនួនតិច តែចំនួនប្រជាជនកម្ពុជាទៅកាន់ប្រទេសថៃមានរហូតដល់ជាង ៤៦ ម៉ឺននាក់ រាប់ទាំងទៅពិនិត្យជំងឺផង ។ ចំណែកប្រជាជនថៃមកកម្ពុជាមានត្រឹមជាង ១៣ ម៉ឺននាក់ប៉ុណ្ណោះ ។

ក្នុងឱកាសនោះ សម្ដេចក៏បានធ្វើការកត់សម្គាល់អំពីតម្លៃនៃឧបករណ៍ពេទ្យទំនើបៗដែលមានតម្លៃខ្ពស់ ក៏ប៉ុន្តែតម្លៃនេះនៅមិនស្មើតម្លៃយន្តហោះចម្បាំងមួយគ្រឿងដែលគេទិញមកសម្រាប់ធ្វើសង្គ្រាមសម្លាប់មនុស្សនោះទេ។ សម្ដេចបានរំឭកថា កាលពីខែដើមខែតុលា ឆ្នាំ២០១៤ អំឡុងពេលដង្ហែព្រះរាជដំណើរព្រះមហាក្សត្រសម្ពោធអគារ សម្រាប់ការវះកាត់ខួរក្បាលនៅក្នុងមន្ទីរពេទ្យកាល់ម៉ែត ពេលនោះរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងប្រធានមន្ទីរពេទ្យ បានបង្ហាញពីបច្ចេកទេសដែលមានលក្ខណៈទាន់សម័យច្រើនណាស់ សម្រាប់ប្រើប្រាស់ក្នុងការព្យាបាលមនុស្ស បើទោះជាវាមានថ្លៃខ្ពស់បន្តិចមែន។ នៅពេលនោះសម្ដេចបានទូលថ្វាយព្រះមហាក្សត្រជាទីសក្ការៈថា បើទោះបីជាឧបករណ៍វេជ្ជសាស្ត្រទំនើបថ្លៃមែនក៏ប៉ុន្តែ វាថ្លៃមិនស្មើទៅនឹងយន្តហោះចម្បាំងមួយគ្រឿងដែលគេហោះសម្រាប់ទម្លាក់សម្លាប់មនុស្សទេ។ អ្វីដែលយើងទិញមកនេះវាថ្លៃមែនប៉ុន្តែសម្រាប់សង្គ្រោះជីវិតមនុស្ស។ សម្ដេចបញ្ជាក់ថាចំណុចវាខុសគ្នានៅកន្លែងហ្នឹង ទើបរាជរដ្ឋាភិបាលបានចំណាយថវិកាទៅលើវិស័យសុខាភិបាល និងវិស័យអប់រំកាន់តែច្រើនទៅៗ ។

❋ព្រឹកថ្ងៃទី ២០ ខែវិច្ឆិកា សម្ដេចតេជោ បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីប្រគល់សញ្ញាបត្រជូននិស្សិតនៃសាកលវិទ្យាល័យ អាយអាយស៊ី IIC នាវិទ្យាស្ថានជាតិអប់រំរាជធានីភ្នំពេញ ។ នៅទីនោះសម្ដេចបានបញ្ជាក់អំពីខ្លឹមសារសំខាន់ៗមួយចំនួនទាក់ទងទៅនឹងកិច្ចព្រមព្រៀងរវាងគណបក្សប្រជាជនកម្ពុជា ជាមួយគណបក្សសង្គ្រោះជាតិថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤។

សម្ដេចបានមានប្រសាសន៍ថា កិច្ចព្រមព្រៀងរវាងគណបក្សនយោបាយទាំងពីរនៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ កន្លងទៅមិនមែនជាកិច្ច



*សម្តេចតេជោ **ហ៊ុន សែន** ប្រគល់សញ្ញាបត្រ ជូននិស្សិតនៃសាកលវិទ្យាល័យ អាយអាយស៊ី*

ព្រមព្រៀងបញ្ចប់ នូវដំណើរការរបស់តុលាការទាក់ទិនរឿងក្តីព្រហ្មទណ្ឌនោះទេហើយនៅក្នុងពិភពលោកនេះក៏គ្មានកិច្ចព្រមព្រៀងនយោបាយណាគ្របដណ្តប់ទៅលើដំណើរការរបស់តុលាការក្នុងរឿងព្រហ្មទណ្ឌដែរ ។

សម្តេចបន្តថា ខ្ញុំជាអ្នកចរចាហើយថ្ងៃចរចានោះមានការស្នើសុំឲ្យនៅក្រៅឃុំ។ ខ្ញុំបានប្រាប់ទៅលោក សម រង្ស៊ី និងគណៈប្រតិភូរបស់គាត់ថា សុំជំរុញល្បឿននៃរដ្ឋប្បវេណីដើម្បីបង្អាក់ព្រហ្មទណ្ឌ។សម្តេចបន្តថា ម៉េចខ្ញុំនិយាយបែបនេះថា ឥឡូវយើងឯកភាពគ្នាហើយថាចូលសភា។ ដូចនេះចូលឲ្យលឿនទៅដើម្បីយកអភ័យឯកសិទ្ធិ។ ហ្នឹងហើយគេហៅថាយករដ្ឋប្បវេណីដើម្បីបង្អាក់ព្រហ្មទណ្ឌ។ ករណីលោក កឹម សុខា ផ្ទាល់ខ្ញុំប្រាប់ថាលោកមានជម្រើសពីរ។ ជម្រើសទី១ចូលសភាស្បថបានរហ័សគឺវារួចខ្លួន និងជម្រើសទី ២ គឺសុំពន្យារពេលចូលតុលាការ ព្រោះតុលាការកោះហៅដែរ។ អញ្ចឹងពេលនោះយើងបានប្រឹងប្រែងបានត្រឹមធានាឲ្យនៅក្រៅឃុំប៉ុណ្ណោះ មិនអាចបញ្ចប់រឿងក្តីនេះបានទេ ។

សម្តេចបានបន្តថា ខ្ញុំបានប្រាប់ឯកឧត្តម សម រង្ស៊ី យ៉ាងច្បាស់នៅក្នុងសភាអំពីករណីចាប់ខ្លួនអ្នកណាម្នាក់នោះ ព្រោះថាប៉ូលីសនិងតុលាការគេធ្វើកោសល្យវិច័យទៅលើរូបភាព ។ ខ្ញុំបានប្រាប់គាត់ថារឿងនេះខ្ញុំមិនអាចធ្វើអ្វីបានទេ។ ដំណើរការមានតែទៅតាមក្រឹត្យក្រមរបស់វា។ប្រសិនជាមិនអាចសុំនៅក្រៅឃុំបានទេ គឺសុំប្តឹងទៅឧទ្ធរណ៍។ ករណីក្រុមប្រឹក្សាសង្កាត់ច្បារអំពៅ ខ្ញុំប្រាប់គាត់ទៀតថា ខ្ញុំមិនអាចធ្វើអ្វីកើតទេ ប្រសិនគេឲ្យនៅក្រៅឃុំជាសំណាងហើយ តែប្រសិនជាគេមិនអនុញ្ញាតឲ្យនៅក្រៅឃុំហើយកាត់ទោសយកល្អសុំលោកកុំប្តឹងឧទ្ធរណ៍ ដើម្បីទុកឲ្យសាលក្រមចូលជាស្ថាពរដល់សាលក្រមចូលជាស្ថាពរ ហើយខ្ញុំមានឱកាសអនុវត្តច្បាប់ពន្ធនាគារដែលអនុញ្ញាតឲ្យនាយករដ្ឋមន្ត្រីសុំព្រះរាជទានទោសបាន ។

សម្តេចបន្តថា ឥឡូវមកចោទថារាជរដ្ឋាភិបាលប្រើប្រាស់ឧបករណ៍ដើម្បីបង្ក្រាបបក្សប្រឆាំង ឬចាប់គេមកធ្វើចំណាប់ខ្មាំង។ សម្តេចសូមផ្តាំត្រឡប់ទៅវិញ ដោយសារតែនាយករដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាលគ្មានសិទ្ធិទៅលើតុលាការហ្នឹងហើយទើបមានរឿងបែបនេះ។នាយករដ្ឋមន្ត្រីចង់ការពារបរិយាកាសសុខស្រួល មិនមែនចង់ឲ្យមានរឿងទេ ព្រោះយើងត្រូវការបរិយាកាសសុខសន្តិភាព និងការបង្រួបបង្រួមជាតិ ដើម្បីអភិវឌ្ឍប្រទេស។ ដោយសារតែនាយករដ្ឋមន្ត្រី ឬរាជរដ្ឋាភិបាលវាគ្មានសិទ្ធិទើបបានជាមានការចាប់ខ្លួនបែបនេះ។ បើសម្តេចមានសិទ្ធិ សម្តេចបញ្ជាទៅតុលាការដោះលែងថ្ងៃនេះក៏បាន តែវាគ្មានសិទ្ធិ ។

សម្តេចបន្តថា ឯកឧត្តម សម រង្ស៊ី សរសេរលិខិតមកឯកឧត្តម **ស ខេង** ។ ឯកឧត្តម **ស ខេង** សរសេរទៅ ឯកឧត្តម **អង្គ វង្សវឌ្ឍនា** ។ ឯកឧត្តម **អង្គ វង្សវឌ្ឍនា** ឆ្លើយទៅវិញថា ជានីតិវិធីតុលាការ។ អ៊ីចឹងសូមបញ្ជាក់ទៅវិញកិច្ចព្រមព្រៀងរវាងគណបក្សនយោបាយទាំងពីរ នៅថ្ងៃ ២២ ខែកក្កដា ២០១៤ មិនមែនជាកិច្ចព្រមព្រៀងពន្លត់បណ្តឹងអាជ្ញានោះទេ ។ ឥឡូវគ្រាន់តែសមាជិកសភាមានអភ័យឯកសិទ្ធិ តែនៅពេលអស់អភ័យឯកសិទ្ធិ គេយកទៅកាត់ទោសដដែលហ្នឹង។ សុំកុំភ័ន្តច្រឡំសូមមើលឡើងវិញទៅ ហើយបើខ្វះឯកសារជាសម្តីសម្តេចមាន។ ទាំងឯកសារជាសម្តី ខ្សែអាត់ និងលាយលក្ខណ៍អក្សរ។ គេចេញមកស្រែកថារំលោភកិច្ចព្រមព្រៀង។ អត់មានទេ ។ កិច្ចព្រមព្រៀងអត់មាននិយាយបែបនេះទេ។ សម្តេចជាអ្នកចរចាផ្ទាល់។

សម្តេចបានបញ្ជាក់ថា ទោះជាយ៉ាងណាបញ្ហានេះមិនធ្វើឲ្យរាំងស្ទះដល់ការចរចាធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងសភា និងការចាត់តាំងនិងប្រព្រឹត្តិទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនោះដែរ ។ រឿងនេះយកល្អកុំចាក់សាំងលើភ្លើង ។ វាមិនល្អទេ ។ ដំណើរការអ្វីត្រូវឲ្យវាទៅតាមច្បាប់ ។ ទន្ទឹមប្រជាធិបតេយ្យ ក៏ត្រូវពង្រឹងនីតិរដ្ឋផងដែរ។ មិនអាចយោគយល់ និងមិនអាចអត់អោនឲ្យបានដែរ។ អារឿងអីឡើងបិទផ្លូវ ដល់ពេលវេលាដែលអាជ្ញាធរត្រូវធ្វើហើយ ។ រឿងអីក៏នយោបាយៗ ។ រឿងព្រហ្មទណ្ឌក៏ទៅជារឿងនយោបាយ។ បើអញ្ចឹងឲ្យតុលាការធ្វើទៅតាមច្បាប់តែម្តងទៅ ។

គួររំលឹកថា គណបក្សសង្គ្រោះជាតិបានបញ្ចេញប្រតិកម្មរបស់ខ្លួនតាមរយៈសេចក្តីថ្លែងការណ៍ និងបណ្តាញប្រព័ន្ធផ្សព្វផ្សាយសង្គមមួយចំនួនបានចោទប្រកាន់មកលើគណបក្សប្រជាជនកម្ពុជាថា បានរំលោភលើស្មារតីនៃកិច្ចព្រមព្រៀងនយោបាយថ្ងៃទី២២ខែកក្កដាឆ្នាំ២០១៤អំពីករណីនៃការចាប់ឃុំខ្លួន លោក មាជ សុវណ្ណារ៉ា មន្ត្រីជាន់ខ្ពស់របស់គណបក្សសង្គ្រោះជាតិកាលពីថ្ងៃទី១១ ខែវិច្ឆិកាកន្លងទៅនេះ។ ការចាប់ខ្លួនលោក មាជ សុវណ្ណារ៉ា គឺអនុវត្តតាមដីការបស់សាលាដំបូងរាជធានីភ្នំពេញ ពីបទដឹកនាំកុប្បកម្ម ញុះញង់ឲ្យប្រព្រឹត្តបទល្មើស ផ្តើមគំនិតក្នុងអំពើហិង្សាដោយចេតនា មានស្ថានទម្ងន់ទោស ដែលលោកបានប្រព្រឹត្តនៅទីលានប្រជាធិបតេយ្យកាលពី ថ្ងៃ ១៥ ខែតុលា ឆ្នាំ ២០១៤ ។

យោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២៨ ចែងថា អ្នកផ្តើមគំនិតបានជំរុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិម តាមការណែនាំ ឬការបញ្ជាអាចនឹងត្រូវផ្តន្ទាទោស ។ មាត្រា៤៥៩ ចែងថា បទដឹកនាំកុប្បកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២០ឆ្នាំដល់៣០ឆ្នាំ។មាត្រា៤៩៥ ចែងថា អំពើញុះញង់ដោយផ្ទាល់ ឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គមតាមមធ្យោបាយណាមួយក្នុងមាត្រា៤៩៤វាក្យខណ្ឌទី១ចែងពីលក្ខខណ្ឌអត្ថិភាពនៃការញុះញង់អាចត្រូវផ្តន្ទាទោសកាលបើអំពើនោះត្រូវបានប្រព្រឹត្តដោយពាក្យសម្តីតាមប្រភេទណាមួយក៏ដោយ ដែលប្រកាសនៅទីសាធារណៈ ឬនៅក្នុងពេលប្រជុំជាសាធារណៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ ២ ឆ្នាំ និងពិន័យជាប្រាក់មួយលានរៀល ទៅបួនលានរៀល ប្រសិនបើការញុះញង់នេះគ្មានប្រសិទ្ធភាពទេ និងមាត្រា ២១៨ ស្ថានទម្ងន់ទោសចែងថា អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ ឆ្នាំ ដល់ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ៤ លានរៀល ទៅ ១០ លានរៀល កាលបើអំពើនេះបានប្រព្រឹត្តដោយមានការគិតទុកជាមុន ៕

# សម្ដេចចក្រី ហេង សំរិន អញ្ជើញជាអធិបតីបើកសិក្ខាសាលា ពិគ្រោះយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥



*សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ថ្លែងសុន្ទរកថាបើកសិក្ខាសាលា*

ព្រឹកថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ នៅវិមានរដ្ឋសភា សម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ បើកសិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងច្បាប់ ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥។ សិក្ខាសាលានេះមានការចូលរួមពីសំណាក់សមាជិករដ្ឋសភា ព្រឹទ្ធសភា និងតំណាងអង្គការអន្តរជាតិជាដៃគូ ប្រមាណ ២០០ នាក់ចូលរួមពិភាក្សា។

ថ្លែងទៅកាន់សិក្ខាសាលានាឱកាសនោះ សម្ដេចចក្រី **ហេង សំរិន** បានលើកឡើងថា បច្ចុប្បន្នកម្ពុជាមានកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណ ៧% ក្នុងមួយឆ្នាំ និងបានធ្វើឱ្យផលិតផលសរុបសម្រាប់មនុស្សម្នាក់ទទួលបាន ១.១៣០ ដុល្លារ ក្នុងឆ្នាំ ២០១៤ និងអាចកើនឡើងដល់ ១.២២៥ ដុល្លារអាមេរិកក្នុងឆ្នាំ ២០១៥ ដែលប្រការនេះអាចឱ្យកម្ពុជាឈានដល់ដំណាក់កាលនៃការអភិវឌ្ឍថ្មីមួយ គឺកំពុងឈានទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ។

សម្ដេចប្រធានរដ្ឋសភាបញ្ជាក់ថា យើងពិតជាមានមោទនភាព និងត្រេកអរយ៉ាងខ្លាំងចំពោះកំណើនសេដ្ឋកិច្ចរបស់យើងក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ទោះបីជាកម្ពុជាជួបប្រទះនូវបញ្ហាប្រឈម និងហានិភ័យក្ដី ក៏កំណើនសេដ្ឋកិច្ចកម្ពុជាស្ថិតក្នុងលក្ខណៈជាកំណើនមួយដែលមានភាពរឹងមាំ និងជឿជាក់។ សម្ដេចក៏បានរំឭកថា បើទោះបីជាសេដ្ឋកិច្ចកម្ពុជាយើងទទួលបានកំណើនខ្ពស់គួរឱ្យកត់សម្គាល់ក៏ដោយ ក៏យើងមិនត្រូវមានសុទិដ្ឋិនិយមពេកទេ ពីព្រោះកំណើននេះហាក់ដូចជាស្ថិតនៅក្នុងរយៈពេលខ្លី និងមធ្យមប៉ុណ្ណោះ ដែលទាមទារឱ្យយើងទាំងអស់គ្នាជាពិសេសស្ថាប័នពាក់ព័ន្ធគ្រប់ជាន់ថ្នាក់ ត្រូវបន្តពង្រឹងពង្រីកនូវសក្ដានុពលរបស់ខ្លួនថែមទៀត ពិសេសពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជា ដើម្បីធានាថាកំណើននេះត្រូវបានបែងចែកដល់ពលរដ្ឋភាគច្រើនក្នុងសង្គម ពិសេសប្រជាពលរដ្ឋនៅទីជនបទ សំដៅឈានទៅកាត់បន្ថយភាពក្រីក្រឱ្យបានជាអតិបរមា ។

ឯកឧត្ដម **ជាម យៀប** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភាបានឲ្យដឹងថា សេចក្ដីព្រាងច្បាប់ ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៥ ឬច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥ត្រូវបានរាជរដ្ឋាភិបាល បញ្ជូនទៅកាន់រដ្ឋសភា កាលពីថ្ងៃ ទី ២៧ ខែតុលាឆ្នាំ ២០១៤ ។ សេចក្ដីព្រាងច្បាប់ថវិកាជាតិ ឆ្នាំ ២០១៥ បានកំណត់ការចំណាយថវិការដ្ឋ សរុបចំនួន ១៥.៦៩៩.៥២៩ លានរៀល ស្មើប្រមាណ ៣.៨៤៨ លានដុល្លារ ត្រូវ ជា ២១,០៩% នៃ ផ.ស.ស. និងមានកំណើន ១០,៨ ភាគរយ ធៀបនឹងច្បាប់ស្ដីពីហិរញ្ញវត្ថុឆ្នាំ ២០១៤ ។ សេចក្ដីព្រាងច្បាប់នេះមាន ៦ ជំពូក និង ១៧ មាត្រា ៕



*ឯកឧត្ដម **ជាម យៀប** គូសបញ្ជាក់អំពីសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៥*





*សមាជិករដ្ឋសភា ព្រឹទ្ធសភា និងតំណាងអង្គការអន្តរជាតិជាដៃគូប្រមាណ ២០០ នាក់ ចូលរួមពិភាក្សាក្នុងសិក្ខាសាលា*

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស





ថ្ងៃទី១០ ខែវិច្ឆិកា ឯកឧត្តម **កែ គឹមយ៉ាន** ឧបនាយករដ្ឋមន្ត្រី សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ប្រធានអាជ្ញាធរជាតិប្រយុទ្ធគ្រឿងញៀន បានអញ្ជើញចូលរួមបិទពិធីបុណ្យអុំទូកនៅក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។នៅពេលសំណេះសំណាលជាមួយប្រជាពលរដ្ឋនិងកីឡាករទូករាប់ម៉ឺននាក់ ឯកឧត្តមបានអរគុណចំពោះពុទ្ធបរិស័ទ និងសប្បុរសជនជិតឆ្ងាយក្នុងអំឡុងបុណ្យវេនកាន់បិណ្ឌ ភ្ជុំបិណ្ឌ និងបុណ្យកឋិនទានឆ្នាំនេះប្រមូលបានតាមវត្តទូទាំងខេត្តបន្ទាយមានជ័យបានដល់ជិត ៦.០០០ លានរៀល។



ថ្មីៗនេះ នៅក្នុងបរិវេណវត្តប្រជុំសាគរ ក្នុងសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយ-ចង្វា រាជធានីភ្នំពេញ ឯកឧត្តមបណ្ឌិត **ឃួន ញ៉ុល** អនុប្រធានទី ២ រដ្ឋសភា សមា-ជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខ និងនាំយកថវិកា ស្បៀងអាហារ ថ្នាំពេទ្យចែកជូនដល់ កីឡាករអុំទូកចំនួនបីរបស់ឯកឧត្តម បណ្ឌិត គឺទូក សែនសិរីមានជ័យវត្តសែនសិរីសង្កាត់ស្រយ៉ូវក្រុងស្ទឹងសែន ទូកស្ទឹងសែនមានជ័យវត្តស្លែង ទូកតេជោសែនជ័យ វត្តដួងសូរិយាហៅវត្តក្ដីដូង ស្ថិតក្នុងឃុំក្ដីដូង ស្រុកកំពង់ស្វាយ ដែលត្រូវចូលរួមក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក សំពះព្រះខែនៅរាជធានីភ្នំពេញដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី៥.៦.៧ ខែវិច្ឆិកា ឆ្នាំ២០១៤ ។

*ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ អញ្ជើញចូលរួមដោយ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រីសមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសទទួលស្គាល់សាខាគណៈកម្មការសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ចំនួន ៣២ រូប និងសមា-ជិកចំនួន ២៦៣ រូប នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអង្គភាពរដ្ឋាករទឹកស្វយ័តភ្នំពេញ ។ ក្នុងឱកាសនោះ លោកជំទាវ **ម៉ែន សំអន** បានគូសបញ្ជាក់ថា នារីដើរតួនាទីយ៉ាងសំខាន់និងសកម្មបំផុតក្នុងការងារអភិវឌ្ឍស្ត្រីរួមមាន ការបង្កើតតំបន់អភិ-វឌ្ឍស្ត្រីខ្មែរជាច្រើន ដើម្បីបណ្ដុះបណ្ដាលមុខជំនាញវិជ្ជាជីវៈ ការផ្ដល់កិច្ចគាំពារ និងថែទាំសុខភាព ការជួយដោះស្រាយទុក្ខលំបាកផ្សេងៗទៀតដល់ស្ត្រីទីទាល់ក្រ និងងាយរងគ្រោះ ។*



*ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកឧត្តម **ជា ចាន់តូ** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី១ក្រុមការងារថ្នាក់ជាតិចុះជួយខេត្តកំពង់ធំ និងជាប្រធានក្រុមការងារចុះជួយស្រុកស្ទោង ខេត្តកំពង់ធំ បានអញ្ជើញចូលបើកបវេសនកាលឆ្នាំសិក្សា ២០១៤-២០១៥ នៅវិទ្យាល័យរស្មីសោភ័ណ្ឌ ស្រុកស្ទោង ខេត្តកំពង់ធំ និងសម្ពោធដាក់ឲ្យប្រើប្រាស់នូវអគារសិក្សាថ្មីចំនួន ៣ ខ្នង ក្នុងនោះពីរខ្នងជាថ្នាក់រៀនស្មើ១០បន្ទប់ និងមួយខ្នងទៀតជាអគារសម្រាប់ប្រជុំ។*

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី ១៥ ខែវិច្ឆិកា ឯកឧត្តម **ខង សូត** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទាបានអញ្ជើញចូលរួមសម្ពោធអគារសិក្សាមួយខ្នងមានប្រាំបន្ទប់ មានតុ កៅអី ក្ដារខៀន បង្គន់អនាម័យនិងអណ្ដូងស្នប់ខ្នាតធំមួយ ដែលជាជំនួយរបស់អង្គការសមាគមជំនួយខ្មែរសតវត្សទី ២១ នៅភូមិអំពិលឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ។





*ថ្ងៃទី ១៧ ខែវិច្ឆិកា ឯកឧត្តមនាយឧត្តមសេនីយ៍ **ខ្វាន់ ស៊ាម** សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា អគ្គមេបញ្ជាការរងមេបញ្ជាការកងកម្លាំងវិស្វកម្ម អគ្គបញ្ជាការនៃកងយោធពលខេមរភូមិន្ទ បានដឹកនាំគណៈប្រតិភូជំនាញវិស្វកម្មអគ្គបញ្ជាការ ចុះត្រួតពិនិត្យស្ថានភាពផ្លូវជាតិលេខ ៤៨ ចាប់ពីផ្លូវបំបែកពីផ្លូវជាតិលេខ ៤ ត្រង់ស្រែអំបិលទៅខេត្តកោះកុង ខណៈដែលពេលនេះកំពុងជំរុញការជួសជុលឲ្យទាន់មុនពិធីបុណ្យសមុទ្រ ដែលនឹងប្រារព្ធឡើងនៅខេត្តកោះកុង។*



ថ្ងៃទី ៣ ខែវិច្ឆិកា ឯកឧត្តម **ឈិត សុខុន** សមាជិកគណៈកម្មាធិការ កណ្ដាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ បានអញ្ជើញជួបសំណេះសំណាល និងប្រគល់ប័ណ្ណកម្មសិទ្ធិសំគាល់អចលនវត្ថុជូនប្រជាពលរដ្ឋនៅភូមិ ៣ និងភូមិ ៤ ចំនួន ៧៧៨ គ្រួសារនៅឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។



*ថ្ងៃទី១១-១២ ខែវិច្ឆិកាឆ្នាំ ២០១៤ ឯកឧត្តម **ម៉ម ប៊ុននាង** អនុប្រធានគណៈកម្មការទី១០ នៃព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំស្ដីពីការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ និងការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ និងជួបពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ខេត្ត អង្គការសង្គមស៊ីវិល និងក្រុមជនបង្គោលប្រឆាំងអំពើពុករលួយ ដែលប្រព្រឹត្តទៅនៅក្នុងសាលាខេត្តកណ្ដាល និងសាលាខេត្តកំពង់ស្ពឺ។*





នៅព្រឹកថ្ងៃទី ២១ វិច្ឆិកា ឆ្នាំ ២០១៤ នៅការិយាល័យអ្នកតំណាងរាស្ត្រ ខេត្តព្រះវិហារ ឯកឧត្តម **សួស យ៉ារ៉ា** តំណាងរាស្ត្រ មណ្ឌលព្រះវិហារ បានជួបសំណេះសំណាល សួរសុខទុក្ខ ក្រុមប្រឹក្សាសង្កាត់ តំណាងប្រជាពលរដ្ឋដែលមកពីសង្កាត់កំពង់ប្រណាក សង្កាត់ប៉ាលហាល តំណាងប្រជាពលរដ្ឋឃុំស្រយ៉ង់ ក្នុងក្រុង ព្រះវិហារ និងតំណាងសិស្សានុសិស្សមកពីវិទ្យាល័យ **ជា ស៊ីម** ត្បែងមានជ័យ និងមានផ្ដល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រម ៨ ជំនាញ នៅវិទ្យាស្ថានជាតិសង្គមកិច្ច ដល់សិស្ស និស្សិតដែលទើបប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ ចំនួន ៣០ នាក់ ៕

# ព្រឹត្តិការណ៍សំខាន់ៗក្នុងខែ វិច្ឆិកា





*ថ្ងៃទី៩វិច្ឆិកាខួបអនុស្សាវរីយ៍លើកទី ៦១ ថ្ងៃបុណ្យឯករាជ្យជាតិ (០៩.១១.១៩៥៣-០៩.១១.២០១៤) ប្រព្រឹត្តទៅយ៉ាងឧឡារិកនៅវិមានឯករាជ្យ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះករុណាព្រះបាទ **សម្ដេចព្រះ បរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា*

❋ថ្ងៃទី ១ វិច្ឆិកា ស្ពានជ្រោយចង្វាទី ២ ដែលស្ថាបនាឡើងក្រោមប្រាក់កម្ចីសម្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន បានបើកឱ្យដំណើរការជាបណ្ដោះអាសន្នដើម្បីបញ្ចៀសការកកស្ទះចរាចរក្នុងរាជធានីភ្នំពេញ ពិសេសក្នុងឱកាសនៃព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប អកអំបុក និងសំពះព្រះខែ។

❋ថ្ងៃទី៣វិច្ឆិការដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបើកសម័យប្រជុំលើកទី៣ នីតិកាលទី៥ ក្រោមអធិបតីភាពសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងមានការចូលរួមរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការបោះឆ្នោតជ្រើសតាំងឯកឧត្តម **អ៊ុត រ៉ាឌី** អតីតភាពជាចៅក្រម ជាសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមសម្រាប់អាណត្តិ ៥ ឆ្នាំលើកទី ១ ។

❋ថ្ងៃទី ៣ វិច្ឆិកា ក្រុមអ្នកជំនាញខាងបរិស្ថានមកពីប្រទេសជាសមាជិកអនុសញ្ញារ៉ាំសារ (Ramsar) ចំនួន៣៣ប្រទេសបានជួបប្រជុំគ្នានៅក្នុងសណ្ឋាគារអប្សរាអង្គរ នាទីក្រុងសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងពិភាក្សាគ្នាអំពីការគ្រប់គ្រងការអភិរក្ស និងអភិវឌ្ឍន៍តំបន់ដីសើមប្រកបដោយចីរភាព ។ កិច្ចប្រជុំនេះប្រព្រឹត្តទៅក្រោមអធិបតីភាពឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន ។

❋ថ្ងៃទី ៦ វិច្ឆិកា ក្នុងសារលិខិតជូនជនរួមជាតិក្នុងទិវាជាតិអាហារូបត្ថម្ភលើកទី ១ សម្ដេចតេជោ **ហ៊ុន សែន** មានប្រសាសន៍ថាការប្រារព្ធទិវានេះគឺមានគោលបំណងដើម្បីលើកកម្ពស់ការយល់ដឹងពីអាហារូបត្ថម្ភនៅទូទាំងប្រទេស ស្របគ្នាជាមួយទិវាយល់ដឹងអាហារូបត្ថម្ភពិភពលោក ហើយទិវានេះគឺឆ្លើយតបទៅនឹងការប្រកាសរបស់ពិភពលោកដែលបានបញ្ជាក់ថាសន្តិសុខស្បៀង និងអាហារូបត្ថម្ភត្រូវបានពិភពលោកទទួលស្គាល់ និងចាត់ទុកថាជាសិទ្ធិមូលដ្ឋានរបស់បុគ្គលម្នាក់ៗ ។

❋ថ្ងៃទី៥-៧ វិច្ឆិកាព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប សំពះព្រះខែ និងអកអំបុកបានប្រព្រឹត្តទៅដោយជោគជ័យនៅរាជធានីភ្នំពេញ ។

❋ថ្ងៃទី៩វិច្ឆិកាខួបអនុស្សាវរីយ៍លើកទី ៦១ ថ្ងៃបុណ្យឯករាជ្យជាតិ (០៩.១១.១៩៥៣-០៩.១១.២០១៤) បានប្រព្រឹត្តទៅយ៉ាងឧឡារិកនៅវិមានឯករាជ្យ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះករុណាព្រះបាទ **សម្ដេចព្រះ បរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងមានការអញ្ជើញចូលរួមពីសំណាក់សម្ដេចចក្រី **ហេង សំរិន** ថ្នាក់ដឹកនាំព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល នាម៉ឺនសព្វមុខមន្ត្រី ព្រះរាជវង្សានុវង្ស អង្គទូត និងតំណាងស្ថានទូតនានាប្រទេសជាមិត្តប្រចាំកម្ពុជា ព្រមទាំងសិស្ស និស្សិត លោកគ្រូ អ្នកគ្រូនិងប្រជាពលរដ្ឋយ៉ាងច្រើនកុះករ ។

❋ថ្ងៃទី ៩ វិច្ឆិកា គណៈប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយ សម្ដេចតេជោ **ហ៊ុន សែន** និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** បានធ្វើមាតុភូមិនិវត្តន៍បន្ទាប់ពីបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ កិច្ចសន្ទនាដើម្បីពង្រឹងភាពជាដៃគូនៃការតភ្ជាប់ និងកិច្ចប្រជុំកំពូលនាយកប្រតិបត្តិនៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិកឆ្នាំ២០១៤ (APEC CEO Summit 2014) នៅទីក្រុងប៉េកាំង ។

❋ថ្ងៃទី ១២ ខែ វិច្ឆិកា រាជរដ្ឋាភិបាលបានសម្រេចដំឡើងប្រាក់ឈ្នួលអប្បបរមារបស់កម្មករ និយោជិត ផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងចំនួន ១២៨ ដុល្លារ សម្រាប់អនុវត្តចាប់ពីខែមករា ឆ្នាំ២០១៥ ខាងមុខនេះ ។ ទន្ទឹមនឹងការសម្រេចដំឡើងប្រាក់ខែនេះ ប្រាក់អត្ថប្រយោជន៍ផ្សេងៗទៀតដែលកម្មករធ្លាប់បានទទួលកន្លងមកត្រូវរក្សាទុកដដែល ។ ដូច្នេះជាមធ្យមកម្មករ និយោជិតម្នាក់នឹងទទួលបានប្រាក់បៀវត្សរ៍យ៉ាងតិច ១៤៧ ដុល្លារ ទៅ ១៥៦ ដុល្លារ ក្នុងមួយខែ ។

❋ថ្ងៃទី១៤ វិច្ឆិកា នៅក្រសួងអភិវឌ្ឍន៍ជនបទ គណៈកម្មការអន្តរក្រសួងបានបើកកិច្ចប្រជុំដើម្បីរៀបចំអនុវត្តន៍គម្រោងអភិវឌ្ឍន៍នៅតាមបណ្ដោយព្រំដែនទិសខាងលិច និងខាងជើងនៃព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងតំណាងមន្ត្រីជាសមាជិកមកពីបណ្ដាក្រសួងស្ថាប័នពាក់ព័ន្ធជាច្រើនទៀត ។

❋ថ្ងៃទី១៧វិច្ឆិកា នៅទីស្ដីការក្រសួងការបរទេស ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងឯក ឧត្តម YUJI KUMAMARU ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលជប៉ុនចំនួន ២៥១ លានយ៉េន ប្រហាក់ប្រហែល ២.៣១ លានដុល្លារអាមេរិក ដើម្បីកែលម្អបន្ថែមកំណាត់ទីប្រជុំជនផ្លូវជាតិលេខ ១ ក្បែរស្ពានព្រះមុនីវង្ស ។

❋ថ្ងៃទី១៨ វិច្ឆិកា ថ្លែងក្នុងសិក្ខាសាលាការដឹកជញ្ជូនភ័ស្តុភារកម្ម និងការដឹកជញ្ជូនពហុរូបភាព នៅរាជធានីភ្នំពេញ ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន បានមានប្រសាសន៍ឲ្យដឹងថា ចាប់ពីពេលនេះទៅរាជរដ្ឋាភិបាលកម្ពុជាចាប់ផ្ដើមសិក្សាឈានទៅអភិវឌ្ឍន៍លើមធ្យោបាយដឹកជញ្ជូននៅកម្ពុជា ដើម្បីបម្រើវិស័យពាណិជ្ជកម្មសម្រាប់ទំនាក់ទំនងក្នុងស្រុក និងជាមួយបណ្ដាប្រទេសក្នុងតំបន់ ។

❋ថ្ងៃទី២០ វិច្ឆិកា ក្នុងឱកាសអញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីចែកសញ្ញាប័ត្រឲ្យសិស្ស និស្សិតពុទ្ធសាកលវិទ្យាល័យIICសម្ដេចតេជោ **ហ៊ុនសែន** បានបង្ហាញនូវក្ដីរីករាយ និងមានមោទនភាពបំផុតចំពោះកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ ។ សម្ដេចបានថ្លែងថា បើយោងតាមរបាយការណ៍ស្រាវជ្រាវថ្មីៗនេះបានឲ្យដឹងថា រយៈពេល២០ឆ្នាំជាប់ៗគ្នាចុងក្រោយនេះ កំណើនសេដ្ឋកិច្ចកម្ពុជាថេរហើយបានធ្លាក់ចុះតែមួយឆ្នាំគត់មកដល់ ០.១% កាលពីឆ្នាំ២០០៩ នៅពេលមានវិបត្តហិរញ្ញវត្ថុសាកល ។ ក្នុងឱកាសនោះដែរ សម្ដេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍ថា កិច្ចព្រមព្រៀងរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ មិនមែនជាកិច្ចព្រមព្រៀងបញ្ចប់រឿងក្ដីនៅតុលាការទេ ហើយក៏មិនមែនជាកិច្ចព្រមព្រៀងដើម្បីរំលត់បណ្ដឹងអាជ្ញានោះដែរ សូមកុំមានការភាន់ច្រឡំ ។ ..លើពិភពលោកនេះអត់មានកិច្ចព្រមព្រៀងនយោបាយណាគ្របដណ្ដប់លើដំណើរការរបស់តុលាការ ក្នុងរឿងព្រហ្មទណ្ឌឡើយ ។

❋ថ្ងៃទី ២០ វិច្ឆិកា នៅក្នុងជំនួបពិភាក្សាការងារជាមួយឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅទីស្ដីការក្រសួង លោកស្រី **សាន់ ត្រាម៉ូឡាស្ដី** អគ្គនាយករងទទួលបន្ទុកផ្នែកគោលនយោបាយរបស់អង្គការអន្តរជាតិខាងការងារ (ILO) បានសម្ដែងនូវការកោតសរសើរ និងអបអរសាទរ និងគាំទ្រដល់ដំណោះស្រាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្ដល់ប្រាក់ឈ្នួលអប្បបរមាដល់កម្មករផ្នែកវាយនភ័ណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង សម្រាប់ឆ្នាំ ២០១៥ ខាងមុខ ។

❋ថ្ងៃទី ២០ វិច្ឆិកា នៅក្នុងសន្និសីទអង្ករពិភពលោក នាសណ្ឋាគារសូហ្វីតែល ភូគីត្រាភ្នំពេញអង្គរក្រអូប ផ្ការំដួល របស់កម្ពុជាបានទទួលពានរង្វាន់អង្ករល្អជាងគេរបស់ពិភពលោកThe Best Rice ក្នុងចំណោមអង្ករល្អទាំង ៧ លើពិភពលោក រួមមាន កម្ពុជា វៀតណាម ថៃ បាគីស្ថាន ឥណ្ឌា អាមេរិក និងភូមា ។ នៅក្នុងសន្និសីទនេះ មានក្រុមហ៊ុនអង្ករចំនួន ៥០០ មកពី ៣៧ ប្រទេសបានចូលរួម។ គួរបញ្ជាក់ថា នេះជាលើកទី ៣ ដែលអង្ករ ផ្ការំដួល របស់កម្ពុជាបានទទួលជ័យលាភី បន្ទាប់ពីបានទទួលនាឆ្នាំ ២០១២ នៅទីក្រុងបាលី ប្រទេសឥណ្ឌូនេស៊ី និងឆ្នាំ ២០១៣ នៅទីក្រុងហុងកុង ។

❋ថ្ងៃទី២២ វិច្ឆិកា ឯកឧត្តមទេសរដ្ឋមន្ត្រី **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មមានប្រសាសន៍នៅក្នុងកម្មវិធីសប្ដាហ៍សហគ្រិនភាពពិភពលោកកម្ពុជាថា បច្ចុប្បន្ននេះ ក្រសួងពាណិជ្ជកម្មបាន និងកំពុងធ្វើការកំណែទម្រង់មួយចំនួន ដើម្បីត្រៀមខ្លួនប្រកួតប្រជែងជាមួយប្រទេសអាស៊ានផ្សេងៗទៀត នៅពេលធ្វើសមាហរណកម្មអាស៊ាន ដែលចូលមកដល់នាឆ្នាំ ២០១៥ខាងមុខនេះ ។

❋ថ្ងៃទី ២៣ វិច្ឆិកា តបតាមការអញ្ជើញរបស់ឯកឧត្តម Thongsing THAMMAVONG នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ចាកចេញពីកម្ពុជាតាមជើងយន្តហោះពិសេស ដើម្បីទៅចូលរួមកិច្ចប្រជុំកំពូល កម្ពុជា-ឡាវ-វៀតណាម (C.L.V) លើកទី ៨ ដើម្បីអភិវឌ្ឍន៍តំបន់ត្រីកោណ ដែលប្រព្រឹត្តទៅពីថ្ងៃទី២៤ដល់២៥ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅទីក្រុងវៀងច័ន្ទ ។

# លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

**ចំណូលពន្ធដារខែតុលា :**

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឲ្យដឹងថា នៅក្នុងខែតុលា ឆ្នាំ ២០១៤ កន្លងទៅនេះ ពន្ធដាររកចំណូលពន្ធបានជាង ៣៣០,៩១ ពាន់លានរៀល ឬ ប្រមាណ ៨២,៧ លានដុល្លារ ។ ចំណូលនេះមានកំណើន ២,៨% បើប្រៀបធៀបនឹងចំណូលប្រចាំខែកញ្ញាកន្លងទៅ ។

ដោយឡែកក្នុងរយៈពេល ១០ខែដំបូងនៃឆ្នាំ ២០១៤ ពន្ធដាររកចំណូលបានស្មើនឹង៨៩% នៃគោលដៅកំណត់ក្នុងច្បាប់ថវិកា។ ក្នុងនោះថវិការដ្ឋសម្រេចបាន ៨៩% និងថវិកាថ្នាក់ក្រោមជាតិសម្រេចបាន៨៣,៨%។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នា( ១០ខែ )នៃឆ្នាំ២០១៣ ឃើញថា ការប្រមូលចំណូល ១០ ខែដំបូងនៃឆ្នាំ ២០១៤ មានកំណើនស្មើនឹង ១៨,៩%។

តាមការវិភាគប្រភេទពន្ធឃើញថា ចំណូលក្នុងឆ្នាំ ២០១៤ មានការកើនឡើងគ្រប់ប្រភេទ ក្នុងនោះប្រភេទពន្ធសំខាន់ៗដែលមានការកើនឡើងមានដូចជា ពន្ធលើប្រាក់បៀវត្សរ៍កើនឡើងប្រមាណ ៣១,១%។ ពន្ធលើប្រាក់ចំណេញកើនឡើង ២៥%។ អាករលើតម្លៃបន្ថែមកើនឡើង ១៤,៦% និងអាករពិសេសកើនឡើង ១៣% ។

ដោយឡែក បើពិនិត្យតាមវិស័យចំណូលក្នុងឆ្នាំ ២០១៤ នេះ ក៏មានការកើនឡើងស្ទើរគ្រប់សកម្មភាព ក្នុងនោះផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២១,៩%។ ទូរគមនាគមន៍កើន ២,៤% ។ ផ្នែកស្ថាបត្យកម្មនិងសំណង់កើន ៦២,១%។ ផលិតភេសជ្ជៈកើន ១៨%។ ផ្នែកផលិតគ្រឿងប្រើប្រាស់កើន ២៥,៦%។ ផ្នែកផលិតសម្លៀកបំពាក់កើន ៤៧,៤%។ នីហ័រណអាហ័រណកើន ១៣,២%។ ផ្នែកសណ្ឋាគារផ្ទះសំណាក់កើន ៤៧,៤%។ ផ្នែកផលិតថ្នាំជក់កើន ៩,៧%។ លក់ភេសជ្ជៈកើន៣៧,៥%។ផលិតម្ហូបអាហារកើន៨២%។ ផ្នែកលក់សម្ភារៈការិយាល័យកើន ៣៩,៦%។ ផ្នែកលក់គ្រឿងយន្តកើន ៦០,៨% និងផ្នែកលក់ឱសថកើន ១៦៨,៤% និងគ្រឿងសំណង់កើន ១២៣៥,៣%។

សម្រាប់រយៈពេលពីរខែចុងក្រោយនេះ ដើម្បីគ្រប់គ្រងចំណូលពន្ធដារបានគ្រប់តាមផែនការ និងដើម្បីធានាបាននូវភាពទុកចិត្តផ្នែកថវិកាសម្រាប់បម្រើឲ្យគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គនាយកដ្ឋានពន្ធដារនឹងត្រូវយកយុទ្ធសាស្ត្រកៀងគរចំណូលរយៈពេលមធ្យមឆ្នាំ២០១៤-២០១៨ យកធ្វើជាត្រីវិស័យបង្ហាញផ្លូវក្នុងការប្រមូលចំណូលសម្រាប់រយៈពេល ២ ខែចុងក្រោយនៃឆ្នាំ ២០១៤ ក៏ដូចបណ្ដាឆ្នាំខាងមុខ។

**ការនាំអង្ករចេញរយៈពេល ១០ ខែ :**

របាយការណ៍ស្ដីពីស្ថានភាពនៃការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល ១០ខែ នៃឆ្នាំ២០១៤ របស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ចុះថ្ងៃទី ១៧ ខែវិច្ឆិកាឆ្នាំ ២០១៤ បានឲ្យដឹងថា បរិមាណអង្ករនាំចេញមានចំនួន ៣០៤៧៨៨ តោន។ ចំនួននេះមានការកើនឡើងចំនួន ១០៦៣៤ តោន ច្រើនជាងរយៈពេល ១០ ខែនៃឆ្នាំ ២០១៣ ដែលនាំចេញបានត្រឹម ២៩៤១៥៤ តោន។ ក្នុងនេះដែរ អង្ករប្រភេទក្រអូបមានបរិមាណនាំមុខគេក្នុងការនាំចេញ ដែលមានរហូតដល់ ១៤៤៣៦៣,៨ តោន ។

ដោយឡែកគិតតែក្នុងខែតុលាឆ្នាំ២០១៤ ការនាំចេញអង្ករមានចំនួន ៣៥៤១៨ តោន មានការកើនឡើងចំនួន ៧៣៨៧ តោន លើសបរិមាណនាំចេញក្នុងខែតុលាឆ្នាំ ២០១៣ ដែលនាំចេញបានតែ ២៨០៣១ តោន។ អង្ករកម្ពុជាបាននាំចេញទៅកាន់ទិសដៅចំនួន ៥៧ ប្រទេស ក្នុងនោះប្រទេសបារាំងឈរលំដាប់ទី ១ ដែលមានចំនួន ៥៦១២៥ តោន។ ក្រុមហ៊ុនចំនួន ៨២ ជាអ្នកនាំអង្ករចេញ គឺកើនឡើង ៥ ក្រុមហ៊ុន បើធៀបនឹង ៩ ខែនៃឆ្នាំ ២០១៣ ។



*ការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល ១០ ខែ នៃឆ្នាំ ២០១៤*
*បរិមាណអង្ករនាំចេញមានចំនួន ៣០៤៧៨៨ តោន*

ស្ថានភាពនៃការបំពេញបែបបទសម្រាប់ការនាំចេញអង្ករ មានដំណើរការប្រព្រឹត្តទៅដូចខែមុនៗដែរ ជាមួយនឹងការខិតខំប្រឹងប្រែងដើម្បីកែលម្អការបំពេញសេវាឲ្យកាន់តែមានភាពល្អប្រសើរ។ ក្រសួង ក៏ដូចជាស្ថាប័នពាក់ព័ន្ធ កំពុងបន្តការខិតខំផ្សព្វផ្សាយដល់គ្រប់ដៃគូទាំងអស់ រួមទាំងវិស័យឯកជនផងដែរ ក្នុងការប្រើប្រាស់យន្តការក្រុមការងារទី ៩ ដើម្បីជំរុញការនាំចេញអង្ករដែលមានគុណភាពខ្ពស់ និងមធ្យមឲ្យបានយ៉ាងតិច ១ លានតោននៅឆ្នាំ ២០១៥ តាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

ដោយឡែក របាយការណ៍របស់ក្រុមការងារផ្នែកស្រូវ-អង្ករ នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លេខាធិការដ្ឋានច្រកចេញចូលតែមួយសម្រាប់បំពេញបែបបទនាំចេញអង្ករបានបង្ហាញពីបរិមាណអង្ករកម្ពុជាដែលបាននាំចេញគិតចាប់ពីឆ្នាំ ២០០៩ ដែលរួមមាន៖ ឆ្នាំ ២០០៩ ចំនួន ១២៦១៣ តោន។ ឆ្នាំ ២០១០ ចំនួន ១០៥២៥៩ តោន។ ឆ្នាំ ២០១១ ចំនួន ២០១៨៩៩ តោន។ ឆ្នាំ ២០១២ ចំនួន ២០៥៧១៧ តោន និងឆ្នាំ ២០១៣ ចំនួន ៣៧៨៨៥៦ តោន ។

**ពាណិជ្ជកម្មកម្ពុជា អាមេរិក ត្រីមាសទី ៣ :**

យោងតាមស្ថិតិដែលបានផ្សព្វផ្សាយដោយការិយាល័យស្ថិតិរបស់អាមេរិក បានឲ្យដឹងថា នៅក្នុងរយៈពេលពីដើមឆ្នាំរហូតដល់ត្រីមាសទី ៣ នៃឆ្នាំនេះ ទំហំពាណិជ្ជកម្មរវាងកម្ពុជា និងសហរដ្ឋអាមេរិកមានទឹកប្រាក់ប្រមាណ ២.៤១៥ លានដុល្លារ។ ជាការកត់សំគាល់ទំហំពាណិជ្ជកម្មទ្វេភាគីនៅក្នុងរយៈពេលនេះមានការកើនឡើងប្រមាណ៦,៥៦% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៣ ដែលមានទឹកប្រាក់ត្រឹមតែប្រមាណ ២២៦៦ លានដុល្លារ។ នៅក្នុងអំឡុងពេលនេះទំហំទឹកប្រាក់នាំចេញ និងនាំចូលមានការកើនឡើងដូចគ្នា ។

គិតពីខែមករាមកដល់ខែកញ្ញា កម្ពុជានាំចេញផលិតផលទៅកាន់ទីផ្សារអាមេរិកមានទំហំទឹកប្រាក់ប្រមាណ ២១៦១ លានដុល្លារ គឺមានការកើនឡើងប្រមាណ ៦៩,១ លានដុល្លារ ឬប្រមាណ ៣,៣% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៣ ដែលកាលនោះកម្ពុជាមានលទ្ធភាពនាំចេញត្រឹមតែ ២០៩២ លានដុល្លារ ។

ដោយឡែក សម្រាប់ទំហំទឹកប្រាក់ទំនិញដែលកម្ពុជានាំចូលពីអាមេរិកមកវិញ មានការឡើងដ៏គំហុក។ រយៈពេល ៩ ខែនៃឆ្នាំ ២០១៣ កម្ពុជានាំចូលទំនិញពីអាមេរិកមានតម្លៃត្រឹមតែ ១៧៣,៧ លានដុល្លារទេ តែរយៈពេលដូចគ្នានាឆ្នាំ ២០១៤ នេះ ការនាំចូលមានចំនួនរហូតដល់ទៅ ២៥៣,៤ លានដុល្លារ គឺកើនឡើងប្រមាណ ៧៩,៧ លានដុល្លារឬប្រមាណ ៣១,៤៥% ។

រហូតមកដល់ពេលនេះ អាមេរិកនៅតែជាទីផ្សារធំបំផុតនៃទំនិញនាំចេញរបស់កម្ពុជា ដែលមានដូចជាផលិតផលឧស្សាហកម្មកាត់ដេរ និងផលិតផលពីវិស័យកសិកម្មផ្សេងៗ ។

**វិស័យធានារ៉ាប់រង :**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអះអាងថា ទោះបីសព្វថ្ងៃនេះឧស្សាហកម្មធានារ៉ាប់រងនៅកម្ពុជានៅមានទំហំតូចនៅឡើយ បើប្រៀបធៀបនឹងបណ្ដាប្រទេសក្នុងអាស៊ានក៏ដោយ ក៏ឧស្សាហកម្មមួយនេះមានសក្ដានុពលធំធេងនាអនាគត ខណៈបុព្វលាភក្នុងទីផ្សារធានារ៉ាប់រងបន្តកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំក្នុងទិសដៅវិជ្ជមាន ។

ជាលទ្ធផលនៅក្នុងឆ្នាំ ២០១៣ បុព្វលាភដុលធានារ៉ាប់រងទូទៅបានកើនឡើងរហូតដល់ប្រមាណ ៤៣ លានដុល្លារអាមេរិក។ រីឯទ្រព្យសកម្មបានកើនឡើងដល់ ១១១ លានដុល្លារ ។ ជារួម កំណើនបុព្វលាភដុលធានារ៉ាប់រងទូទៅជាមធ្យមក្នុង ១ ឆ្នាំ សម្រាប់រយៈពេល ៥ ឆ្នាំចុងក្រោយមានប្រមាណ ១៧% គឺជាអត្រាកំណើនមួយខ្ពស់ ។ ដោយឡែកសម្រាប់រយៈពេល ៩ ខែដំបូងនៃឆ្នាំ ២០១៤ នេះ បុព្វលាភដុលធានារ៉ាប់រងទូទៅមានចំនួន ៣៩ លានដុល្លារ កើនឡើងប្រមាណ ២៤% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០១៣ ។ បើបូកបញ្ចូលទាំងធានារ៉ាប់រងអាយុជីវិត និងធានារ៉ាប់រងខ្នាតតូចផង បុព្វលាភដុលធានារ៉ាប់រងទាំងមូលសម្រាប់រយៈពេល ៩ ខែនៃឆ្នាំ ២០១៤ មានប្រមាណ ៤៣,៦ លានដុល្លារ កើនឡើងប្រមាណ ៣៤% បើធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៣ ។

ផលវិជ្ជមាននៃការវិវឌ្ឍរបស់វិស័យធានារ៉ាប់រងនៅកម្ពុជា គឺស្របតាមផែនទីបង្ហាញផ្លូវរយៈពេលវែងរបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុដែលបានដាក់ចេញតាំងពីឆ្នាំ ២០០១ និងត្រូវបានធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់ ៕

# លទ្ធផលក្នុងការខិតខំអនុវត្តតាមគោលដៅអាទិភាពទាំង ៧ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន



*សកម្មភាពស្តារ និងអភិវឌ្ឍផ្លូវដែក*

កាលពីពេលថ្មីៗកន្លងទៅនេះក្រសួងសាធារណការនិងដឹកជញ្ជូនបានបង្ហាញពីលទ្ធផលការងារខួប (ខែកញ្ញាឆ្នាំ ២០១៣ ដល់ខែសីហា ឆ្នាំ ២០១៤)តាមគោលដៅអាទិភាពទាំង៧របស់ក្រសួង ក្នុងការអនុវត្តយុទ្ធ-សាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដំណាក់កាលទី៣ ។ លទ្ធផលបានបង្ហាញថា បណ្តាគោលដៅជាអាទិភាពទាំងនេះ កំពុងត្រូវបាន និងកំពុងអនុវត្តប្រកបដោយផ្លែផ្កា ។

ក្រសួងសាធារណការ និងដឹកជញ្ជូនបានបញ្ជាក់ថាអាទិភាពទី១គឺការជំរុញកសាងបណ្តាញផ្លូវជាតិ និងផ្លូវខេត្ត ក្រោមក្របខណ្ឌជំនួយរបស់ចិន ជប៉ុន កូរ៉េ សរុបចំនួន ២៤ គម្រោង។ បច្ចុប្បន្នបញ្ចប់បានចំនួន ៦ គម្រោង ក្នុងនោះក្រាលកៅស៊ូចំនួន ៤ គម្រោង ប្រវែង ២៩៤,០៨ គ.ម ស្ពាន ១ គម្រោង ប្រវែង ៨៥៥ ម និងលូ ស្ថានីយចម្រោះទឹកកខ្វក់ ១ គម្រោង ហើយកំពុងបន្តដំណើរការមានចំនួន ១៨ គម្រោង។ ក្នុងការកសាងផ្លូវ ស្ពានយុទ្ធសាស្ត្រ អនុលោមតាមអនុសាសន៍សម្តេចតេជោនាយករដ្ឋមន្ត្រី បានបញ្ចប់ចំនួន ៤ គម្រោង ប្រវែង ៤៣,០៤ គ.ម ក្នុងនោះមានផ្លូវក្រាលកៅស៊ូប្រវែង២៧,០៨គ.មផ្លូវក្រាលក្រួសក្រហមប្រវែង១៥,៩៦គ.មនិងគម្រោងកំពុងដំណើរការចំនួន ២ ។

អាទិភាពទី២គឺការបង្កើនការជួសជុលថែទាំដោយថវិកាអន្តរជាតិចំនួន ២៥ គម្រោង ដែលបានបញ្ចប់ចំនួន ១១ គម្រោង ប្រវែង ២៤០,៨១ គ.ម កំពុងដំណើរការចំនួន ៧ គម្រោង និងមិនទាន់អនុវត្តចំនួន ៧ គម្រោង ។ ចំពោះការងារដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ គណៈកម្មការសម្របសម្រួលអចិន្ត្រៃយ៍ របស់គណៈកម្មាធិការដឹកនាំត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ មានអង្គភាពស្ថានីយជញ្ជីងចំនួន ៩ និងក្រុមត្រួតពិនិត្យចល័តពិសេសខេត្តចំនួន ១៤ ក្រុម និងក្រុមចល័តចម្រុះរបស់គណៈកម្មការសម្របសម្រួលចំនួន ៤ ក្រុម បានដំណើរការងារត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់បានចំនួន១០៧.១៦៩ គ្រឿង(ក្នុងនោះ៩៤.១៩១គ្រឿងមិនលើសទម្ងន់កំណត់)និងប្រាក់ពិន័យបានចំនួន ២.០៩៧.៤៣០.៥៥០ រៀល។ ការរឹតបន្តឹងនេះបង្ហាញថា បទល្មើសដឹកជញ្ជូនលើសទម្ងន់កំពុងមាននិន្នាការថយចុះ ទន្ទឹមនេះការរឹតបន្តឹងត្រូវបានរក្សានិរន្តរភាព ដើម្បីកាត់បន្ថយករណីល្មើសឱ្យដល់កម្រិតមួយដែលអាចទទួលយកបាន ។

អាទិភាពទី ៣ គឺការកែលម្អកិច្ចពង្រឹងការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ សេចក្តីព្រាងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកថ្មីត្រូវបានអនុម័តយល់ព្រមនៅកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៤ ហើយត្រូវបានបញ្ជូនទៅស្ថាប័នរដ្ឋសភា។ ក្រសួងបាន និងកំពុងអនុវត្តយ៉ាងសកម្ម ក្នុងការងារត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ការគ្រប់គ្រងយានយន្ត និងការអនុញ្ញាតចេញប័ណ្ណធ្វើអាជីវកម្មជួសជុលកែច្នៃ និងដំឡើងការងារគ្រប់គ្រងយានយន្ត ការងារផ្តល់ប័ណ្ណបើកបរ និងការងារសុវត្ថិភាពចរាចរណ៍ ។

អាទិភាពទី ៤ គឺបានជំរុញ និងទទួលបានលទ្ធផលជាផ្លែផ្កាក្នុងអនុវត្តផែនការមេនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ដើម្បីតភ្ជាប់ផ្ទៃក្នុងប្រទេស និងជាមួយប្រទេសជិតខាង ការស្តារ និងអភិវឌ្ឍផ្លូវដែក កំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែស្វយ័តភ្នំពេញ និងកាំសាប ។

អាទិភាពទី ៥ គឺការរៀបចំគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តចាំបាច់សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធច្បាប់ស្តីពីផ្លូវថ្នល់ដែលត្រូវបាន ថ្ងៃទី៤ ខែឧសភា ឆ្នាំ ២០១៤ កន្លងទៅ។

អាទិភាពទី ៦ គឺការរៀបចំផែនការមេនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង ក្នុងនោះគម្រោងធ្វើឱ្យប្រសើរឡើងនូវទីក្រុងតាមបណ្តោយរបៀងសេដ្ឋកិច្ចមហាអនុតំបន់មេគង្គ (ធនាគារអភិវឌ្ឍអាស៊ី) រួមមានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធទីក្រុង ការរៀបចំផ្លូវថ្នល់ សិល្បការ ស្ថានីយចម្រោះទឹកកខ្វក់ ការគ្រប់គ្រងកាកសំណល់គ្រប់គ្រងច្រាំងស្ទឹង ឬទន្លេ និងស្ថានីយប្រមូលចែកចាយទំនិញ។ ក្នុងជំហានទី ១ បានជ្រើសរើសទីក្រុងចំនួន ៤ តាមបណ្តោយផ្លូវជាតិលេខ ១ និង ៥ រួមមាន បាវិត (ខេត្តស្វាយរៀង) អ្នក-លឿង (ខេត្តព្រៃវែង) ខេត្តបាត់ដំបង និងប៉ោយប៉ែត (ខេត្តបន្ទាយមាន-ជ័យ)សម្រាប់ការអនុវត្តគម្រោង។ ចំពោះជំហានទី ២ កំពុងសិក្សា និងជ្រើសរើសទីក្រុងចំនួន ៤ តាមបណ្តោយផ្លូវជាតិលេខ ៧ និង ៤។ គម្រោងធ្វើឱ្យប្រសើរបរិស្ថានទីក្រុង ជុំវិញបឹងទន្លេសាប បានជ្រើសរើសទីក្រុងចំនួន២ (កំពង់ឆ្នាំងនិងពោធិសាត់)។ គម្រោងសិក្សាលទ្ធភាពសាងសង់បណ្តាញដឹកជញ្ជូនសាធារណៈនៅរាជធានីភ្នំពេញ (សាធារណរដ្ឋបារាំង) ជំហានទី ១ និងទី ២ ត្រូវបានបញ្ចប់ និងបានកំណត់ខ្សែផ្លូវអាទិភាពដំបូងសម្រាប់អយរថអគ្គិសនីនៅក្នុងរាជធានីភ្នំពេញ។

អាទិភាពទី ៧ គឺការបន្តជំរុញការចូលរួមរបស់វិស័យឯកជនក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន តាមរយៈការពង្រឹង និងកែលម្អយន្ត-ការភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។ បន្តធ្វើទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍នានា ដើម្បីជួយជាជំនួយបច្ចេកទេសក្នុងការរៀបចំជានីតិវិធី បទដ្ឋាននានា ដែលទាក់ទងដល់ការងារវិនិយោគគម្រោងសាងសង់ផ្លូវស្ពាន។ ឯកភាពការស្នើរៀបចំការសិក្សា និងសាងសង់ផ្លូវល្បឿនលឿនភ្នំពេញ-បាវិត (ស្វាយរៀង) ដោយទីភ្នាក់ងារចៃកាជប៉ុន (JICA)។ ក្រុមហ៊ុនសាជីវកម្មស្ពានថ្នល់របស់ប្រទេសចិនកំពុងសិក្សាការវិនិយោគសាងសង់ខ្សែផ្លូវថ្មី ផ្លូវល្បឿនលឿនភ្នំពេញ-ខេត្តព្រះសីហនុ។ នាយកដ្ឋានដឹកជញ្ជូននៃខេត្តហឺណានប្រទេសចិនបានបញ្ចប់ និងប្រគល់ជូនក្រសួងនូវផែនការមេផ្លូវល្បឿនលឿននៅព្រះរាជាណាចក្រកម្ពុជា ។



*ស្ពានឆ្លងកាត់ទន្លេមេគង្គខេត្តស្ទឹងត្រែង ប្រវែង ១៧៣១ ម៉ែត្រ សម្រេចបាន ១០០%*

ដោយឡែក ក្នុងរបាយការណ៍របស់ក្រសួងសាធារណការ និងដឹកជញ្ជូននេះដែរ គិតត្រឹមថ្ងៃទី ៤ ខែវិច្ឆិកាឆ្នាំ ២០១៤ នេះ បណ្ដាការដ្ឋាន និងគម្រោងមួយចំនួនទៀតបានទទួលលទ្ធផលជាវិជ្ជមាន និងមួយចំនួនក៏បានបញ្ចប់រួចហើយដែរ។ ក្នុងនោះមាន ៖

### ១-គម្រោងធំៗក្នុងក្របខ័ណ្ឌជំនួយអន្តរជាតិ

#### *ក-គម្រោងជំនួយរបស់សាធារណរដ្ឋប្រជាមានិតចិន :*

ស្ពានតាខ្មៅក្រុងតាខ្មៅ ខេត្តកណ្ដាលប្រវែង ៨៥៥ ម៉ែត្រ សម្រេចបាន ១០០%។ ស្ពានមេគង្គ ខេត្តស្ទឹងត្រែងប្រវែង ១ ៧៣១ ម៉ែត្រសម្រេចបាន ១០០%។ ស្ពានជ្រោយចង្វារទី ២ រាជធានីភ្នំពេញ ប្រវែង ៧២៥ ម៉ែត្រ សម្រេចបាន ៩៨,៨៥%។ កំណាត់ផ្លូវជាតិលេខ ៦ ប្រវែង ៤០,៤៩ គ.ម មានបួនគន្លងចាប់ពីមុខក្រសួងសុខាភិបាលថ្មីដល់ថ្នល់កែងនៃខេត្តកំពង់-ចាម សម្រេចបាន ៨៧,៨៩%។ ផ្លូវជាតិលេខ ៩ ប្រវែង ១៤៣,៣៣ គ.ម ចាប់ពីត្បែងមានជ័យ ខេត្តព្រះវិហារ-ថាឡាបរីវ៉ាត់ ខេត្តស្ទឹងត្រែង សម្រេចបាន ៩៩,៦៤%។ កំណាត់ផ្លូវជាតិលេខ ៧៦ បន្ត ប្រវែង ១៧១,៧៨ គ.ម ចាប់ពីសែនមនោរម្យកោះញែកខេត្តមណ្ឌលគីរី-លំផាត់តាអង់ខេត្តរតនគីរី សម្រេចបាន៦៥,៤៩%។ផ្លូវជាតិលេខ៤៤ប្រវែង១៣៩,៦១គ.មចាប់ពីច្បារមន ឱរ៉ាល់ ឧដុង្គ ខេត្តកំពង់ស្ពឺ សម្រេចបាន ៧២,៤១%។ កំណាត់ផ្លូវជាតិលេខ ៥ ប្រវែង ៣០,១៤៥ គ.ម ចាប់ពីភ្នំពេញដល់ព្រែកក្ដាម សម្រេចបាន ២០,៧៦%។ កំណាត់ផ្លូវជាតិលេខ ៦ ប្រវែង ២៤៧,៧០ គ.ម ថ្នល់កែង-អង្គ្រង ខេត្តសៀមរាប សម្រេចបាន ៣៨,៩៨%។ ស្ពានកោះធំខេត្តកណ្ដាល ប្រវែង ៤១៥ ម៉ែត្រ សម្រេចបាន ៣៥,២១%។ កំណាត់ផ្លូវជាតិលេខ ៧ ប្រវែង ៣៩ គ.ម ពីស្រុកចិត្របុរី ស្រុកសំបូរ ខេត្តក្រចេះ សម្រេចបាន ៣៤,៦៦%។

#### *ខ- គម្រោងជាជំនួយជប៉ុន :*

គម្រោងសាងសង់ស្ពានអ្នកលឿងប្រវែង ២,២២ គ.ម សម្រេចបាន ៩២%។ គម្រោងបង្ការគ្រោះមហន្តរាយដោយទឹកជំនន់ រួមមានការជួស-ជុលចាក់កៅស៊ូលើកំណាត់ផ្លូវជាតិលេខ ៥ ប្រវែង ២,២ គ.ម ផ្លូវក្នុងក្រុងប្រវែង ២,៤ គ.ម និងប្រព័ន្ធរំដោះទឹកជំនន់ប្រវែង ២,៦ គ.ម នៅខេត្តកំពង់-ឆ្នាំង និងនៅលើកំណាត់ផ្លូវជាតិលេខ ១១ សាងសង់ស្ពានបេតុង ៨ កន្លែងនៅខេត្តព្រៃវែង សម្រេចបាន ៨៧,៨០%។

#### *គ- គម្រោងជំនួយកូរ៉េ :*

ផ្លូវជាតិលេខ ៣១ ប្រវែង ៥៤,៧៩ គ.ម ផ្លូវជាតិលេខ ៣៣ ប្រវែង ៣៦,២៧គ.មផ្លូវខេត្តលេខ១១៧ប្រវែង១១,២៥គ.មនិងផ្លូវវាងទីរួមខេត្តកំពតប្រវែង ៣,៦៩ គ.ម សម្រេចបាន ១០០%។គម្រោងសាងសង់ប្រព័ន្ធលូ និងស្ថានីយចម្រោះទឹកកខ្វក់ខេត្តសៀមរាប សម្រេចបាន ១០០%។ ផ្លូវជាតិលេខ ៥៦ កំណាត់ទី ២ ប្រវែង ៨៤ គ.ម ពីស្វាយចេក សំរោង ខេត្តឧត្ដរមានជ័យ សម្រេចបាន ៦៥,០១%។



*ស្ពានតាខ្មៅក្រុងតាខ្មៅ ខេត្តកណ្ដាលប្រវែង ៨៥៥ ម៉ែត្រ សម្រេចបាន ១០០%*

#### *ឃ- គម្រោងជំនួយធនាគារអភិវឌ្ឍន៍អាស៊ី* (ADB)

សាងសង់អគារត្រួតពិនិត្យឆ្លងកាត់ព្រំដែនព្រែកចាក ខេត្តកំពត សម្រេចបាន ៨៤,៧១%។ ផ្លូវជាតិលេខ ៥៦ កំណាត់ទី ១ ប្រវែង ២៩ គ.ម ពីសិរីសោភ័ណ ស្វាយចេក ខេត្តបន្ទាយមានជ័យ សម្រេចបាន ១០០%។ ផ្លូវជាតិលេខ១៣ប្រវែង៦២,៤០គ.មរមាសហែក-ប្រសូតខេត្តស្វាយរៀង សម្រេចបាន ១០%។ ផ្លូវខេត្តលេខ ៣១៤D ប្រវែង ២៥.៥០ គ.ម ប្រសូត-ព្រៃវល្លិ៍ព្រំដែនកម្ពុជាវៀតណាមសម្រេចបាន១០%។ផ្លូវជាតិលេខ១៥០B ផ្លូវខេត្តលេខ ៥៣ និងផ្លូវខេត្តលេខ ១៥១B ប្រវែង ៨៧,៩០ គ.ម ក្នុងខេត្តកំពង់ឆ្នាំង និងកំពង់ស្ពឺ សម្រេចបាន ១០%។

#### *ង- គម្រោងប្រើប្រាស់ថវិកាជាតិ*

### ការងារថែទាំប្រចាំនិងការងារថែទាំខួបប្រចាំឆ្នាំ

ក្នុងឆ្នាំ ២០១៤ នេះ ការងារថែទាំប្រចាំឆ្នាំសម្រេចបាន៦០,៣៣%និងការងារថែទាំខួបប្រចាំឆ្នាំ( ផ្លូវនិងស្ពាន )សម្រេចបាន ៦០%។

-ការងារសាងសង់ផ្លូវ ស្ពានយុទ្ធសាស្ត្រមួយចំនួនតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្ដេចតេជោនាយករដ្ឋមន្ត្រី :

ផ្លូវខេត្តលេខ ១១០ ប្រវែង ៨៥,៧៤ គ.ម ( ពីផ្លូវជាតិលេខ ១ ដល់ឃុំព្រែកជ្រៃ ស្រុកកោះធំ ខេត្តកណ្ដាល )។ ជំហានទី ៤ សាងសង់ផ្លូវដោយចាក់កៅស៊ូបានប្រវែង ១៨,២២ គ.ម (ឃុំឈើខ្មៅ-ឃុំព្រែកជ្រៃ) សម្រេចបាន ៦៦,៦៤%។

ផ្លូវខេត្តលេខ១៣៦( ១២៣ចាស់ )ប្រវែង១០គ.មពីសង្កាត់កំពង់បាយដល់ឃុំព្រៃឃ្មុំស្រុកទឹកឈូខេត្តកំពត។ជំហានទី១ចាក់ក្រាលក្រួសក្រហមនិងចាក់ដីលើកតួផ្លូវការពារទឹកភ្លៀងប្រវែង៤,៥គ.មអនុវត្តបាន១០០%។

ជួសជុលកំណាត់ផ្លូវជាតិលេខ ៧ ប្រវែង ២៣ គ.ម ក្នុងស្រុកសំបូរ ខេត្តក្រចេះសម្រេចបាន ៥៣,២៣%។

តាមរយៈសកម្មភាព និងលទ្ធផលការងារខាងលើនេះបានឆ្លុះបញ្ចាំងច្បាស់នូវការប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីសម្រេចឱ្យបាននូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍មួយប្រទាក់ក្រឡានៅទូទាំងប្រទេសប្រកបដោយគុណភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច សំដៅជួយទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ការធ្វើសមាហរណកម្មផ្ទៃក្នុង និងសមាហ-រណកម្មក្នុងតំបន់។ ជាមួយនឹងប្រព័ន្ធផ្លូវកាន់តែល្អប្រសើរឡើង នឹងបង្កអំណោយផលថែមទៀត ដល់ការលើកស្ទួយជីវភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាជន ជាពិសេស ប្រជាជននៅតំបន់ជនបទ ៕

# វិស័យធនាគារបានចូលរួមយ៉ាងសកម្ម ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច



*ឯកឧត្ដម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជាថ្លែងក្នុងពេលសម្ពោធធនាគារឯកជនមួយកន្លែងនៅរាជធានីភ្នំពេញ*

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងការជំរុញការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការលើកកម្ពស់សេវាសាធារណៈ និងការពង្រឹងអភិបាលកិច្ចល្អ ធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាបន្តរីកចម្រើនទៅមុខទៀតប្រកបដោយថាមពលដ៏ខ្លាំងក្លា។

ឯកឧត្ដម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា បានឱ្យដឹងថា ស្ថិតក្នុងស្ថានភាពអំណោយផលនៃសេដ្ឋកិច្ចសាកល គួបផ្សំនឹងការរក្សាបាននូវស្ថិរភាពនយោបាយ សេដ្ឋកិច្ចកម្ពុជាបានបន្តងើបឡើងគួរឱ្យកត់សម្គាល់ ។ រាជរដ្ឋាភិបាលកម្ពុជាបានព្យាករណ៍ដោយសុទិដ្ឋិនិយមថា សេដ្ឋកិច្ចកម្ពុជានឹងរក្សាបាន នូវកំណើនប្រមាណ ៧% នៅក្នុងឆ្នាំ ២០១៤ នេះ ។

ឯកឧត្ដមទេសាភិបាលធនាគារជាតិនៃកម្ពុជាបានបន្តថា កំណើននេះ



*ធនាគារ អេស៊ីលីដា ភីអិលស៊ី*



*ធនាគារជាតិនៃកម្ពុជា*

គាំទ្រដោយវិស័យកសិកម្មដែលមានការកើនឡើងប្រមាណជា ៤,៥% និងវិស័យឧស្សាហកម្មកើនឡើងប្រមាណ ៨,៩% ។ ក្រៅពីនោះ វិស័យសេវាកម្ម វិស័យទេសចរណ៍ ព្រមទាំងការវិនិយោគផ្ទាល់ពីបរទេស សុទ្ធតែបានជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាផងដែរ ។ ធនាគារជាតិនៃកម្ពុជាបានចូលរួមចំណែកយ៉ាងសកម្មក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការបន្តអនុវត្តគោលនយោបាយរូបិយវត្ថុ និងគោលនយោបាយប្ដូរប្រាក់ប្រកបដោយភាពប្រុងប្រយ័ត្នជានិច្ច ដោយរក្សាបាននូវតម្លៃប្រាក់រៀលមិនឲ្យឡើងចុះហួសកម្រិត ធៀបនឹងប្រាក់ដទៃដែលចរាចរណ៍នៅលើទីផ្សារក្នុងប្រទេសកម្ពុជា ។

ដោយឡែកចំពោះវិស័យមីក្រូហិរញ្ញវត្ថុវិញគេសង្កេតឃើញមានការរីកលូតលាស់ខ្លាំងផងដែរ ទាំងសេវាកម្មប្រាក់បញ្ញើ និងឥណទាន ដោយបានពង្រីកសាខារបស់ខ្លួនជាបន្តបន្ទាប់នៅតាមបណ្ដាខេត្តនានា ជាក់ស្ដែងមីក្រូហិរញ្ញវត្ថុអម្រឹត ស្ថាបនា ប្រាសាក់ ហត្ថាកសិករ ជាដើម ដែលបានពង្រីកសាខានៅតាមបណ្ដាខេត្តជាបន្តបន្ទាប់ ដើម្បីបង្កលក្ខណៈងាយស្រួល និងបំពេញតម្រូវការផ្នែកហិរញ្ញវត្ថុដល់អតិថិជនរបស់ខ្លួន ។

តាមរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជាបានឱ្យដឹងថា គិតត្រឹមឆមាសទី១នៃឆ្នាំ២០១៤ធនាគារពាណិជ្ជមានចំនួន៣៥ធនាគារឯកទេសមានចំនួន ៩ ការិយាល័យតំណាងធនាគារបរទេសមានចំនួន ៦ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៤០ ។ ឥណទានផ្ដល់ដោយវិស័យមីក្រូហិរញ្ញវត្ថុកើនឡើង ៤៨% ពីចំនួន ៤ ៤៥៩ ពាន់លានរៀល ដល់ ៦ ៥៧១ ពាន់លានរៀល ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៣ ។ ចំណែកប្រាក់បញ្ញើបានកើនដល់ ២ ៣១៥ ពាន់លានរៀល ពីអ្នកផ្ញើប្រាក់ចំនួន ៩៩៣ ៥៤៩ នាក់ ពោលគឺកើនឡើងប្រមាណ ៥២% ។

តាមរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជាបានឲ្យដឹងថា ចំនួនឥណទានដែលផ្ដល់ដោយគ្រឹះស្ថានធនាគារនៅកម្ពុជាមានចំនួន ៨,០៩ ពាន់លានដុល្លារអាមេរិក កើនឡើង ២១,៧% និងប្រាក់បញ្ញើពីអតិថិជនមានចំនួន ៨,៩២ ពាន់លានដុល្លារអាមេរិក កើនឡើង ២១,៥% បើធៀបរយៈពេលដូចគ្នា កាលពីឆ្នាំ ២០១៣ ។

បច្ច័យទាំងនេះបានបង្ហាញឲ្យឃើញកាន់តែច្បាស់ថែមទៀត អំពីលទ្ធភាពរបស់ប្រជាជនដែលអាចទទួលបានសេវាហិរញ្ញវត្ថុកាន់តែច្រើនឡើង ។

របាយការណ៍ដដែលបង្ហាញទៀតថា គិតត្រឹមឆមាសទី ១ ឆ្នាំ ២០១៤ ចំនួនអ្នកទទួលបានឥណទានមានប្រមាណ ២,០៦ លាននាក់ កើនឡើង ១៩,៧% ហើយចំនួនអ្នកដាក់ប្រាក់បញ្ញើមានប្រមាណ ៣,០២ លាននាក់



*ធនាគារកម្ពុជាសាធារណៈ*

កើនឡើង ១៩,៨% បើធៀបទៅនឹងឆមាសទី ១ ឆ្នាំមុន។

ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជាបានមានប្រសាសន៍នៅក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆមាសទី ១ និងទិសដៅការងារឆមាសទី ២ ឆ្នាំ ២០១៤ របស់ធនាគារជាតិនៃកម្ពុជាថា កំណើននេះដោយសារតែធនាគារជាតិនៃកម្ពុជាបានលើកកម្ពស់ជាប្រចាំនូវសមត្ថភាព និងវិធីសាស្ត្រត្រួតពិនិត្យ ការពង្រឹងក្របខ័ណ្ឌច្បាប់ បទ-ប្បញ្ញត្តិ និងការវិភាគលើហានិភ័យសំខាន់ៗ ដូចជា ហានិភ័យឥណទាន ហានិភ័យទីផ្សារ ហានិភ័យប្រតិបត្តិការ ។ល។ ក្នុងគោលបំណងតាមដានពិនិត្យអំពីផលប៉ះពាល់នៃហានិភ័យទាំងនោះមកលើប្រាក់ចំណេញ និងស្ថានភាពដើមទុនរបស់ប្រព័ន្ធធនាគារ ។

ឯកឧត្តមថ្លែងថា នេះជាសូចនាករល្អណាស់ដែលប្រាក់បញ្ញើក៏កើនឡើង និងឥណទានក៏កើនឡើង ហើយម៉្យាងទៀតឥណទានមិនដំណើរការបានថយចុះ ដែលបង្ហាញថា ឥណទានទាំងនោះត្រូវបានយកទៅប្រើប្រាស់ចំគោលដៅ បង្កើនដល់ផលិតកម្ម និងទំនិញក្នុងស្រុក។ ដូចនេះវាផ្តល់បច្ច័យល្អសម្រាប់ប្រទេសជាតិ។ ឯកឧត្តមក៏បានវាយតម្លៃថា ប្រព័ន្ធធនាគារនៅប្រទេសកម្ពុជានៅតែមានសុខភាពល្អប្រសើរ ដោយសារបណ្តាគ្រឹះស្ថានធនាគារបានអនុវត្តតាមបទបញ្ញាដ៏ប្រុងប្រយ័ត្នរបស់ធនា-គារជាតិនៃកម្ពុជា ដែលក្នុងនោះធ្វើឲ្យឥណទានមិនដំណើរការមានត្រឹមតែ ២,៦% ប៉ុណ្ណោះ ។




*អតិថិជនដកប្រាក់ពីម៉ាស៊ីន ETM*

ឯកឧត្តម **គីម វ៉ាដា** អគ្គនាយកត្រួតពិនិត្យធនាគារជាតិនៃកម្ពុជាបានឲ្យដឹងនៅក្នុងពិធីសម្ពោធបើកសាខាធនាគារសហពាណិជ្ជ ក.អ (UCB) ស្រុកខ្សាច់កណ្តាល កាលពីថ្ងៃទី ៥ កញ្ញា ឆ្នាំ ២០១៤ ថា គិតត្រឹមឆមាសទីមួយ ឆ្នាំ ២០១៤ ទ្រព្យសកម្មសរុបក្នុងប្រព័ន្ធធនាគានៅកម្ពុជាមានប្រមាណ ១៤,៥៣ ពាន់លានដុល្លារអាមេរិក កើនឡើងចំនួន ១៤% និងប្រាក់ចំណេញសរុបក្នុងប្រព័ន្ធធនាគារមានប្រមាណ ៣១២ លានដុល្លារអាមេរិក កើនឡើងចំនួន ២៧,៤៧% បើធៀបទៅនឹងដំណាច់ឆ្នាំ ២០១៣ កន្លងមកនោះ ។ ផ្ទុយមកវិញអនុបាតឥណទានមិនដំណើរការបានថយចុះពី ២,៧០% មកនៅ ២,៦៣% ដែលបង្ហាញឲ្យឃើញអំពីភាពរីកចម្រើននៅក្នុងវិស័យធនាគារទាំងមូលរបស់កម្ពុជា។ អគ្គនាយកត្រួតពិនិត្យធនាគារជាតិនៃកម្ពុជាក៏បានលើកឡើងដែរថា ការវិវឌ្ឍជាវិជ្ជមាននេះគឺដោយសារតែមានការចូលរួមចំណែក ពីបណ្តាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុទាំងឡាយនៅកម្ពុជា ក្នុងការបង្កើនប្រសិទ្ធភាពគ្រប់គ្រងគុណ-ភាព ឥណទានបានល្អប្រសើរឡើង ។

សរុបមកវិស័យធនាគារ និងហិរញ្ញវត្ថុឆ្នាំ ២០១៣-២០១៤ នេះសម្រេចបានសមិទ្ធផលប្រកបដោយមោទនភាព ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការជួយទ្រទ្រង់កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ។ លទ្ធផលដែលទទួលបាននេះ ស្ថិតក្នុងបរិការណ៍ទូទៅដ៏ល្អរបស់ប្រទេសជាតិដែលមានសន្តិភាព និងស្ថិរភាពនយោបាយរឹងមាំ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈដ៏ប្រុងប្រយ័ត្នរបស់រាជរដ្ឋាភិបាល ដែលមានសម្តេចតេជោ **ហ៊ុន សែន** ជាប្រមុខ។ ទន្ទឹមនេះ វិស័យធនាគារ និងហិរញ្ញវត្ថុ ក៏នៅមានបញ្ហាជាច្រើនទៀតដែលត្រូវបន្តដោះស្រាយចំពោះមុខការវិវឌ្ឍដ៏ស្មុគស្មាញនៃសេដ្ឋកិច្ចតំបន់ និងពិភពលោក ក្នុងនោះក៏រួមមានការទប់ស្កាត់នូវហានិភ័យដែលអាចកើតមានក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ទាក់ទងទៅនឹងលទ្ធភាពសងបំណុលរបស់ប្រជាជន ដែលមានលទ្ធភាពទន់ខ្សោយនៅតាមបណ្តាមូល-ដ្ឋាន ។ បញ្ហានេះវាមិនគ្រាន់តែជាបញ្ហាសេដ្ឋកិច្ចទេ តែវាក៏ជាបញ្ហាជះឥទ្ធិពលដល់នយោបាយផងដែរ ដែលទាមទារឲ្យរាជរដ្ឋាភិបាលគប្បីយកចិត្តទុកដាក់ដោះស្រាយតាមរយៈគោលនយោបាយ ឬវិធានការជាក់ស្តែងដ៏មានប្រសិទ្ធភាពនានា ៕




*មីក្រូហិរញ្ញវត្ថុអម្រឹត*

# រចនាប័ទ្មបន្ទាយស្រី


*រូបភាព ១-៣ : ហោជាង (ឯកសារ អភិរក្សដ្ឋានអង្គរ ឆ្នាំ ១៩៣៥), សសរពេជ្រ, សសរផ្ដោប និង ក្បាច់ផ្ដែរ (ម.ត ២០០៦)*

ប្រាសាទបន្ទាយស្រីជាប្រាសាទតែមួយគត់សាងសង់អំពីថ្មភក់មានពណ៌ផ្កាឈូកវិមានស្ថាបត្យកម្មនេះត្រូវបានគេប្រៀបទៅនឹងពេជ្រមួយគ្រាប់។ និទានរឿងរ៉ាវផ្សេងៗ ដែលមានក្នុងទេវកថាវិទ្យានៃព្រហ្មញ្ញសា-សនា ដូចជារឿងគ្រិស្នៈសម្លាប់ភាមៈ ឬក៏ព្រះសិវៈប្រថាប់លើភ្នំកៃលាស ជាឧទាហរណ៍។ គេក៏អាចកត់សម្គាល់ឃើញមាន ការផ្ដើមផលិតហោជាងត្រួតគ្នាតែថយក្រោយបន្តិច។

ហោជាងមានក្រប ហោជាងមានលក្ខណៈខុសប្លែកគ្នាច្រើន ដូចជាហោជាងមានរាងត្រីកោណលម្អដោយក្បាច់សន្លឹកឈើ ហើយខាងចុងមានក្បាលនាគរាជ និងម្ករ ។ នៅចន្លោះហោជាង គេឆ្លាក់រឿងផ្សេងៗ ឬស្លឹកឈើសុទ្ធសាធ លម្អជញ្ជាំងមានរូបទេពឬទ្វារបាល មានចម្លាក់យ៉ាងល្អប្រណិត ចម្លាក់ដែលឆ្លាក់មានលក្ខណៈជាចម្លាក់ជ្រៅៗ។

ពាក់ព័ន្ធនឹងសម្លៀកបំពាក់ នៃទេវរូបនាជំនាន់នោះគប្បីត្រូវជ្រាបថា សម្លៀកបំពាក់មានពីរបែប ៖

១-សំពត់ផ្នត់មានជាយ និងមានហោប៉ៅដូចករណីរូបស្រីទេពអប្សរឆ្លាក់ដាច់តែឯងអមនៅជណ្ដើរ។

២-សំពត់លាត មានលក្ខណៈប្រហាក់ប្រហែលនិងសំពត់ក្នុងរចនាប័ទ្មព្រះគោ ដោយរបៀបស្លៀកឡើងលើដល់ផ្ចិត មានផ្នត់មានហោប៉ៅ។រីឯខ្សែក្រវាត់មានរាងសំប៉ែតគ្មានជរ និងមានកន្ទុយត្រី ( ឧទាហរណ៍រូបអប្សរជាទ្វារបាលមានកន្ទុយត្រី ) ក្នុងចម្លាក់ភេទស្រីដែលស្ថិតក្នុងរចនាប័ទ្មបន្ទាយស្រីស្ត្រីស្លៀកសំពត់ផ្នត់ រីឯរូបទេវតាភេទប្រុស ស្លៀកសំពត់លាត។

សូមរំឭកថា នៅក្នុងរចនាប័ទ្មប្រែរូប និងមេបុណ្យសំពត់ផ្នត់មានបីជ្រុង។រីឯការលម្អសក់វិញ យើងក៏អាចសង្កេតឃើញថា វាមានលំនាំដូចនៅរចនាប័ទ្មកោះកេរដែរ តែក្បាំងមានក្បាច់ក្បូរយ៉ាងលម្អិត (ឧទាហរណ៍លើរូបត្របកផ្កាឈូក)។រីឯកម្រងផ្នួងមានរាងម្កុដត្រួតគ្នា ហើយរួមទៅលើ ភ្នួងសក់មានលម្អ ដូចដៃប៉ាន់ត្រួតគ្នាជាថ្នាក់ៗ នៅគល់ផ្នួងជាជួរគុជ។ ចម្លាក់ទេវរូបច្រើនមានលក្ខណៈតូចៗ មានទឹកមុខស្រស់បស់ ដោយនៅលើជញ្ជាំង មានលម្អ ដោយគ្រឿងអលង្ការដ៏ល្អប្រណិតជាច្រើន។

ជាទូទៅគេឃើញមានខ្សែក្រវាត់និងក្រវិលនៅលើព្រះបដិមាដ៏សម្បូរបែប ដែលវិចិត្រករឆ្លាក់យ៉ាងប៉ិនប្រសប់ ហើយមានលក្ខណៈតូចឆ្មារ រំលេចចេញពីថ្មគួរឲ្យចាប់ចិត្តណាស់ ។ សូមរំឭកថា នៅលើជ្រុង សសរមានការជំនួស និងមានវត្ថុមានរបស់សសរមូល ៕

*( ម.ត្រាណេ )*


*រូបភាព ១-៤ : សំពត់ទេវរូប, ទ្វារបាល ជាគ្រុឌ (ឯកសារ អភិរក្សដ្ឋានអង្គរ ឆ្នាំ ១៩៣៥), ទ្វារបាល និង ព្រះឥសូរ (សារមន្ទីរជាតិភ្នំពេញ)*


*រូបភាព ១-៤ : ផ្នួងសក់ និង ប្រភេទសំពត់ទេវរូប (ឯកសារ អភិរក្សដ្ឋានអង្គរ រវាងឆ្នាំ ១៩២៩ និង ១៩៣៥)*



# ឱសថធម្មជាតិ ៧ ប្រភេទ ជួយដល់ការរំលាយអាហារ

កង្វះខាតការយល់ដឹង ពីគុណប្រយោជន៍នៃអាហារបន្លែបង្ការ វាជាកត្តាសំខាន់នាំឱ្យប៉ះពាល់ សុខភាព ហើយបន្លែផ្លែឈើមួយចំនួនដែលមានតម្លៃថ្លៃនោះ មិនមែនប្រាកដសុទ្ធតែមានប្រយោជន៍ដល់សុខភាពទេ ប្រសិនបើអ្នកជ្រើសរើសបន្លែផ្លែឈើទាំងនោះយកទៅទទួលទាន មិនបានត្រឹមត្រូវ ជាពិសេសបន្លែបង្ការមួយចំនួនដែលមានដុះនៅ តាមមូលដ្ឋាន ភូមិឋានរបស់ប្រជាកសិករយើង ភាគច្រើនមានតម្លៃថោក និងជាឱសថធម្មជាតិដ៏ល្អចំពោះសុខភាព។

ក្រុមអ្នកស្រាវជ្រាវបានឱ្យដឹងថា បន្លែបង្ការមួយចំនួនដែលមានដុះនៅតាមមូលដ្ឋាន ភូមិឋានរបស់ប្រជាកសិករយើង មិនត្រឹមតែជាឱសថធម្មជាតិដ៏ល្អចំពោះសុខភាពប៉ុណ្ណោះទេ ថែមទាំងជួយដោះស្រាយអាការៈមិនស្រួលខ្លួនផ្សេងៗ តួយ៉ាងឱសថធម្មជាតិ ៧ មុខខាងក្រោមនេះ ដែលយើងបានស្គាល់ច្បាស់ស្ទើរគ្រប់គ្នា។ វាសុទ្ធតែមានគុណសម្បត្តិក្នុងការដោះស្រាយអាការៈហើមពោះឆ្អល់ពោះ ចុកសៀតណែនបាន ។

**១.ខ្ទឹមស ៖** ខ្ទឹមស ជាឱសថធម្មជាតិដ៏ល្អចំពោះសុខភាព ។ នៅពេលណាយើងទទួលទានចូលទៅសារធាតុក្នុងខ្ទឹមសនឹងជួយបង្កើន អង់ហ្ស៊ីម និងទឹកប្រមាត់ ជាហេតុធ្វើឱ្យការរំលាយអាហារដំណើរការបានល្អ ហើយថែមទាំងកាត់បន្ថយអាការៈឈឺពោះដោយសារតែអាហារ មិនរំលាយបានទៀតផង។ ប្រសិនបើយើងមានអាការៈ ចុកសៀតណែនដោយ



សារអាហារមិនរំលាយញឹកញាប់នោះ ត្រូវយកខ្ទឹមសមកបកសំបករួចយកតែសាច់ក្នុង ៥កំពិសមកហាន់ឱ្យម៉ដ្ឋទទួលទានជាមួយទឹកក្រោយបាយរួចនោះ អាការៈនេះនឹងបាត់ម្តងបន្តិចៗជាក់ជាមិនខាន។



**២.ខ្ទឹមក្រហម ៖** ខ្ទឹមក្រហម មានហ្វ្លាវ៉ូណយ (Flavonoid) គ្លៃកូស៊ែ (Glycosides) ភេកទីន (Pectin) និងគ្លូខូឃីនីន (Glucokinin) ជួយរំលាយអាហារ និងធ្វើឱ្យបាយឆ្ងាញ់ ។ យើងអាចយកខ្ទឹមក្រហមមកធ្វើអាហារបានច្រើនប្រភេទ ជាពិសេសញាំជាមួយនឹងអាហារផ្សេងៗ ។



**៣.ម្ទេសស្រស់ ៖** ម្ទេសស្រស់គ្រប់ប្រភេទមិនថាហិរខ្លាំង ហិរតិច គឺសុទ្ធតែជួយរំញោចការបញ្ចេញទឹកមាត់ឱ្យចេញមកច្រើន អង់ហ្ស៊ីមក្នុងទឹកមាត់នេះហើយដែលជួយរំលាយជាតិម្សៅក្នុងមាត់ ។ ក្រៅពីនេះគេក៏បានរកឃើញផងដែរថា ម្ទេសខ្មាំងហិរខ្លាំងជួយរំលាយអាហារជួយឱ្យបាយឆ្ងាញ់ និងដើរខ្យល់ល្អ ។

**៤.រំដេង ៖** រំដេងមានឥទ្ធិពលបញ្ចេញទឹកប្រមាត់ទើបជាមុខម្ហូបមួយដែលជួយរំលាយអាហារបានដែរ។ វិធីដ៏ល្អដែលធ្វើឱ្យយើងទទួលទានរំដេងបានឆ្ងាញ់ដូចបន្លែដទៃ គឺត្រូវហាន់រំដេងជាចំណិតតូចៗ រួចទើបយក



មកធ្វើអាហារ ។



**៥.ស្លឹកគ្រៃ ៖** ស្លឹកគ្រៃមានសារធាតុក្នុងការបញ្ចេញទឹកប្រមាត់ដើម្បីជួយរំលាយអាហារ ។ ប៉ុន្តែបើយើងទទួលទានស្លឹកគ្រៃស្រស់ៗ អាចមិនសូវឆ្ងាញ់ទេ។ ដូច្នេះហើយ បានជាគេច្រើនតែយកស្លឹកគ្រៃមកធ្វើជាទឹកគ្រឿង ស្លឹកគ្រៃ ឬតែស្លឹកគ្រៃទើបជួយឱ្យមានរសជាតិឆ្ងាញ់ ។



**៦.ស្លឹកជីរនាងវង** (Ocimum basilicum) ស្លឹកជីរនាងវងមានក្លិនក្រអូប ពិសេសគឺក្រអូបធូរច្រមុះ ហើយប្រេងក្រអូបឆ្លលនេះ មានឥទ្ធិពលក្នុងការជួយរំលាយអាហារ ។

**៧. ស្លឹកម្រះព្រៅ ៖** ម្រះពៅមានឥទ្ធិពលបញ្ចេញទឹកប្រមាត់ចេញមកជួយរំលាយអាហារ ។ មិនគួរឱ្យជឿឡើយ នៅពេលដែលយើងបានធុំក្លិនឆាក្តៅ ឬ ឆាម្រះព្រៅពេលណា តែងធ្វើឱ្យយើងឃ្លានបាយភ្លាមៗ៕





# អាងត្រពាំងថ្ម : ទីអភិរក្ស និងអភិវឌ្ឍន៍ ដែលមានទាំងកសិកម្ម និងទេសចរណ៍





*អាងត្រពាំងថ្ម ស្រុកភ្នំស្រុក ក្នុងខេត្តបន្ទាយមានជ័យ ជាតំបន់អេកូទេសចរណ៍ និងកសិកម្ម*

*ពេលនិយាយដល់ឈ្មោះ ខេត្តបន្ទាយមានជ័យ គេពិតជាមិនភ្លេចពីការរំលឹកដល់អាងត្រពាំងថ្ម ដែលជាតំបន់អភិរក្សសត្វជិត ២០០ ប្រភេទ ពិសេសសត្វក្រៀលក្បាលក្រហម និងសត្វស្លាបជិតផុតពូជលើលោក ១៨ ប្រភេទ។ ជាដែនជម្រកសត្វដ៏ធំមួយនៅកម្ពុជា ក៏ដូចជានៅអាស៊ីអាគ្នេយ៍ ។ ទីនោះក៏ជាទីអភិរក្សពួកម្រឹគ មច្ឆជាតិ ព្រមទាំងជាតំបន់អេកូទេសចរណ៍ និងកសិកម្ម។*

*សំខាន់ជាងនេះ អាងត្រពាំងថ្មក៏ជាទីឆ្លងកាត់នៃខ្សែមហាផ្លូវក្នុងប្រវត្តិសាស្ត្រសម័យអង្គរជាអាងធារាសាស្ត្រដ៏ធំជាងគេនៅពាយ័ព្យកម្ពុជា ដែលកសាងដោយពលករខ្មែរនៅសម័យកម្ពុជាប្រជាធិបតេយ្យ។អាងនេះក៏ត្រូវបានស្តារនិងអភិវឌ្ឍន៍ឡើងវិញដោយជំនួយឥតសំណងរបស់ជប៉ុន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល សម្រាប់ផ្តល់ទឹកបម្រើឲ្យការស្រោចស្រពដំណាំស្រូវវស្សា និងប្រាំងដំណាំចម្ការរាប់ម៉ឺនហិកតា។ បច្ចុប្បន្នរាជរដ្ឋាភិបាលបានស្ថាបនាផ្លូវក្រាលកៅស៊ូមួយភ្ជាប់ដល់អាងតែម្តង។ ប្រការសំខាន់ទីនោះត្រូវបានកំណត់ថា "ជាទីអភិរក្ស និងអភិវឌ្ឍន៍ "។*

## ភូមិសាស្ត្រ ប្រវត្តិសាស្ត្រ:

អាងត្រពាំងថ្មស្ថិតនៅចន្លោះ ឃុំប៉ោយចារ ឃុំពន្លៃ និងឃុំណាំតៅ ស្រុកភ្នំស្រុក មានចម្ងាយ ៧០គ.ម ទិសឦសានទីរួមខេត្តបន្ទាយមានជ័យ ឬក្រុងសិរីសោភ័ណ និងខាងលិចក្រុង / ខេត្តសៀមរាប ១០០គ.ម។

បើធ្វើដំណើរតាមផ្លូវជាតិលេខ ៦ ទៅដល់ត្រង់ភូមិព្រៃមាន់ ឃុំរហាល ស្រុកព្រះនេត្រព្រះ យើងនឹងឃើញរូបចម្លាក់ថ្មយាយត្បាញសូត្រ គឺត្រូវបត់ទៅទិសខាងជើង តាមផ្លូវខេត្តដែលក្រាលកៅស៊ូប្រប នឹងប្រឡាយមេ កាត់ឃុំស្រះជីក ឃុំប៉ោយចារ ចម្ងាយ ២៣ គ.ម នឹងទៅដល់អាង ដែលមានផ្ទៃទឹកធំ សន្ធឹងជាប់ជើងមេឃ ។



*ផ្លូវទៅកាន់អាងត្រពាំងថ្ម ស្រុកភ្នំស្រុក ក្នុងខេត្តបន្ទាយមានជ័យ*

យោងតាម ប្រវត្តិដែល ចងក្រងទុកដោយអាជ្ញាធរ គឺពីលិចទៅកើតនៃ អាង ជាអតីតមហាផ្លូវភ្ជាប់ពីខេត្តបុរីរម្យ ខេត្តនគររាជសីមា (អតីតទឹកដីអាណាចក្រខ្មែរបច្ចុប្បន្ន ស្ថិតនៅប្រទេសថៃ) មកបន្ទាយឆ្មារ (ក្រុងតូច) កាត់តាមទំនប់អាងនេះ កាត់តាមស្ពានបុរាណមួយចំនួនមានស្ពានក្មេង ស្ពានស្រែង ឆ្ពោះទៅអតីតរាជធានីមហានគរ។ សព្វថ្ងៃគេឃើញនៅមានសេសសល់ បង្កាន់ដៃស្ពានជាប់ទំនប់លិច-កើតនៃអាងស្ពានក្មេងស្ពានស្រែង ដែលធ្វើពីថ្មបាយក្រៀមជាដើម ។

ក្នុងសម័យខ្មែរក្រហមកាន់អំណាច (១៩៧៥-ខែមករា ឆ្នាំ១៩៧៩) ក៏បានក្លាយជាអាងទឹកធំជាងគេនៅភាគពាយ័ព្យ និងនៅកម្ពុជាដែលស្ថាបនាដោយដៃទាសករ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៧ ដែលធ្វើឲ្យប្រជាជនកម្ពុជាស្លូតត្រង់ប្រមាណជាង ៧.០០០នាក់បានបាត់បង់ជីវិតនៅទីនោះ។

នៅខែសីហា ឆ្នាំ២០០៤ តាមរយៈក្រសួងធនធានទឹក និងឧតុនិយមបានសម្រេចស្តារឡើងវិញផ្នែកទំនប់ទ្វារទឹកនៃអាងនេះដោយប្រើជំនួយឥតសំណងនៃរាជរដ្ឋាភិបាលជប៉ុន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា ។ នៅឆ្នាំ ២០០៦ សម្តេចតេជោនាយករដ្ឋមន្ត្រី **ហ៊ុន សែន** និងឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជាបានអញ្ជើញសម្ពោធដាក់ឲ្យប្រើប្រាស់។ សមិទ្ធផលនេះបានប្រែក្លាយវាលទារុណកម្ម ការបង្អត់អាហារ ការឈឺមិនព្យាបាល ការនិរាសព្រាត់ប្រាសរបស់ប្រជាជនកម្ពុជា និងការកាប់សម្លាប់ក្នុងសម័យប៉ុល ពត ទៅជាតំបន់អភិវឌ្ឍន៍មួយ។ ទីនោះបានប្រែក្លាយទៅជាតំបន់កសិកម្ម និងទេសចរណ៍ធម្មជាតិតាមរយៈនៃការដាំដុះដំណាំស្រូវ ដំណាំចម្ការ និងការទស្សនាសត្វស្លាបដ៏

ច្រើនសម្បើម ។

**តំបន់អភិរក្សសត្វក្រៀលមានច្រើន និងធំជាងគេនៅកម្ពុជា និងអាស៊ីអាគ្នេយ៍ :**

យោងព្រះរាជក្រឹត្យ ជស/រកត/០២០០/១១០ ចុះថ្ងៃទី ២២ កុម្ភៈ ឆ្នាំ ២០០០ បានបង្កើតតំបន់គ្រប់គ្រង និងអភិរក្សដែនបម្រុងសត្វក្រៀលអាងត្រពាំងថ្មមានផ្ទៃដីរួម១២.៦៥០ហ.ត។ព្រះរាជក្រឹត្យនេះស្ថិតក្នុងបំណង :

ក.ការពារសត្វក្រៀល និងប្រភេទសត្វស្លាបកម្រផ្សេងទៀត ដែលកំពុងរងគ្រោះថ្នាក់ឲ្យស្ថិតស្ថេរគង់វង្សនៅប្រទេសកម្ពុជា ។

ខ. រក្សាប្រភពទឹកនៅក្នុងអាងត្រពាំងថ្មឲ្យមានប្រក្រតីភាព សម្រាប់ជម្រកសត្វទាំងនោះ និងសម្រាប់ស្រោចស្រពក្នុងវិស័យកសិកម្ម។

គ. រក្សាលំនឹងបរិស្ថានធម្មជាតិដែលជាទីជម្រកសម្រាប់ភាពសុខសាន្ត និងការបន្តពូជសត្វទាំងនោះ។

លោក ***ហុង វាសនា*** ប្រធានគម្រោងអភិរក្សសត្វក្រៀលអាងត្រពាំងថ្ម នៃរដ្ឋបាលព្រៃឈើក្រសួងកសិកម្មបាន ប្រាប់ទស្សនាវដ្ដីប្រជាជនថា ក្នុងតំបន់មានផ្នែកស្នូល ៣.០០០ហ.ត ដែលមិនឲ្យពលរដ្ឋប៉ះពាល់ទេ ដោយទុកសម្រាប់ជាទីបន្តពូជ ទីរកចំណីរបស់សត្វ។ មានផ្នែកទ្រនាប់ដែលអាចឲ្យពលរដ្ឋប៉ះពាល់បាន ដូចជាបង្កបង្កើនផល ប៉ុន្តែត្រូវគោរពលក្ខន្តិក:។

ចាប់តាំងពីបង្កើត និងដំណើរការនៅតំបន់នោះមកគឺមានជំនួយពីសមាគមអភិរក្សសត្វព្រៃ (WCS) ព្រមទាំងរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរដែនដីសមត្ថកិច្ចនិងពលរដ្ឋសហគមន៍។ជំនួយទាំងនេះបាន ជួយដល់ការងារអភិរក្ស ប្រកបដោយជោគ-ជ័យ ។

ទីនាះដំបូងមានលោក ***សំ វាសនា*** ជាអ្នកត្រួសត្រាយ ប៉ុន្តែលោក បានទទួលមរ-ណភាពដោយសារជំងឺគ្រុនចាញ់ ។អ្នកជំនាន់ក្រោយ ក៏បានបង្កើតមជ្ឈមណ្ឌល ***សំវាសនា*** មានការិយាល័យនៅវត្តរាជបូព៌ាក្រុងសៀមរាបខេត្តសៀមរាបបម្រើឲ្យសេវាទេសចរណ៍ ទៅតំបន់អភិរក្សសត្វ ជាការផ្តល់កិត្តិយសដល់លោក ។

មន្ត្រីគម្រោងបានអះអាងថា អាងត្រពាំងថ្មបានអភិរក្សសត្វស្លាប ម្រឹគ យ៉ាងតិច ១៨៩ ប្រភេទ ក្នុងនោះមានសត្វរងការគំរាមកំហែងខ្លាំង និងជិតផុតពូជ ១៨ ប្រភេទ ពិសេស គឺសត្វក្រៀលក្បាលក្រហមដែលកើនពី ២០០ ក្បាលឥឡូវមានប្រមាណ ៨០០ ក្បាល ។ គឺជាតំបន់អភិរក្ស ដែលមានសត្វក្រៀលច្រើនជាងគេនៅកម្ពុជាផង និងនៅអាស៊ីអាគ្នេយ៍ផងដែរ ។ តែបើគិតពីជំរំសត្វស្លាបអាងត្រពាំងថ្ម បានស្ថិតលំដាប់ទី ២ បន្ទាប់ពីតំបន់ព្រែកទាល់ ក្នុងបឹងទន្លេសាបខេត្តបាត់ដំបង ។ អាងនេះក៏មានសត្វស្លាបផ្តល់មោទនភាពដទៃទៀត ដូចជា ទាកាប៉ាព្រៃរាប់ពាន់ក្បាល តាដក់តូច តាដក់ធំ ត្រយ៉ងរនៀលក-ស ។ល។

លោក ***គៀនតន*** មន្ត្រីនគរបាលស្រុកភ្នំស្រុកប្រចាំសន្តិសុខ ក្រុមការងារសត្វក្រៀលអាងត្រពាំងថ្ម មានប្រសាសន៍ថា ការជំរឿនសត្វ ត្រូវបានធ្វើនៅរាល់ចុងខែ ហើយវត្តមាន សត្វគ្រប់ប្រភេទ លេចមុខច្រើននៅរាល់ចុងឆ្នាំ។ សត្វទាំងនោះ ពិសេសសត្វក្រៀល មានវត្តមានច្រើន ពីខែមករាដល់ខែមេសា ឬឧសភា ជារៀងរាល់ឆ្នាំ ។ គឺខែនេះហើយ ដែលជារដូវទាក់ទាញភ្ញៀវឲ្យមកទស្សនាដោយពេញចិត្ត ។



*ភោគផលកសិកម្មរបស់ប្រជាកសិករស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ*

លោក ***គៀន តន*** បន្តថា"ជាទូទៅមនុស្សបានយល់ និងស្រឡាញ់សត្វ ហើយផ្តល់សន្តិ-សុខសុវត្ថិភាព ភាពសុខសាន្ត និងការរីកធំធាត់ដល់តំបន់អភិរក្ស"។ ទោះយ៉ាងណាកម្លាំង និងក្រុមការងារមិនអាចធ្វេសប្រហែស ហើយលង់លក់ក្នុងលទ្ធផលល្អនេះទេ គឺត្រូវចុះល្បាតការ-ពារជាប្រចាំទើបធានាថាមិនថ្លោះធ្លោយ។

បើតាមអ្នកគ្រប់គ្រងគម្រោងនិងក្រុមការងារសត្វក្រៀលអាងត្រពាំងថ្មនាះបានឲ្យដឹងថាមកទល់ពេលនេះសត្វសំខាន់ៗក្នុងតំបន់អភិរក្សបានកើន រួមមាន: សត្វក្រៀលក្បាលក្រហម ៨៥០ក្បាល, ទាកាប៉ាព្រៃ ៣០០០ក្បាល, រនាលពណ៌២០០០ក្បាល, ត្រយ៉ងខ្លួនស ឬក្បាលខ្មៅ ២៤០០ក្បាល, តាដក់ធំ ៥០ក្បាល, តាដក់តូច ១០០ក្បាល , អកធំ ១៣០ក្បាល, អកត្រីក្បាលប្រផេះ ១២ក្បាល, អង្កត់ខ្មៅ ឬដំបងគ្រញូង ១៨ក្បាល, ចង្កៀលខ្យង ៤០០០ក្បាល. ខ្លែងខ្មៅ ៨០ក្បាល, ទុងប្រផេះ ១៥០០ក្បាល ... រមាំងជាង ១០ក្បាល ឈ្លូស ពស់ និងសត្វស្លាបគោក និងទឹក ម្រឹគ មច្ឆជាតិយ៉ាងច្រើនទៀត។

មន្ត្រីគម្រោងបានបន្តថា"ការងារអភិរក្សសត្វដែលរួមទាំងសត្វស្លាបទឹក សត្វស្លាបគោក ម្រឹគ រហូតដល់មច្ឆជាតិនៅតំបន់អាងត្រពាំងថ្ម បានចេញដំណើរពីសូន្យមកបច្ចុប្បន្ន ទទួលបានជោគជ័យយ៉ាងធំធេង"។ ក្នុងនោះក្រុមការងារបានទទួលជំនួយពីដៃគូអភិវឌ្ឍន៍ គឺសមាគមអភិរក្សសត្វព្រៃ (WCS) និងកំពុងខំដើរដោយខ្លួនឯង ។ គម្រោងក៏បានខិតខំពង្រឹងបណ្តុះបណ្តាលបច្ចេកទេសការងារ ដល់សហគមន៍ឲ្យចេះមើលប្រភេទសត្វ ការថែទាំ និងការពារ លើ



*ភាពសប្បាយរីករាយនៅអាងត្រពាំងថ្ម*



*តំបន់អភិរក្សសត្វស្លាបនៅតំបន់អេកូទេសចរណ៍*

ការអប់រំផ្សព្វផ្សាយ ការសង្គ្រោះសត្វ ការទប់ស្កាត់ បង្ក្រាបបទល្មើសលើសត្វជាដើម។

**ដើម្បីទៅមុខ ចាំបាច់ត្រូវមានការផ្សាភ្ជាប់រវាងការអភិវឌ្ឍ និងអភិរក្ស :**

លោកប្រធានគម្រោងអភិរក្ស សត្វក្រៀល អាងត្រពាំងថ្មបានបញ្ជាក់ថា "ទោះយ៉ាងណាការអភិរក្សត្រូវផ្សារភ្ជាប់ជាមួយការអភិវឌ្ឍ ។ និយាយដោយសាមញ្ញគឺ មិនអាចអត់មួយណាបានតែត្រូវមានតុល្យភាព" ។ ក្នុងនោះយើងអនុញ្ញាតិឲ្យ ពលរដ្ឋធ្វើស្រែក្នុងផ្នែកទ្រនាប់ និងបានបង្កើត "ស្រូវមិត្តសង្គ្រោះសត្វព្រៃ" ដែលជាធនាគារស្រូវមួយ ផ្ដល់ពូជឲ្យកសិករខ្ចីយកទៅដាំដុះ ហើយក្រុមការងារ និងសមាគម WCS ទទួលទិញស្រូវវិញក្នុងតម្លៃខ្ពស់ជាងទីផ្សារសេរី ១០ ទៅ១៥%។ តែកសិករត្រូវគោរពលក្ខខណ្ឌដូចជា មិនប៉ះពាល់សត្វ(មានចាប់ សម្លាប់ បរបាញ់ទាក់)មិនកាប់ដើមឈើមិនប្រើថ្នាំគីមី។ល។ នេះគឺចង់ឲ្យពលរដ្ឋ ចូលរួមលើការងារអភិរក្សសត្វ តែក៏ធ្វើឲ្យពួកគាត់ទទួលផលពីទីនេះដែរ។

លោកនិយាយបន្តថា បន្ថែមលើនោះ ក្រុមការងារ និងអាជ្ញាធរមូលដ្ឋានបានបង្កើតសហគមន៍ទេសចរណ៍ធម្មជាតិនៅភូមិសំបួរ ឃុំប៉ោយចារ ដើម្បីឲ្យប្រជាជនក្នុងមូលដ្ឋានសហការ នឹងមជ្ឈមណ្ឌល ***សំវាសនា*** ទទួលភ្ញៀវបរទេសមកទស្សនាសត្វក្រៀល និងកំសាន្តផ្សេងៗនៅតំបន់អាងត្រពាំងថ្ម។

លោក ***ប៉េង ប៊ុនថាវ៉ា*** មេឃុំ និងជាប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ឃុំប៉ោយចារមានប្រសាសន៍ថា ភ្ញៀវទេសចរបរទេស តាមរយៈការនាំ ឬកក់នៅខេត្តសៀមរាបបានមកទស្សនាសត្វក្រៀល និងងូតទឹកកំសាន្តនៅ អាងត្រពាំងថ្មក្នុងមួយឆ្នាំៗ ពី ៣០០-៤០០ នាក់ (ក្នុងម្នាក់ ១០ ដុល្លារ និងកម្រៃជូនដោយម៉ូតូ និងទុកម្នាក់ថ្លៃ៣ដុល្លារ)។ឆ្នាំ ២០១៣ សហគមន៍ទេសចរណ៍ ធម្មជាតិសំបួរ បានយកថវិកាពីចំណូលភ្ញៀវ ទៅកសាងផ្លូវក្នុងភូមិ បានមួយខ្សែ ។ ពលរដ្ឋសប្បាយចិត្ត ដែលពួកគេទទួលបានផលពីការចូលរួមអភិរក្សនេះជាក់ស្ដែង។

លោក ***ប៊ុនថាវ៉ា***បានបន្តទៀតថាឆ្នាំ២០១៣-២០១៤ នេះឃុំទទួលគម្រោងកាត់បន្ថយភាពក្រីក្រតំបន់បឹងទន្លេសាបដោយផ្អាកការស្ថាបនាផ្លូវទៅជាស្ថាបនាជាប្រឡាយនាំទឹកតូចៗក្នុងឃុំជំនួសវិញ។ នោះគឺដើម្បីលើកទឹកចិត្ត និងជំរុញឲ្យពលរដ្ឋខំធ្វើស្រែ ទាំងរដូវវស្សាទាំងរដូវប្រាំងឲ្យអស់សក្ដានុពលទឹកអាង។

ស្រូវប្រាំងប៉ុន្មានឆ្នាំចុងក្រោយនេះ ពិសេសឆ្នាំ២០១៤នៅទូទាំងឃុំបានកើនឡើងជាលំដាប់ ដែលវាអាចកាត់បន្ថយការរិះគន់ដែលថា រដ្ឋ និងម្ចាស់ជំនួយបរទេសខំស្ដារ និង អភិវឌ្ឍអាង អស់លុយដ៏ច្រើន តែបែរជាទុកឲ្យទឹកហូរចោល កសិករមានស្រែមិនធ្វើអស់លទ្ធភាព។

លោករំលឹកថាពេលនេះកសិករបានប្រើទឹកពីអាងដើម្បីដាំដំណាំបន្លែដំណាំហូបផ្លែ។ពោលគឺបន្ថែមលើធ្វើស្រែទាំងវស្សា និងប្រាំង ចិញ្ចឹមសត្វ ត្បាញរវៃសូត្រប្រពៃណីដ៏ល្បី និងសេវានានា ពីភ្ញៀវទេសចរជាតិរាល់ចុងសប្ដាហ៍ថ្ងៃឈប់សម្រាក ថ្ងៃបុណ្យប្រពៃណី។

ជាងនេះទៅទៀត ឥឡូវនេះផ្លូវខេត្តបំបែកពីផ្លូវជាតិលេខ ៦ ត្រង់ភូមិព្រៃមាន់មកដល់ខ្នង និងស្ពានទី១ នៃអាងត្រពាំងថ្មប្រវែង ២៣គ.ម ត្រូវបានក្រសួង និងមន្ទីរសាធារណការ និង ដឹកជញ្ជូន ស្ថាបនាជាផ្លូវក្រាលកៅស៊ូបម្រើឲ្យការធ្វើដំណើរកាន់តែងាយស្រួលជាងមុន។ នេះជាចំណងដៃថ្មីបន្ថែមទៀត បន្ទាប់ពីស្ដារឡើងវិញអាងត្រពាំងថ្មនិងប្រព័ន្ធប្រឡាយ សាលារៀន មណ្ឌលសុខភាព... របស់រាជរដ្ឋាភិបាលមានសម្ដេចតេជោ **ហ៊ុន សែន** ជាប្រមុខបានផ្ដល់ជូនពលរដ្ឋឃុំប៉ោយចារ ក៏ដូចអ្នកស្រុក ភ្នំស្រុក និងខេត្តបន្ទាយមានជ័យ។

លោកបន្តថា ជាក់ស្ដែងមូលដ្ឋានទាញប្រយោជន៍ពីអាង ដូចជា ៖

១. អភិរក្សសត្វក្រៀល និងសត្វនានា ហើយបង្កើតសហគមន៍ទេសចរណ៍ធម្មជាតិ រកចំណូលជូនសហគមន៍ (ភ្ញៀវបរទេស)។

២.ភ្ញៀវទេសចរជាតិក្នុង និងក្រៅខេត្តមកកំសាន្ត។

៣.ពលរដ្ឋក្នុងមូលដ្ឋានបម្រើសេវា និងលក់ដូរចំណីអាហារ។

លោកមេឃុំបាននិយាយ ទាំងញញឹមថា មរតកអ្នកជំនាន់មុន បានទុកជុំមាសដល់អ្នកស្រុកជំនាន់ក្រោយ នូវអាងត្រពាំងថ្មនេះ តាំងពីទឹកហូប ទឹកប្រើប្រាស់ និងស្រោចស្រពដំណាំ។ ផ្ដល់ត្រី ផ្ដល់លុយ ពីទេសចរណ៍ មិនចេះខ្វះ ទាំងខែវស្សា ទាំងខែប្រាំង។

លោក ***សេង គី*** អភិបាលស្រុកភ្នំស្រុកមានប្រសាសន៍ប្រាប់ ទស្សនាវដ្ដីប្រជាជនដែរថា ប៉ុន្មានឆ្នាំចុងក្រោយនេះ កសិករធ្វើស្រែ និងដាំដំណាំរួមផ្សំដោយប្រើទឹកអាងបានល្អជាងមុន។ ពលរដ្ឋចូលរួមថែរក្សាការពារសត្វ ហើយទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិឲ្យមកទស្សនាសត្វ និងកំសាន្តនៅអាង។ តាំងពីស្ថាបនារួចផ្លូវក្រាលកៅស៊ូភ្ជាប់ដល់អាង នាំឲ្យមានភ្ញៀវជាតិមកពីទីជិតឆ្ងាយក្នុង និងក្រៅខេត្តមកកំសាន្តរាប់រយនាក់នៅចុងសប្ដាហ៍ដែលពីមុនពុំមានជាប់លាប់ដូចនេះទេ។ ចំពោះថ្ងៃឈប់សម្រាក ថ្ងៃបុណ្យជាតិមានភ្ញៀវរាប់រយពាន់នាក់។ នៅថ្ងៃបុណ្យប្រពៃណីធំៗ ដូចជាបុណ្យភ្ជុំបិណ្ឌ, បុណ្យចូលឆ្នាំខ្មែរ និងបុណ្យចូលឆ្នាំចិនវិញ មានភ្ញៀវពី ១៥០០០ ទៅ២៥០០០នាក់ ក្នុងមួយថ្ងៃៗ។ ឯការប្រើប្រាស់ទឹកអាង និងប្រព័ន្ធប្រឡាយធារាសាស្ត្រសម្រាប់ធ្វើស្រែ និងដំណាំរួមផ្សំក៏ផុលផុសជាងមុនដែរ។

ពលរដ្ឋប្រកបរបរលក់ដូរចំណីអាហារ បែបធម្មជាតិ នៅលើខ្នងអាងបានកើនដល់រាប់សិបគ្រួសារ ហើយរកកម្រៃបានក៏ប្រសើរឡើងៗ។ ឯពលរដ្ឋប្រកបរបរ ផ្ដល់សេវាដឹកជញ្ជូនភ្ញៀវ សេវារោង ទូកកាណូត ដាក់ពោះវៀនកង់ឡានឲ្យភ្ញៀវលេងទឹក ក៏រកស៊ីបានផលច្រើនជាងមុនដែរ។



*រូបសំណាកលោកយាយវៃសូត្រ ក្នុងស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ*

លោក ***ហាញ់ វន្ថា*** អនុប្រធានមន្ទីរធនធានទឹក និងឧតុនិយម ខេត្តបន្ទាយមានជ័យមានប្រសាសន៍ថា កាលឆ្នាំ ២០០៤អាងត្រពាំងថ្មត្រូវបានស្តារឡើងវិញ ក្រោមជំនួយឥតសំណងរបស់រាជរដ្ឋាភិបាលជប៉ុន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា លើផ្នែកទំនប់អាងទ្វារទឹក គឺ ទំនប់ពីកើតទៅលិចប្រវែង១០គ.ម និងពីត្បូងទៅឰសានប្រវែង៦គ.ម។ បន្ទាប់មកក្រសួងធនធានទឹក និងឧតុនិយមអភិវឌ្ឍន៍បន្ថែមធ្វើឲ្យទំនប់អាង មានប្រវែង១០គ.ម គុណនឹង១០គ.ម និងស្ថាបនាឡើងវិញនូវប្រព័ន្ធប្រឡាយមេធំៗ ៣ខ្សែនៅឆ្នាំ២០០៨ និងបន្តមកបានស្ថាបនាប្រឡាយរងរំដោះទឹក ដែលមានប្រវែងរាប់សិបគីឡូម៉ែត្រ ។ នៅឆ្នាំ២០១៣-២០១៤ នេះបានស្ថាបនាប្រឡាយមេថ្មី២ខ្សែទៀត នៅប៉ែកខាងក្រោមភ្ជាប់តំបន់ស្រោចស្រពខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យដែលអនុវត្តដោយក្រុមហ៊ុនចិន ។ ប្រឡាយថ្មីសុទ្ធតែចាក់បេតុងនៅពោះប្រឡាយ ។ លោកមានប្រសាសន៍បន្តថា អាងនេះអាចស្តុកធារទឹកបាន១៨០លានម៉ែត្រត្រីគុណ នៅរដូវវស្សា និង១០០លានម៉ែត្រត្រីគុណនៅរដូវប្រាំង។ វាអាចផ្តល់ទឹកស្រោចស្រពស្រូវវស្សាបាន ១២០០០ ហ.ត ។ ស្រោចស្រពស្រូវប្រាំង និងស្រូវវស្សាដើមរដូវ ឬស្រូវស្រាលបង្កើនរដូវបានពី ៧៥០០ ហ.ត ឡើងទៅ។ អាងនេះគ្រប់គ្រងផ្ទាល់ដោយក្រសួងធនធានទឹក។

លោក ***ហាញ់ វន្ថា*** ទទួលស្គាល់ថា ពីមុនការប្រើប្រាស់ទឹកអាង ពុំទាន់អស់សក្តានុពលមែនតែចាប់តាំងពីឆ្នាំ ២០១៣មកការប្រើប្រាស់ទឹកមានការប្រែប្រួលវិជ្ជមានដោយកសិករនិងសហគមន៍ខិតខំទាញប្រយោជន៍ពីទឹក យកទៅបម្រើឲ្យវិស័យកសិកម្មកាន់តែច្រើនឡើងៗ និងទទួលបានទិន្នផលកាន់តែខ្ពស់ ។ ពលរដ្ឋក៏យល់ដឹងច្រើនជាងមុន ក្នុងការសន្សំសំចៃមិនប្រើទឹកខ្ជះខ្ជាយ ហើយមិនឲ្យទឹកហូរហួសស្រែចម្ការខ្លួនដោយមិនបានដាំដុះទាំងរដូវប្រាំងនិងវស្សា។

លោកប្រាប់ថា នៅឆ្នាំក្រោយក្រោមឥណទានធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្រសួងនឹងស្ថាបនាជើងទំនប់អាងដោយវាយសំណាញ់ និងរៀបថ្មទប់ការពាររលកទឹក និងកម្រិតហួសបរិមាណទឹកអាង អាចគំរាមកំហែងទំនប់ដូចកាលពីទឹកជំនន់ឆ្នាំ ២០១៣ កន្លងមកទៀត ។ នាពេលនេះ ប្រជាកសិករ នៅស្រុកភ្នំស្រុក និងព្រះនេត្រព្រះបានទទួលផលពីអាង ។ កសិករដែលធ្វើស្រែ ដោយធ្វើដីតាមបច្ចេកទេស ប្រើពូជស្រូវ ប្រើទឹក ប្រើជី និងថែទាំបានត្រឹមត្រូវ អាចទទួលផលពី ៣,៥ ទៅ ៥ តោនស្រូវក្នុង១ហ.ត។កសិករធ្វើស្រែតាមទម្លាប់ធម្មតា ទទួលផលពី ២,៥តោនទៅ៣.៥ស្រូវក្នុងមួយ ហ.ត ។ រីឯអ្នកដែលមានលទ្ធភាពធំ ដូច ជាលោក ***អ៊ឹង សៀងហ៊ី*** ម្ចាស់ដេប៉ូគ្រឿងយន្តកសិកម្ម ម៉ាកគូបូតា និងជាប្រធានក្រុម ហ៊ុន ***អ៊ឹង សៀងហ៊ី*** អន្តរជាតិ និងកសិករជាច្រើន ទៀតក្នុងខេត្ត និងមកពីខេត្តបាត់ដំបង ខេត្ត សៀមរាប បានធ្វើស្រែក្នុងទ្រង់ទ្រាយធំ នៅតំបន់ក្រោមនៃអាងត្រពាំងថ្មបានអះអាងថា ទិន្នផលស្រូវរបស់ខ្លួនបានពី៧ទៅ៩តោនក្នុងមួយហ.ត ។

ជួបជាមួយយើង ពលរដ្ឋជាកសិករជាច្រើនបាននិយាយថា ដោយសារតំបន់អភិរក្សសត្វក្រៀល និងជីវៈចម្រុះ តំបន់សហគមន៍ទេសចរណ៍ធម្មជាតិ និងតំបន់អភិវឌ្ឍន៍អាងត្រពាំងថ្មនៅកៀកនឹងលំនៅនិងភូមិឋានរបស់គាត់ ធ្វើឲ្យគាត់ងាយស្រួលចូលរួមអនុវត្ត ការបង្ការការពារ និងទាញផលប្រយោជន៍ពីអាងនេះ ហើយផលប្រយោជន៍នេះ នឹងបន្តទៅអនាគតកូនចៅតទៅទៀត។

កសិករបាននិយាយថា ចំណូលប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំរបស់ពួកខ្លួនប្រែប្រួលកើនឡើងជាលំដាប់ ឬអាចនិយាយថា បើប្រៀបធៀបនឹងមិនទាន់មានការអភិរក្ស និងអភិវឌ្ឍអាងនេះ គឺចំណូលកើនឡើងជាង ៥ ទៅ ១០ដង។

ផ្លែផ្កានៃការរីកចម្រើនរួម និងដោយឡែកទាំងនេះ ជាលទ្ធផលនៃគោលនយោបាយ និងការដឹកនាំដ៏ត្រឹមត្រូវ និងវាងវៃរបស់រាជរដ្ឋាភិបាលដឹកនាំដោយសម្តេចតេជោ **ហ៊ុន សែន** របស់គណបក្សប្រជាជនកម្ពុជា និងមន្ត្រីក្រុមការងារគណបក្សថ្នាក់កណ្តាល ថ្នាក់ខេត្ត ថ្នាក់ស្រុក ក៏ដូចជាក្រុមការងារថ្នាក់ជាតិដែលបានចុះជួយជាប្រចាំ ។ ពលរដ្ឋនិងមូលដ្ឋានបាន និងកំពុងទទួលបានផលប្រយោជន៍ ពីការអភិរក្ស និងអភិវឌ្ឍ ដែលត្រូវដើរទន្ទឹមគ្នានេះ៕



*អ្នកលក់ម្ហូបអាហារនៅអាងត្រពាំងថ្ម*




# ពូជស្រូវសំខាន់ទាំង១០

- កូនអើយមុខរបរស្រែចម្ការ
ទោះស្រូវវស្សាឬក៏ស្រូវប្រាំង
ចូរប្រឹក្សាជ្រើសយកពូជសម្រាំង
ដាំពូជខ្លាំងតម្រូវទៅទីផ្សារ ។

- ក្រសួងកសិកម្មបានផ្សព្វផ្សាយ
ទិន្នន័យគណនាវិជ្ជាមាត្រា
ពូជស្រូវខ្សាយសាយផលសព្វគ្រួសារ
មិនមុសាឲ្យប្រជាជួបស៊ុន ។

- ពូជដប់ប្រភេទអ្នកប្រាជ្ញសិក្សា
យ៉ាងពូជស្រូវស្រាលក្រអូបបាយទន់
បញ្ជាក់ថា ផលធារច្រើនពេកពន់
ជាពូជធន់មិនប្រកាន់រដូវ ។

- ពូជផលសារ អ៊ីអ៊ែរហុកប្រាំមួយ(១)
សែនពិដោរក្រអូបអស់សព្វស្រូវ
បាយទន់ស្រួយមានរសឆ្ងាញ់ពេកកូវ
ផលលក់ទៅថ្លៃលើស្រូវទីទៃ ។

- ពូជស្រូវកណ្តាលប្រកាន់រដូវ
ប្រឹក្សាក្បួនសាស្ត្រវិភាគទិន្នន័យ
មុនដាំត្រូវគិតប្រៀងប្រិតលក់លៃ
ឲ្យតម្លៃកែខៃស្នងឬព្រោះ ។

- ស្រូវផ្ការំដេងនូវផ្ការំដួល
កាលបុរាណពុំធ្លាប់បានឮសោះ
រមៀតឆ្មួលពិដោរនាមពីរោះ
យល់ដល់ឈ្មោះរសក្លិនបុស្បា ។

- ផ្កាច័ន្ទសែនសរក៏ឈ្មោះផ្កាដែរ
អង្ករគ្រាប់វែងលួនសថ្លា
ទាស់ត្រង់តែក្រអូបពុំដូចផ្កា
រសពិសាសឹងឆ្ងាញ់ទន់ល្មួតស្រួយ ។

- បីពូជស្រូវធ្ងន់ប្រកាន់រដូវ
សុទ្ធសឹងពូជល្អបន្សុទ្ធលើកស្ទួយ
រាំងជ័យនូវខាបួន(២) ខាប្រាំមួយ(២)
កបជាមួយស្រែក្រោមមានទឹកជ្រៅ ។

- ជាស្រូវសន្ទូងឬអាចពង្រោះ
អ្នកពិសោធសម្រាំងតាមតម្រូវ
ដើមលូតខ្ពស់ធន់ទ្រាំសព្វលើសស្រូវ
ទីទឹកជ្រៅអាស្រ័យនូវអាកាស ។

- មួយហិកតាផលឈានដល់ប្រាំតោន
ទំហំគួរខិនគ្រាប់វែងស្មើល្អណាស់
កូនអើយដាំស្រូវត្រូវស្គាល់ពូជច្បាស់
មុនប្រើប្រាស់កុំភ្លេចសួរប្រភព ៕

---

១- អ៊ីអ៊ែរ ៦៦: ជាឈ្មោះដាក់ឲ្យដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៏កសិកម្មកម្ពុជា

២-ខា ៤ ខា ៦ : ជាឈ្មោះដាក់ឲ្យដោយវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៏កសិកម្មកម្ពុជា

- ពូជស្រូវសំខាន់ៗ ..........

ដោយសាស្ត្រាចារ្យបណ្ឌិត ម៉ែន ស៊ីផាន់




## កើតរោគថ្លង់

នៅលើផ្លូវលំតាមជនបទ ឧទ្ធម្ភាគចក្រល្បាតមួយគ្រឿង ចុះចតកណ្តាលផ្លូវស្ទាក់រថយន្តបុរសម្នាក់ រួចប៉ូលីសចេញពីឧទ្ធម្ភាគចក្រស្រែកប្រាប់ ៖

- នែលោក! ប្រពន្ធលោកធ្លាក់ចេញពីរថយន្តតាំងពីប៉ុន្មាននាទីមុនម៉្លេះ លោកមិនដឹងទេឬ?

ស្រាប់តែបុរសបើករថយន្តសើចក្អាកក្អាយនិយាយ៖

- សណោងណោស ខ្ញុំអត់មានថ្លង់ទេ!

- ថាម៉េចហ្នឹង ថ្លង់មិនថ្លង់ស្អី?

- គឺប្រពន្ធខ្ញុំអង្គុយខាងក្រោយ ឡូឡាតាមផ្លូវ។ លុះអត់ឮសំឡេងឡូឡាទៀត ខ្ញុំស្មានតែត្រចៀកខ្លួនឯងកើតជំងឺថ្លង់ ប្រើការលែងកើតទៅហើយ ដឹងអីនាងធ្លាក់ដីសោះ ។

## ខ្ញុំយ៉ាប់ជាង

នាយកាត់ នាយកង ស្រវឹងទន់រៀងខ្លួនជជែកគ្នា ៖

កាត់ ៖ ខ្ញុំនេះយ៉ាប់មែនទែន ថ្ងៃមុនពេលត្រឡប់ពីស៊ីការវិញ ដោយសារស្រវឹងខ្លាំងពេកក៏ឆ្លោយមាត់ប្រាប់ការពិតដល់ប្រពន្ធថា ធ្លាប់រៀបការម្តងហើយកាលពីប៉ុន្មានឆ្នាំមុន ។

កង ៖ អ្ហែស គ្រាន់តែប៉ុណ្ណឹងមានអីធ្ងន់ធ្ងរ ។ ខ្ញុំឯណេះទើបយ៉ាប់ជាងបងឯងទៅទៀត ។ ម្សិលមិញពេលត្រឡប់មកពីចូលរួមពិធីឡើងផ្ទះមិត្តភក្តិ ព្រោះតែស្រវឹងខ្លាំងពេកក៏ឆ្លោយមាត់ប្រាប់ប្រពន្ធពីគម្រោងប្រុងលួចរៀបការជាមួយនារីម្នាក់ទៀត ។

## ជួយយ៉ាងម៉េច?

នារាត្រីខែចេត្រដ៏សែនស្អុះស្អាប់នាយម៉ាប់ដើរចេញពីបន្ទប់ដេក ដោយកាន់ផ្លិតបក់បណ្តើរនិយាយប្រាប់ប្រពន្ធបណ្តើរ ៖

- អើយមេឃយប់នេះ ម៉េចក៏ស្អុះស្អាប់ខ្លាំងម៉្លេះហ្ន៎? បងកំពុងនឹកគិតក្នុងចិត្តថា តើពួកអ្នកភូមិនឹងនឹកគិតយ៉ាងម៉េច ប្រសិនបើបងស្រាតខោអាវចេញអស់ ហើយទៅឈរនៅកណ្តាលផ្លូវខាងមុខផ្ទះ?

- អេហ៍ បើបងហ៊ានធ្វើអ៊ីចឹងមែន ពួកអ្នកភូមិមុខតែច្រឡំបងថាជា គីងកុង វង្វេងព្រៃ។ ដល់ពេលនោះ ខ្ញុំពុំដឹងជួយបងយ៉ាងម៉េចទេ៕

## លេខទូរស័ព្ទ

ក្នុងថ្នាក់រៀនមួយ អ្នកគ្រូសួរសិស្សរបស់ខ្លួន ៖

-រាល់ពេលគេសរសេរឈ្មោះអ្នកនិពន្ធដ៏ល្បីល្បាញជនជាតិបារាំងឈ្មោះ វិចទ័រហ៊ុយហ្គោ គេតែងបើកវង់ក្រចកហើយសរសេរលេខ (១៨០២-១៨៨៥) ភ្ជាប់តាមក្រោយ តើលេខនោះជាលេខអ្វី?

ពេលពួកសិស្សក្នុងថ្នាក់ទាំងអស់ កំពុងធ្វើក្បាលងេងើឆ្លើយមិនរួច ស្រាប់តែសិស្សតូចល្អិតម្នាក់លើកដៃឆ្លើយៈ

- បាទ ជម្រាបអ្នកគ្រូ លេខនោះជាលេខទូរស័ព្ទរបស់អ្នកនិពន្ធ វិចទ័រហ៊ុយហ្គោ ។

## ហាត់ផ្ញុំ

ក្រោយពិនិត្យសព្វគ្រប់រួច លោកវេជ្ជបណ្ឌិតប្រាប់នាយគាំ ៖

- អារម្មណ៍លោកខ្សោយណាស់ ងាយស្រួលនឹងត្រូវរងឥទ្ធិពលរំញោចធ្វើឲ្យតឹងតែងខ្លាំង។ យកល្អលោកត្រូវហាត់បន្ធូរអារម្មណ៍តឹងតែងដោយខ្លួនឯង។ពេលធ្វើការលោកគួរតែធ្វើការបណ្តើរ ច្រៀងលេងបណ្តើរ ដើម្បីកុំឲ្យខួរក្បាលតឹងតែងជាមួយការងារពេក។

- ថាម៉េច? ធ្វើការបណ្តើរ ច្រៀងបណ្តើរ ! អ្វីទៀតខ្ញុំធ្វើបាន តែបើឲ្យច្រៀងពេលកំពុងធ្វើការ ខ្ញុំធ្វើមិនបានដាច់ខាត។

- ម៉េចអ៊ីចឹង?

- ព្រោះមុខរបរខ្ញុំ មិនអនុញ្ញាតឲ្យខ្ញុំធ្វើអ៊ីចឹង។

- លោកប្រកបមុខរបរអ្វី?

- ផ្តុំព្រៃ ហែសពស្មោះ ! ៕

បោះពុម្ពដោយ រោងពុម្ព **អរិយធម៌** ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខណ្ឌទួលគោក-ភ្នំពេញ
H/P : 012 935 822 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com / ariyathoar@online.com.kh

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៦២

| | | | | |
|---|---|---|---|---|
| ១- | ឯ.ឧ | **កែ គឹមយ៉ាន** | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ | ១០០ ដុល្លារ |
| ២- | ឯ.ឧ | **ហ៊ុន ណេង** | ប្រធានគណៈកម្មការទី ៤ នៃរដ្ឋសភា | ១០០ ដុល្លារ |
| ៣- | ឯ.ឧ | **មិន ឃិន** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា និងលោកជំទាវ **ខួន ឆួន** | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | **ត្រាំ អ៊ីវតឹក** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសាធារណការ និងដឹកជញ្ជូន | ១០០ ដុល្លារ |
| ៥- | ឯ.ឧ | **ថោង ខុន** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍ | ១០០ ដុល្លារ |
| ៦- | ឯ.ឧ | **ប្រាក់ ចំរើន** | សមាជិកព្រឹទ្ធសភា | ១០០ ដុល្លារ |
| ៧- | ឯ.ឧ | **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០០ ដុល្លារ |
| ៨- | ឯ.ឧ | **លន់ លឹមថៃ** | ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | **ជៀង អំ** | ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | **អូស្មាន ហាស្សាន់** | ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | **សរ ចឺរុង** | ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | **ផា សុជាតិវង្ស** | ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | **ឈិត សុខុន** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | **ម៉ម ប៊ុននាង** | អនុប្រធានគណៈកម្មការទី ១០នៃព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | **ម៉ៅ ធនិន** | អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | **អ៊ុន វីរជាតិ** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ១០០ ដុល្លារ |
| ១៧- | ឯ.ឧ | **យូ តិរម្យ** | សមាជិកក្រុមការងារចុះខេត្តកំពង់ស្ពឺ ប្រធានក្រុមការងារចុះស្រុកឱរ៉ាល់ | ១០០ ដុល្លារ |
| ១៨- | គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | | | ១០០ ដុល្លារ |
| ១៩- | គណៈកម្មាធិការគណបក្សខេត្តសៀមរាប | | | ១០០ ដុល្លារ |
| ២០- | គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ | | | ៥០ ដុល្លារ |
| ២១- | គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី | | | ៥០ ដុល្លារ |
| ២២- | ឯ.ឧ | **លឹម គានហោ** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ២០០.០០០ ៛ |
| ២៣- | ឯ.ឧ | **ម៉ម ប៊ុនហេង** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៤- | ឯ.ឧ | **ថា យ៉ាវ** | អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា | ២១៣.៤៧០៛ |
| ២៥- | ឯ.ឧ | **ជូ យិនស៊ីម** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៦- | ឯ.ឧ | **អ៊ុក ប្រាថ្នា** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | ២០០.០០០ ៛ |
| ២៧- | ឯ.ឧ | **យឹម សារិទ្ធ** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ៥០ ដុល្លារ |
| ២៨- | ឯ.ឧ | **ប៉ាវ ហាមផាន** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | **សូ ជុងហួរ** | ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ | ៥០ ដុល្លារ |
| ៣០- | ឯ.ឧ | **ចាយ បូរិន** | អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម | ៥០ ដុល្លារ |
| ៣១- | ឯ.ឧ | **សួស យ៉ារ៉ា** | អ្នកតំណាងរាស្ត្រមណ្ឌលព្រះវិហារ | ៥០ ដុល្លារ |
| ៣២- | ឯ.ឧ | **នរៈ រតនៈវឌ្ឍនោ** | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ២០០.០០០ ៛ |
| ៣៣- | ឯ.ឧ | **ឃួន រ៉ានីន** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០ ដុល្លារ |
| ៣៤- | ឯ.ឧ.ឧ.សេនីយឯក | **មាស វីរិទ្ធ** | អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន | ៥០ ដុល្លារ |
| ៣៥- | ឯ.ឧ. | **បូន លឹមហេង** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ២០០.០០០៛ |
| ៣៦- | ឯ.ឧ | **សេង ទៀង** | ជំនួយការផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | ២០០.០០០៛ |
| ៣៧- | ឯ.ឧ | **ថោង ឃិន** | សមាជិកគណៈកម្មាធិការត្រួតពិនិត្យ នៃគណៈកម្មាធិការកណ្តាល | ៥០ ដុល្លារ |
| ៣៨- | ឯ.ឧ | **ម៉ៅ ប៊ុនណារិន** | សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា | ១០០.០០០៛ |
| ៣៩- | ឯ.ឧ | **ម៉ែន ស៊ុំផាន់** | សមាជិកព្រឹទ្ធសភា | ១០០.០០០៛ |
| ៤០- | ឯ.ឧ | **ប៉ាន ប៊ុនធឿន** | រដ្ឋលេខាធិការក្រសួងផែនការ | ១០០.០០០៛ |
| ៤១- | លោកជំទាវ | **ស៊ឹង ស៊ុយុត** | | ១០០.០០០៛ |
| ៤២- | ឯ.ឧ | **គឹម ផា** | ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤៣- | ឯ.ឧ | **ប៉ិច សុវណ្ណ** | | ១០០.០០០៛ |
| ៤៤- | ឯ.ឧបណ្ឌិត | **មាស ប៉ូ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១០០.០០០៛ |
| ៤៥- | លោកជំទាវ | **ឆិត្យ ចំនួតារីន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៤៦- | ឯ.ឧ | **ឆា ចំនួលីដា** | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៤៧- | ឯ.ឧ | **ម៉ែន វិបុល** | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤៨- | ឯ.ឧ | **ជួន ថេរ៉ាវ៉ាត** | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៤៩- | ឯ.ឧ | **ម៉ៅ ឡាំង** | អគ្គលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ១០០.០០០៛ |
| ៥០- | ឯ.ឧ | **ឆាយ ឫទ្ធិសែន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៥១- | ឯ.ឧ | **អ៊ុន ឆាលី** | សមាជិកគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណបក្សខេត្តកោះកុង | ១០០.០០០៛ |
| ៥២- | លោក | **អោម ចន** | ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិនៃអគ្គនាយកដ្ឋានពន្ធដារ | ១០០.០០០៛ |
| ៥៣- | លោក | **សាំ ពិសិដ្ឋ** | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ | ១០០.០០០៛ |
| ៥៤- | លោក | **សុខ វិសាលសម្បត្តិ** | អនុប្រធានក្រុមការងារចុះជួយឃុំព្រៃដើមថ្នឹង និងឃុំត្នោត១ ស្រុកស៊ីធរកណ្តាល ប្រធានក្រុមហ៊ុនសម្បត្តិវិសាល | ១០០.០០០៛ |
| ៥៥- | លោក | **សារូ រដ្ឋជាតិ** | មន្ត្រីសាលាខេត្តប៉ៃលិន | ៧០.០០០៛ |
| ៥៦- | លោកជំទាវ | **ខេង សំវ៉ាដា** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ៥០.០០០៛ |
| ៥៧- | ឯ.ឧ | **សាយ បូរិន** | ទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** | ៥០.០០០៛ |
| ៥៨- | ឯ.ឧ | **សេង គឹមសាន** | ជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** | ៥០.០០០៛ |
| ៥៩- | ឯ.ឧ | **ពត ចាន់នី** | សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម | ៥០.០០០៛ |
| ៦០- | ឯ.ឧ | **ហេង វណ្ណា** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦១- | លោក | **ស៊ាង ចាន់** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦២- | លោក | **ឃួន សំបូរ** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |

# អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ១៦២

| | | | | |
|---|---|---|---|---|
| ៦៣- | លោកជំទាវ | ស៊ើ ច័ន្ទថា | | ៥០.០០០៛ |
| ៦៤- | លោក | ជា វុទ្ធី | សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦៥- | កញ្ញា | ផាង និតហ្វើរ | មន្ត្រីក្រសួងទេសចរណ៍ | ៥០.០០០៛ |
| ៦៦- | លោក | ង៉ោ ម៉េងជួន | អភិបាលក្រុងប៉ោយប៉ែត | ៥០.០០០៛ |
| ៦៧- | លោក | អ៊ុំ រាត្រី | ប្រធានគណៈកម្មាធិការគណបក្សក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៨- | លោក | កែវ សែន | ប្រធានគណៈកម្មាធិការគណបក្សស្រុកអូរជ្រៅ | ៥០.០០០៛ |
| ៦៩- | លោក | សួន សុធី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៧០- | លោក | គាត ហ៊ុល | ប្រធានគណៈកម្មាធិការគណបក្សសង្កាត់ផ្សារកណ្តាល ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៧១- | លោក | ចាប ឌីណា | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ខណ្ឌដូនពេញ | ៥០.០០០៛ |
| ៧២- | ឯ.ឧ | វេង សាខុន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ៤០.០០០៛ |
| ៧៣- | លោក | លី សារី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ប្រធានមន្ទីររៀបចំដែនដី ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧៤- | លោក | គីម សុវណ្ណ | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧៥- | គណៈកម្មាធិការគណបក្សប្រជាជនប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម | | | ១០ ដុល្លារ |
| ៧៦- | ឯ.ឧ | ស៊ិន វុទ្ធី | សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៧៧- | ឯ.ឧ | ឈុំ វណ្ណារិទ្ធ | អភិបាលរងខេត្តបន្ទាយមានជ័យ | ៣០.០០០៛ |
| ៧៨- | លោក | ម៉ៅ សុខលីម | អនុប្រធានមជ្ឈមណ្ឌលជាតិវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខេត្តតាកែវ | ៣០.០០០៛ |
| ៧៩- | លោក | ចាន់ ស៊ុំណាត | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៨០- | លោក | ឃុ ពៅ | អភិបាលស្រុកស្វាយចេក | ៣០.០០០៛ |
| ៨១- | លោក | នេព វិសិដ្ឋ | អនុប្រធានគណៈត្រួតពិនិត្យគណបក្សខេត្តព្រះសីហនុ | ៣០.០០០៛ |
| ៨២- | កញ្ញា | កែវ សុជាតា | អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា សមាជិកាក្រុមការងារចុះខេត្តរតនគិរី | ៣០.០០០៛ |
| ៨៣- | សមាជិកគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | | | ២៥.០០០៛ |
| ៨៤- | ឯ.ឧ | ចុង ផែត | អភិបាលរងខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៨៥- | លោក | ឈា ប៊ុនរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៨៦- | លោក | ម៉ៅ ហាក់ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៨៧- | លោក | លឹម វីរក្ស | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ២០.០០០៛ |
| ៨៨- | លោក | លឹម ផេង | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ២០.០០០៛ |
| ៨៩- | លោក | ឃ្លោក សំអាង | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ២០.០០០៛ |
| ៩០- | លោក | ជា គីមលីន | ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ២០.០០០៛ |
| ៩១- | លោក | ទូច សារ៉េត | ប្រធានការិយាល័យគណនេយ្យកសិកម្ម ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៩២- | លោក | ហ៊្វាង ជ្រិន | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | ២០.០០០៛ |
| ៩២- | លោក | ម៉ី វុទ្ធា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ២០.០០០៛ |
| ៩៤- | លោក | អ៊ុក គឹមអាន | មន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ២០.០០០៛ |
| ៩៥- | លោក | គួច ចាន់និត្យ | អាជីវករ ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៩៦- | លោក | ប៊ូ ប៊ុនណារិទ្ធ | សមាជិកគណបក្សប្រជាជនកម្ពុជាក្រុងព្រះសីហនុ | ២០.០០០៛ |
| ៩៧- | លោក | លី សារុន | មន្ត្រីក្រសួងហិរញ្ញវត្ថុ | ១៥.០០០៛ |
| ៩៨- | លោក | អ៊ុច សាវន | អនុប្រធានមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ | ១៥.០០០៛ |
| ៩៩- | ឯ.ឧ | សេង សុមុនី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា | ១០.០០០៛ |
| ១០០- | ឯ.ឧ | ប៊ុញ សច្ចៈ | អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០១- | លោក | មុំ លីហួត | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ១០.០០០៛ |
| ១០២- | លោក | ជួន វណ្ណរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៣- | លោក | មឹម ឬស្ស | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៤- | លោក | សៅ សម្ផស្ស | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៥- | លោក | ឈុន ប៊ុនឈឿន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៦- | លោក | ថេង ប៊ុនតេង | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៧- | លោក | ស្វាយ សុគន្ធី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៨- | លោក | សុខ ចំណាន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១០៩- | លោក | សៅ សម្ភារ | ប្រធានការិយាល័យបណ្តុះបណ្តាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១១០- | លោក | ទិត ចរិយា | ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១១១- | លោក | សែម សំណាង | ប្រធានការិយាល័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១១២- | លោក | សុខ តារា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៣- | លោក | ស៊ូ ផល្លី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៤- | លោក | ហួត ធាន | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៥- | លោក | ទឹម វុដ្ឋារី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៦- | លោក | ណុប រៀមណី | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៧- | លោក | សារុន សម្បត្តិ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៨- | លោក | សរ វិចិត្រ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១១៩- | លោក | ទូច សុផល្លា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១២០- | លោក | ជុំ ឧត្តរ៉ា | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១២១- | លោក | ឈ្លាង ប៊ុយ | សមាជិកក្រុមការងារចុះខេត្តកណ្តាល | ១០.០០០៛ |
| ១២២- | លោក | យស់ ធុល | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២៣- | លោក | ឡុង ចន្ថា | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២៤- | លោក | ឡាច គីរ៉ាត់ | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង | ១០.០០០៛ |
| ១២៥- | លោក | ឈាង សុវណ្ណារ៉ា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ១០.០០០៛ |

# មាតិកា
# Contents



ព្រះរាជពិធីបុណ្យអុំទូក អកអំបុក បណ្តែតប្រទីប និងសំពះព្រះខែ ប្រព្រឹត្តទៅយ៉ាង អធិកអធម និងជោគជ័យ ៤


ពិធីចម្រើនព្រះជន្ម គម្រប់ ៨២ ឈាន ចូល ៨៣ ឆ្នាំរបស់ សម្តេចអគ្គមហាធម្ម-ពោធិសាល **ជា ស៊ីម** ៦


សម្តេចតេជោ **ហ៊ុន សែន** ក្នុងដំណើរបំពេញ ទស្សនកិច្ច នៅប្រទេសចិន ៧



សម្តេចតេជោ **ហ៊ុន សែន** អញ្ជើញចូលរួមកិច្ចប្រជុំ កំពូលអាស៊ានលើកទី ២៥ និងកិច្ចប្រជុំពាក់ព័ន្ធ នៅសហភាពមីយ៉ាន់ម៉ា ១០


សម្តេចតេជោ : កិច្ចព្រមព្រៀង ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ មិនមែនជាកិច្ចព្រមព្រៀង បញ្ចប់ដំណើរការរបស់តុលាការ ក្នុងរឿងក្តីព្រហ្មទណ្ឌឡើយ ១៤


សម្តេចក្រឡាហោម **ហេង សំរិន** អញ្ជើញជាអធិបតីបើក សិក្ខាសាលាពិគ្រោះយោបល់ លើសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់.... ១៦



**និពន្ធនាយក :**
**លោក តាក ស៊ុនអ៊ី**
**គណៈកម្មការនិពន្ធ**
១. លោក ខៀវ ណារី
២. លោក អ៊ឹម សុន្ទរៈ
៣. លោក វង្ស សារុធ
៤. លោក ទាវ សារៈមុនី
៥. លោក សុខ សុធន
**លេខានិពន្ធ**
១. លោក ជុំ សម្បត្តិ
២. លោក ម៉ក់ ឈិន
**អ្នកបកប្រែភាសា**
១. លោកស្រី ម៉ែន នារីសោភ័គ
**អ្នកថតរូប**
១. លោក សុផាត វីរៈមុនី
**វិចិត្រករ**
១. លោក ធា សារុធ


អាស័យដ្ឋាន :
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ :
០២៣ ២១៩ ០៦៥
**Address :**
**No 203 Preah**
**Norodom Bld.**
**Phnom Penh Cambodia**
**Tel : 023 219 065**




## ក្របមុខ

ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នៅរាជធានីភ្នំពេញ
(០៥-០៦-០៧ ខែវិច្ឆិកាឆ្នាំ២០១៤)


វិចារណកថា : ៣៦ ឆ្នាំនៃការតស៊ូប្រឹងប្រែង និងជ័យជម្នះប្រកបដោយ មោទនភាពរបស់ប្រជាជនកម្ពុជា ......... ១
Editorial : Cambodian People's 36 Years Efforts and ProudAchievements.............................. ១
⇨ គណបក្សប្រឆាំងកំពុងតែការពារនិទ្ទណ្ឌភាព ........................................................................ ៣

⇨ សកម្មភាពសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ........................................ ១៧
⇨ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែវិច្ឆិកា : ........................................................................ ១៩
⇨ លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច ........................................................................ ២០
⇨ លទ្ធផលក្នុងការខិតខំអនុវត្តតាមគោលដៅអាទិភាពទាំង ៧ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន...... ២១
⇨ វិស័យធនាគារបានចូលរួមយ៉ាងសកម្ម ក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច.................................. ២៣
⇨ វប្បធម៌ : រចនាប័ទ្មបន្ទាយស្រី ........................................................................ ២៥
⇨ វិទ្យាសាស្ត្រ សុខភាព : ឱសថធម្មជាតិ ៧ ប្រភេទ ជួយដល់ការរំលាយអាហារ ........................... ២៦
⇨ ទឹកដី មាតុភូមិ : អាងត្រពាំងថ្ម:ទីអភិរក្សនិងអភិវឌ្ឍន៍ដែលមានទាំងកសិកម្មនិងទេសចរណ៍........... ២៧
⇨ កំណាព្យ : ពូជស្រូវសំខាន់ទាំង១០...................... សំណើច ............................................ ៣១

ទស្សនាវដ្តី

# ប្រជាជន

THE PRACHEACHUN MAGAZINE










ឆ្នាំទី១៤ លេខ ១៦២ ខែវិច្ឆិកា ឆ្នាំ ២០១៤







ស្ពានជ្រោយចង្វារទី ២
ប្រវែង ៧២៥ ម៉ែត្រ
បើកឱ្យដំណើរការ
នៅថ្ងៃទី២ ខែវិច្ឆិកា
ឆ្នាំ២០១៤